**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Universite Royale de Droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នៅប្រទេសកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **សៅ ជាអ៊ិង**

លោក **សឿន ប៉េងស្រឿន**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ **ញឹក ទុច្ឆី**

ថ្នាក់បរិញ្ញាបត្រ ៖ **នីតិសាស្ត្រ**

ជំនាន់ទី ២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំឈ្មោះ **សៅ ដារ៉ារិទ្ធ និង សឿន ម៉េងស្រៀន** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី២៣ នៃ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ឆ្នាំសិក្សា២០១៩-២០២៣។

យើងខ្ញុំសូមថ្លែងអំណរគុណ និង សម្តែងនូវការកតញ្ញូតាធម៌ ជូនចំពោះ ៖

**លោកឪពុក និង អ្នកម្តាយ** ជាទីគោរព និងស្រលាញ់របស់កូនៗទាំងទ្វេ ដែលលោកអ្នកមានគុណបានផ្តល់កំណើតដល់រូបកូនទាំងពីរ និងបានចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មាន ប្រៀនប្រដៅ ថែមទាំងបានផ្តល់ក្តីស្រលាញ់ដល់កូនៗបានយ៉ាងល្អ រហូតមកដល់ពេលបច្ចុប្បន្ននេះ។ លោកអ្នកមានគុណបានប្រៀនប្រដៅ កូនៗឲ្យធ្វើអំពើល្អ ប្រកបរបរសុចរិត មានគុណធម៌ សុជីវធម៌ ក្លាយជាបុគ្គលល្អក្នុងសង្គម និងទឹកចិត្តស្រលាញ់ ឱ្យកូនល្អតាំងពីកុមារភាពរហូតដល់កូនៗបានបញ្ចប់ការសិក្សាកម្រិតថ្នាក់បរិញ្ញាបត្រ និងក្លាយខ្លួនជាធនធានមនុស្សដ៏សំខាន់នៅក្នុងសង្គមជាតិ។

យើងខ្ញុំ សូមថ្លែងអំណរគុណដល់ **ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ថ្នាក់ដឹកនាំ និងលោក លោកស្រីសាស្ត្រាចារ្យ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានប្រឹងប្រែងអស់ពីសមត្ថភាពក្នុងការបណ្តុះបណ្តាលចែករំលែក ព្រមទាំងផ្តល់នូវការអប់រំ ចំណេះដឹងបទពិសោធន៍ និងដំបូន្មានល្អជាច្រើន រួមទាំងការណែនាំបង្ហាត់បង្រៀនដល់យើងខ្ញុំ យ៉ាងយកចិត្តទុកដាក់ដើម្បីឱ្យយើងខ្ញុំបានសិក្សារៀនសូត្រនូវចំណេះដឹងជាច្រើន រហូតដល់បានបញ្ចប់ការសិក្សាប្រកបដោយភាពជោគជ័យ។

យើងខ្ញុំទាំងពីរ សូមថ្លែងអំណរគុណដល់ **សាស្ត្រាចារ្យជំនួយ ញឹក ឧត្តី** ដែលជាសាស្ត្រាចារ្យណែនាំរបស់រូបយើងខ្ញុំផ្ទាល់លើកិច្ចការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះ ដោយលោកបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីដឹកនាំ ផ្តល់ការប្រឹក្សា និងកែតម្រូវនូវរាល់ចំណុចខ្វះខាតទៅលើការស្រាវជ្រាវ និងការចងក្រងកិច្ចការសារណាបញ្ចប់ការសិក្សាមួយនេះ តាំងពីពេលចាប់ផ្តើមរហូតមកដល់ពេលបញ្ចប់ និងសម្រេចបាននូវកិច្ចការ ការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះ ដោយទទួលបាននូវលទ្ធផលល្អប្រសើរ។

ជាចុងក្រោយ ដើម្បីជាកិច្ចតបស្នង និងការដឹងគុណ យើងខ្ញុំសូមជូនពរដល់ លោកអ្នកមានគុណ ឯកឧត្តម លោក លោកស្រី និង សាស្ត្រាចារ្យទាំងអស់ ឱ្យជួបតែសំណាងល្អ សេចក្តីសុខ សេចក្តីចម្រើន ជោគជ័យគ្រប់ភារកិច្ច និងសូមប្រសិទ្ធិពរជ័យ សិរីមង្គល បវរមហាប្រសើរ សូមឱ្យជួបនូវពុទ្ធពរទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

យើងខ្ញុំជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី២៣ ឆ្នាំសិក្សា២០១៩-២០២៣ បានសរសេរតាក់តែងសារណាបញ្ចប់ការសិក្សា ក្រោមប្រធានបទ **ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា។** កត្តាចម្បង ដែលបានជម្រុញទឹកចិត្តយើងខ្ញុំក្នុងការសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយនេះមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះ គឺដោយសារតែយើងខ្ញុំមានចំណាប់អារម្មណ៍យ៉ាងខ្លាំងនៅក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដែលជាយន្តការថ្មីមួយ ដើម្បីជួយសម្រួលដល់វិស័យយុត្តិធម៌កម្ពុជា ក៏ដូចជាមានភាពងាយស្រួលនៅក្នុងការស្វែងរកដំណោះស្រាយឆាប់រហ័ស។

ក្នុងការចង់ក្រងជាសារណាបញ្ចប់ការសិក្សានេះ បានទាមទារឱ្យមានការខិតខំប្រឹងប្រែងដោយភាពអត់ធ្មត់និងមានទំនួលខុសត្រូវខ្ពស់ ដើម្បីជម្នះនូវរាល់ឧបសគ្គ និងការលំបាកផ្សេងៗ ដោយយើងខ្ញុំបានត្រូវធ្វើការស្រាវជ្រាវយ៉ាងស៊ីជម្រៅ អំពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា ឱ្យមានភាពយល់ច្បាស់បំផុតតាមដែរអាចធ្វើទៅបាន ដើម្បីជាគំនិតសម្រាប់ខ្លឹមសារសារណា។ គោលបំណងនៃការខិតខំប្រឹងប្រែងនេះ គឺសង្ឃឹមថាសរណាមួយនេះបានផ្តល់ជាចំណេះដឹងបន្ថែមមួយទៀត សម្រាប់យើងខ្ញុំដែលជាអ្នកស្រាវជ្រាវ ដ៏ដូចជាផ្តល់ជាឯកសារមួយ សម្រាប់អ្នកស្រាវជ្រាវផ្សេងទៀតដែលបានជ្រើសរើសនូវ ប្រធានបទប្រហាក់ប្រហែលនេះ និងសម្រាប់ជាទុនជូនដល់អ្នកដែលចង់យល់ដឹងពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា ដូចគ្នាផងដែរ។ ហេតុដូច្នេះ យើងខ្ញុំសង្ឃឹមថា ស្នាដៃមួយនេះនឹងផ្តល់នូវគុណប្រយោជន៍លើអ្នកសិក្សាស្រាវជ្រាវលើការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងផ្តល់ជាសារៈប្រយោជន៍ដល់អ្នកដែលនឹងអាចត្រូវប្រើយន្តការនេះផងដែរ ព្រោះអនាគត អ្នកសិក្សាស្រាវជ្រាវក៏អាចនឹងជួបប្រទះបញ្ហាវិវាទជាច្រើនដូចជា វិវាទរដ្ឋប្បវេណី វិវាទការងារ និងវិវាទពាណិជ្ជកម្មជាដើម។

ជាចុងក្រោយ យើងខ្ញុំសូមអភ័យទោសទុកជាមុន និងសូមស្នើសុំនូវក្តីអនុគ្រោះអធ្យាស្រ័យពីសំណាក់អ្នកស្រាវជ្រាវ និងសាស្ត្រាចារ្យនានាចំពោះរាល់កំហុសឆ្គងផ្សេងៗដូចជា អក្ខរាវិរុទ្ធ និងខ្លឹមសារ ដែលកើតមានឡើងដោយអចេតនា ត្បិតចំណេះដឹងរបស់យើងខ្ញុំនៅមានកម្រិតនៅឡើយ។ លើសពីនេះទៅទៀត យើងខ្ញុំរង់ចាំទទួលនូវរាល់មតិកែលម្អ ក៏ដូចជាដំបូន្មានល្អៗទាំងអស់ សម្រាប់ជាទុនក្នុងការកែលម្អ និងអភិវឌ្ឍចំណេះដឹងលើប្រធានបទមួយនេះឱ្យកាន់តែល្អប្រសើរឡើងមួយកម្រិតទៀត។ យើងខ្ញុំសូមអរព្រះគុណ និងអរគុណទុកជាមុនសម្រាប់ការបញ្ចេញមតិសម្រាប់កែលម្អនានាមកលើស្នាដៃមួយនេះ។

# មាតិកា

**ទំព័រ**


**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ**

**ផ្នែកទី១៖ និយមន័យនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ** ........................ ៣

**ផ្នែកទី២.ប្រវត្តិនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា** ...... ៣

កថាភាគទី១៖ បទពិសោធន៍ជាទំនៀមទម្លាប់ និង ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ........................ ៣

កថាភាគទី២៖ ប្រទេសកម្ពុជាឆ្ពោះទៅកាន់ការដោះស្រាយវិវាទ ........................ ៤

កថាភាគទី៣៖ ការវិវត្តន៍នៃក្រមខណ្ឌច្បាប់ក្នុងការឆ្លើយតបទៅនឹងកំណែទម្រង់ ច្បាប់ និង យុត្តិធម៌សម្រាប់ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ ........................ ៥

**ផ្នែកទី៣៖ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ** ........................ ៧

**ជំពូកទី២**

**ប្រភេទវិវាទឯកជននៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ**

**ផ្នែកទី១៖ វិវាទរដ្ឋប្បវេណី** ........................ ៩

កថាភាគទី១៖ និយមន័យនៃវិវាទរដ្ឋប្បវេណី ........................ ៩

កថាភាគទី២៖ មូលហេតុនៃវិវាទរដ្ឋប្បវេណី ........................ ១០

១.វិវាទពាក់ព័ន្ធទៅនឹងទំនាក់ទំនងទ្រព្យសម្បត្តិ ........................ ១០

២.វិវាទពាក់ព័ន្ធទៅនឹងទំនាក់ទំនងញាតិ ........................ ១០

កថាភាគទី៣៖ ដំណោះស្រាយវិវាទរដ្ឋប្បវេណី ........................ ១១

**ផ្នែកទី២៖ វិវាទការងារ** ........................ ១២

កថាភាគគទី១៖ ប្រភេទនៃវិវាទការងារ ........................ ១២

១.វិវាទការងារបុគ្គល ........................ ១២

២.វិវាទការងាររួម ........................ ១៣

កថាភាគទី២៖ មូលហេតុនៃវិវាទការងារ ........................ ១៣

កថាភាគទី៣៖ ដំណោះស្រាយវិវាទការងារ ........................ ១៤

១.នីតិវិធីដោះស្រាយវិវាទបុគ្គលនៅក្រៅប្រព័ន្ធតុលាការ ........ ១៥
២.នីតិវិធីដោះស្រាយវិវាទរួមនៅក្រៅប្រព័ន្ធតុលាការ ........ ១៨
**ផ្នែកទី៣៖ វិវាទពាណិជ្ជកម្ម** ........ ២២
**កថាភាគទី១៖** មូលហេតុនៃវិវាទពាណិជ្ជកម្ម ........ ២៣
**កថាភាគទី២៖** ដំណោះស្រាយវិវាទពាណិជ្ជកម្ម ........ ២៣

## ជំពូកទី៣

## នីតិវិធីនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

**ផ្នែកទី១៖ ការចរចា** ........ ២៥
**កថាភាគទី១៖ និយមន័យនៃកាចរចា** ........ ២៥
**កថាភាគទី២៖ ដំណាក់កាលនៃការចរចា** ........ ២៦
១.ដំណាក់កាលត្រៀម ........ ២៦
២.ដំណាក់កាលចាប់ផ្តើម ........ ២៨
៣.ដំណាក់កាលបញ្ចប់ ........ ២៩
**ផ្នែកទី២៖ សន្ធានកម្ម (ការសម្រុះសម្រួល)** ........ ៣១
**កថាភាគទី១៖និយមន័យនៃសន្ធានកម្ម** ........ ៣១
**កថាភាគទី២៖ ដំណើរការសន្ធានកម្ម** ........ ៣៣
១.ការចាប់ផ្តើមសន្ធានកម្ម ........ ៣៣
២.ការជ្រើសរើសសន្ធានការី ........ ៣៤
៣.ការបើកកិច្ចប្រជុំ ........ ៣៥
៤.ការបញ្ចប់សន្ធានកម្ម ........ ៣៦
**កថាភាគទី៣៖ គុណសម្បត្តិ និងគុណវិបត្តិនៃសន្ធានកម្ម** ........ ៣៨
១.គុណសម្បត្តិ ........ ៣៨
២. គុណវិបត្តិ ........ ៤០
**កថាភាគទី១៖ និយមន័យនៃមជ្ឈត្តការ** ........ ៤២
**កថាភាគទី២៖ ដំណើរការមជ្ឈត្តការ** ........ ៤២
១.ការផ្តួចផ្តើមដំណើរការមជ្ឈត្តការ ........ ៤២
២.ការបង្កើតវេទិកាមជ្ឈត្តកម្ម ........ ៤៦
៣.នីតិវិធីមុនសវនាការ ........ ៤៨

៤.សវនាការមជ្ឈត្តការ ......................................................... ៥១

៥.ការធ្វើសេចក្តីសម្រេច ឬមជ្ឈត្តវិនិច្ឆ័យ ......................................................... ៥២

**កថាភាគទី៣៖ គុណសម្បត្តិ និងគុណវិបត្តិនៃមជ្ឈត្តការ** ......................................................... ៥៤

១.គុណសម្បត្តិ ......................................................... ៥៤

២. គុណវិបត្តិ ......................................................... ៥៦

**សេចក្តីសន្និដ្ឋាន** ......................................................... ៥៧

**អនុសាសន៍** ......................................................... ៥៨

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

រដ្ឋធម្មនុញ្ញ គឺជាច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជា ។ រាល់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ទាំងឡាយ របស់ព្រះរាជាណាចក្រកម្ពុជា ត្រូវអនុលោមទៅតាមរដ្ឋធម្មនុញ្ញ បើពុំនោះសោតច្បាប់ និងលិខិត បទដ្ឋានគតិយុត្តទាំងឡាយ នោះនឹងអធម្មនុញ្ញភាពដោយយល់ពីសារៈសំខាន់នៃរដ្ឋធម្មនុញ្ញ។ អនុលោមតាម មាត្រា ១២៨ថ្មី និង ១២៩ថ្មី នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ បានចែងបញ្ជាក់ថា : អំណាចតុលាការគ្របដណ្តប់ទៅលើ រឿងក្តី ទាំងអស់រួមទាំងរឿងក្តីរដ្ឋបាលផងដែរ និងមានតែចៅក្រមជំនុំជម្រះប៉ុណ្ណោះ ដែលមានសិទ្ធិជម្រះក្តីឱ្យ ចាញ់ឬឈ្នះ ឆ្លងតាមរយៈ អត្ថន័យនេះ យើងអាចធ្វើសេចក្តីសំយោគបាន នៅពេលដែលមានវិវាទកើតឡើង គ្រប់ រឿងក្តី ទាំងអស់រួមមានវិវាទឬរឿងក្តីព្រហ្មទណ្ឌ- រដ្ឋប្បវេណី - ពាណិជ្ជកម្ម - ការងាររដ្ឋបាល[1]។ល។ ត្រូវបញ្ជូនទៅ តុលាការ ដើម្បីប្រគល់ឱ្យចៅក្រមជំនុំជម្រះធ្វើ[2] "ការដោះស្រាយវិវាទក្នុងប្រព័ន្ធតុលាការប៉ុន្តែនៅក្នុងបរិបទថ្មីដែល ប្រទេសកម្ពុជា បានធ្វើសមាហរណកម្មនៃក្របខ័ណ្ឌច្បាប់របស់ខ្លួន ដើម្បីឱ្យមានទំនើបកម្មនៅក្នុងពិភពលោក ទើបបច្ចុប្បន្ននេះ ប្រទេសកម្ពុជាដែលជាព្រះរាជាណាចក្រអច្ឆរិយ បានអនុម័តនូវលិខិតបទដ្ឋានគតិយុត្តមួយ ចំនួនធំ ដែលជាគោលបំណងជាចម្បង គឺដើម្បីណែនាំឱ្យស្គាល់អំពីទស្សនទានទំនើប គ្រាន់បានទុកជាពុទ្ធិដល់ និស្សិត អ្នករៀបរៀងក្នុងការសិក្សាស្រាវជ្រាវ អ្នកមានវិជ្ជាជីវៈកម្ពុជា និងចងក្រងដើម្បីទុកជាវណ្ណកម្ម ពាក់ព័ន្ធនឹង ប្រធានបទស្តីពី "**ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ**" ដែលហៅកាត់ថា **ADR** ។

ដោយយោងតាមទស្សនាទានជាមូលដ្ឋាននៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺជាផ្នែកមួយ ដែលគេអាចមើលឃើញនៅ ក្នុងការអនុវត្តន៍ប្រចាំថ្ងៃក្នុងប្រទេសកម្ពុជា ។ **ឧទាហរណ៍** ការចរចាគឺជាផ្នែកចម្បង នៃកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសកម្ពុជាក្នុងដំណោះស្រាយវិវាទផ្សេងៗ។ វាគឺជាជំហានដំបូងជាធម្មជាតិក្នុង ដំណោះស្រាយវិវាទភាគច្រើន ចាប់ពីវិវាទដ៏សាមញ្ញនៅតាមទីផ្សា រហូតដល់វិវាទដែលមានវិសាលភាពជាងនេះ ដូចជាពាក់ព័ន្ធទៅនឹងគម្រោងសាងសង់ដ៏ធំមួយជាដើម ។ ស្រដៀងគ្នានេះ សន្ទានកម្មក៏ជាផ្នែកមួយនៃប្រពៃណី របស់កម្ពុជាដែរ។ **ឧទាហរណ៍** គូស្វាមីភរិយា ទាំងឡាយ តែងតែស្វែងរកសន្ទានកម្ម ជាញឹកញាប់ ពីសំណាក់ ព្រឹទ្ធាចារ្យក្នុងភូមិ ដែលមានការគោរពរាប់អានពីអ្នកផង ឬពីក្រុមប្រឹក្សាឃុំសង្កាត់នៅតាមមូលដ្ឋាន លើវិវាទក្នុង ជីវិតអាពាហ៍ពិពាហ៍របស់ខ្លួន។ ហើយទោះបីជា មជ្ឈត្តការ មិនមានការនិយមដូចនោះក៏ដោយ ក៏ក្នុងដំណោះ ស្រាយវិវាទទំនើបៗ វាបានក្លាយទៅជាយន្តការមួយដែលមានសារៈសំខាន់កាន់តែខ្លាំងឡើងដែរ។ ក្រុមប្រឹក្សា អាជ្ញាកណ្តាល ដែលត្រូវបានគេទទួលស្គាល់ជាទូទៅនោះ បានធ្វើមជ្ឈត្តការ លើបញ្ហាសំខាន់ៗជាច្រើនពាក់ព័ន្ធ នឹងការគ្រប់គ្រងកម្មករនិយោជិក ក្នុងវិស័យឧស្សាហកម្មកាត់ដេរ និងវាយនភ័ណ្ឌ និង វិស័យ សណ្ឋាគារ ។ ឥឡូវ

[1] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា ១២៨ (ថ្មី)។

[2] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា១២៩ (ថ្មី) ។

នេះ ដោយសាររាជរដ្ឋាភិបាលបានអនុម័តច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មរួចមក តួនាទីរបស់ មជ្ឈត្តការនឹងពង្រីកទៅដល់មជ្ឈដ្ឋានពាណិជ្ជកម្មថែមទៀត ជាពិសេស នៅពេលដែលមជ្ឈមណ្ឌលមជ្ឈត្តការជាតិរបស់ក្រសួងពាណិជ្ជកម្ម ចាប់ផ្តើមដំណើរការ[3]។

ជាលទ្ធផល ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ បានក្លាយជាផ្នែកដ៏សំខាន់នៃប្រព័ន្ធច្បាប់ជាផ្លូវការរបស់ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។ ហេតុអ្វីបានជាប្រទេសកម្ពុជា អនុម័តច្បាប់ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការទាំងនេះ ដើម្បីយល់ដឹងអំពីផលប្រយោជន៍នៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គេត្រូវត្រឡប់ទៅស្វែងយល់អំពីចរិតនៃវិវាទ និងនីតិវិធីជាមុនសិន។

តើអ្វីទៅគឺជាការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ? តើនីតិវិធីនៅក្នុងការដោះស្រាយវិវាទនៅក្រៅប្រព័ន្ធតុលាការមានអ្វីខ្លះ? តើការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការបានផ្តល់សារៈប្រយោជន៍អ្វីខ្លះ?

នៅសារណានេះ និងសិក្សាលើចំណុចចម្បងធំៗដោយមានការបែងចែកជា ៣ ជំពូកដូចតទៅ៖

- ជំពូកទី១៖ សញ្ញាណទូទៅនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- ជំពូកទី២៖ ប្រភេទវិវាទនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- ជំពូកទី៣៖ នីតិវិធីនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

[3] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា

# ជំពូកទី១
# សញ្ញាណទូទៅនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

# ជំពូកទី១
# សញ្ញាណទូទៅនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
## ផ្នែកទី១៖ និយមន័យនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

**Alternative Dispute Resolution (ADR)** មានន័យថាការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺជាការដោះស្រាយវិវាទដោយមិនឆ្លងកាត់នីតិវិធីតុលាការ ឬជាជម្រើសដ៏ល្អប្រសើររបស់គូភាគីវិវាទ ដែលបានឯកភាពគ្នាធ្វើការដោះស្រាយវិវាទដោយមិនចូលឬមុននឹងចូលទៅតុលាការ។ វាជាការដោះស្រាយវិវាទដោយការជ្រើសរើសរបស់គូភាគីវិវាទក្នុងការដោះស្រាយវិវាទណាមួយដោយមិនឆ្លងកាត់តុលាការហើយទាមទារឱ្យគូភាគីត្រូវតែព្យាយាមដោះស្រាយដោយសន្តិវិធីដើម្បីទទួលបានជោគជ័យ ។

ប៉ុន្តែវិធីសាស្ត្រនេះ មិនមែនជាជម្រើសចុងក្រោយបង្អស់របស់គូភាគីវិវាទឡើយ ព្រោះគូភាគីវិវាទអាចធ្វើការជ្រើស រើសនូវការដោះស្រាយវិវាទតាមផ្លូវតុលាការដោយផ្ទាល់ ឬបន្ទាប់ពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមិនទទួលបានជោគជ័យ។ ស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រមូលផ្តុំទៅដោយទម្រង់ជាច្រើននៃវិធី ដោះស្រាយវិវាទ ដែលមួយចំនួនមានលក្ខណៈសាមញ្ញ និងខ្លះទៀតមានលក្ខណៈថ្មីប្លែក ។ ការចរចា សន្ធានកម្ម និងមជ្ឈត្តការ គឺជាទម្រង់ទូទៅបំផុតនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ។

ប៉ុន្តែដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មានឫសគល់ប្រវត្តិសាស្ត្រយ៉ាងជ្រាលជ្រៅនៅក្នុងបណ្តាប្រទេស និងវប្បធម៌ជាច្រើន។ **ឧទាហរណ៍** នៅប្រទេសកម្ពុជាដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជាផ្នែកមួយដ៏សំខាន់នៅក្នុងប្រព័ន្ធដោះស្រាយវិវាទតាមទំនៀមទម្លាប់នៅតាមភូមិស្រុកជាដើម។

## ផ្នែកទី២.ប្រវត្តិនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា
### កថាភាគទី១៖ បទពិសោធន៍ជាទំនៀមទម្លាប់ និងប្រវត្តិសាស្ត្រប្រទេសកម្ពុជា

ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មានអាយុកាលជាយូរណាស់មកហើយក្នុងប្រទេសកម្ពុជា[4]។ជារឿយៗ ប្រជាជនដោះស្រាយជម្លោះរបស់ពួកគេដោយផ្អែកទៅលើយន្តការប្រពៃណី និងវប្បធម៌ក្នុងសហគមន៍របស់ខ្លួន។ ការអនុវត្តនេះត្រូវបានគេហៅថាជា "ការសម្របសម្រួល ឬការផ្សះផ្សារ។ **ឧទាហរណ៍** ការដោះស្រាយដោយចាស់ទុំ នៅក្នុងស្រុក ឬប្រធានភូមិ ហើយដែលវិធីនេះគឺជា វប្បធម៌សន្តិភាព ដែលតែងមាននៅតាមមូលដ្ឋាន។ (ទស្សនៈនេះមានន័យថា បុគ្គល ឬ ក្រុមមនុស្សនៅក្នុងភូមិ ធ្វើការជាមួយគ្នាដើម្បីឆ្លើយតបទៅនឹងបញ្ហា (ដូចជាការធ្វើកិច្ចការប្រចាំថ្ងៃដោយមានការសហការគ្នាល្អ) ហើយនឹងការចងក្រងជាគ្រួសារតូចមួយ)។ រចនាសម្ពន្ធ័សង្គមនេះគឺផ្តោតសំខាន់ផងដែរទៅលើសុវត្ថិភាពរបស់សមាជិកនីមួយៗ។ ជាលក្ខណៈប្រពៃណី បងប្អូន

[4] ទិដ្ឋភាពទូទៅនៃប្រព័ន្ធច្បាប់ និងតុលាការកម្ពុជា និងការខិតខំប្រឹងប្រែងនាពេលថ្មីៗនេះ ក្នុងកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ ក្នុងសេចក្តីផ្តើមនៃច្បាប់កម្ពុជា,លោក គង់ ផល្លាក (Konrad-adenauer-stiftung,២០១២ ទំព័រ១២ )។

ឬអ្នកជិតខាងដែលមានទំនាក់ទំនងជិតដិត គឺជាបុគ្គលទីមួយដែលភាគីមានវិវាទពឹងឱ្យមក ជួយដោះស្រាយជម្លោះមុននឹងមានភាគីទីបីដែលឯករាជ្យ តួអង្គសំខាន់ដែលដើរតួនាទីជាភាគីទីបី នៅក្នុងការសម្របសម្រួលគឺចាស់ទុំ ប្រធានភូមិ ព្រះសង្ឃ អាចារ្យ និងមនុស្សសំខាន់ ឬល្បីដែលភាគីទុកចិត្ត[5]។ អាចារ្យ ព្រះសង្ឃ និងចាស់ទុំប្រើប្រាស់បទពិសោធន៍ និងចំណេះដឹងពីប្រពៃណី ដំបូន្មានរបស់ព្រះពុទ្ធនៅក្នុងការណែនាំ និងបង្រៀនមនុស្សដែលមានវិវាទគ្រួសារនិងវិវាទពាក់ព័ន្ធនឹងដីធ្លី។ ប៉ុន្តែនៅពេលជម្លោះមាន ភាពធ្ងន់ធ្ងរ ជម្លោះនោះនឹងត្រូវបញ្ជូនទៅប្រធានភូមិ[6]។ ប្រធានភូមិដែលមានការរៀនសូត្រផ្អែកលើប្រពៃណី និង ដំបូន្មានព្រះពុទ្ធក្នុងការផ្តល់នូវដំណោះស្រាយ ចំណែកឯប្រធានភូមិដែលមិនបានរៀនសូត្រផ្តល់នូវដំណោះស្រាយដោយផ្អែកលើការយល់ឃើញផ្ទាល់ខ្លួន។ មុនឆ្នាំ១៩៧០ ព្រះមហាក្សត្រក៏ដើរតួនាទីជាភាគីទីបី ព្រោះព្រះអង្គធ្វើព្រះរាជសវនាការ ដែលប្រជាជនអាចយកជម្លោះរបស់ខ្លួនថ្វាយព្រះមហាក្សត្រជួយដោះស្រាយវិវាទ[7]។ ជាជាងដាក់ចេញនូវសេចក្តីសម្រេច ព្រះមហាក្សត្រផ្តល់នូវយោបល់ដែលមិនតម្រូវឱ្យភាគីត្រូវតែអនុវត្តទេ ។

**កថាភាគទី២៖ ប្រទេសកម្ពុជាឆ្ពោះទៅកាន់ការដោះស្រាយវិវាទ**

បន្ទាប់ពីកិច្ចព្រមព្រៀងទីក្រុងប៉ារីស ខែតុលា ឆ្នាំ១៩៩១ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតនូវកំណែទម្រង់ប្រព័ន្ធតុលាការដោយបង្កើតនូវស្ថាប័នមានសមត្ថកិច្ចជាច្រើនដូចជា ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋក្នុងឆ្នាំ១៩៩៩ និងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងយុត្តិធម៌ក្នុងឆ្នាំ២០០២[8] គណៈរដ្ឋមន្ត្រីក៏បានធ្វើការអនុម័តទៅលើយុទ្ធសាស្ត្រ កំណែទម្រង់ច្បាប់ និងតុលាការនៅក្នុងឆ្នាំ២០០៣ និងផែនការសកម្មភាពនៅក្នុងឆ្នាំ២០០៥។ គោលបំណង នៃយុទ្ធសាស្ត្រកំណែទម្រង់យុត្តិធម៌ និងតុលាការ គឺជាការបង្កើតនូវស្ថាប័នដែលមានកិត្យានុពល និងស្ថេរភាព ច្បាប់ និងយុត្តធម៌ប្រកាន់ភ្ជាប់នូវគោលការណ៍សិទ្ធិបុគ្គលពីរដ្ឋ និងភាពចែកដាច់ពីគ្នានៃអំណាចនៅក្នុងប្រព័ន្ធប្រជាធិបតេយ្យ ដែលនេះគឺជួយជម្រុញដល់វិស័យឯកជនដើម្បីទទួលបាននូវភាពរីកចម្រើនខាងសេដ្ឋកិច្ច។ ដើម្បីទទួលបាននូវភាពជោគជ័យក្នុងការអនុវត្តនូវគោលបំណងនេះ គោលដៅយុទ្ធសាស្ត្រប្រាំពីរត្រូវបានបង្កើតដែលក្នុងនោះ (ការណែនាំនូវយុទ្ធសាស្ត្រដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការគឺជាគោលដៅទីប្រាំមួយ) ។

[5] ទិដ្ឋភាពទូទៅនៃប្រព័ន្ធច្បាប់ និងតុលាការកម្ពុជា និងការខិតខំប្រឹងប្រែងនាពេលថ្មីៗនេះ ក្នុងកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ ក្នុងសេចក្តីផ្តើមនៃច្បាប់កម្ពុជា,លោក គង់ ផល្លាក (Konrad-adenauer-stiftung,២០១២ ទំព័រ១៣ )។

[6] Luco, Between a tiger and a crocodile: Management of local conflicts, and anthropological approach to traditional and new practices. p.31

[7] ទិដ្ឋភាពទូទៅនៃប្រព័ន្ធច្បាប់ និងតុលាការកម្ពុជា និងការខិតខំប្រឹងប្រែងនាពេលថ្មីៗនេះ ក្នុងកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ ក្នុងសេចក្តីផ្តើមនៃច្បាប់កម្ពុជា,លោក គង់ ផល្លាក (Konrad-adenauer-stiftung,២០១២ ទំព័រ១៣ )។

[8] ព្រះរាជក្រឹតស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ (១៩៩៩) និងព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងតុលាការ (២០០២)។ថ្មីៗនេះក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងយុត្តធម៌ ត្រូវបានដាក់ឲ្យនៅក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌ជំនួសវិញ។

ចំណែកឯផែនការណ៍សកម្មភាពមានគោលបំណង ស៊ើបអង្កេត បង្កើត និងពង្រឹងវិធីផ្សេងៗនៃការដោះស្រាយវិវាទក្រៅតុលាការ និងការដោះស្រាយវិវាទបែបប្រពៃណី[9]។

មានមូលហេតុជាច្រើន ដែលជម្រុញឱ្យមានការកើនឡើងនូវការប្រើប្រាស់ប្រព័ន្ធដោះស្រាយវិវាទក្រៅផ្លូវតុលាការ ដោយក្នុងនោះមានដូចជា បញ្ហាទាក់ទងទៅនឹងស្ថានភាពភូមិសាស្ត្រ សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ប្រជាជន ក្រីក្រ និងក្រុមជនដែលងាយរងគ្រោះ។ ប្រមាណ៨០ភាគរយ នៃប្រជាជនកម្ពុជាសរុប ១៣,៤ លាននាក់ (ឆ្នាំ២០០៨) គឺជាអ្នករស់នៅជនបទ[10] ហើយជម្លោះតែងកើតឡើងចំពោះប្រជាជននៅតាមជនបទភាគច្រើនជា ជម្លោះរវាងបុគ្គល និងបុគ្គល ហើយភាគច្រើនប៉ះពាល់ ទៅដល់ អ្នកក្រីក្រ ស្ត្រី និងជនជាតិភាគតិច។ ជម្លោះ ទាំងនោះភាគច្រើនកើតឡើងក្នុងមូលដ្ឋាន ហើយទាក់ទងនឹងបញ្ហាហឹង្សាលើស្ត្រី ដីធ្លី និងព្រហ្មទណ្ឌ[11]។ ប្រជាជននៅតាមតំបន់ជនបទយល់ឃើញថា ការធ្វើដំណើរទៅតុលាការមានចម្ងាយឆ្ងាយ ចំណាយច្រើន និង មាននីតិវិធីសាំញ៉ាំ។ មូលហេតុទាំងនេះជម្រុញឱ្យប្រជាជនមិនប្រើប្រាស់ប្រព័ន្ធតុលាការនៅក្នុងការដោះស្រាយវិវាទ។

បញ្ហានេះ គឺមកពីការកកស្ទះសំណុំរឿង និងកង្វះខាតធនធានមនុស្សនៅតុលាការ។ យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងយុត្តិធម៌របស់រាជរដ្ឋាភិបាលហាក់បីដូចជាផ្តោតសំខាន់ទៅលើមូលហេតុដែលថា តុលាការមិនគួរដោះស្រាយគ្រប់ជម្លោះដែលកើតឡើងនោះទេ ហើយដំណោះស្រាយក្រៅប្រព័ន្ធតុលាការគួរតែត្រូវបានយកចិត្តទុកដាក់។

## កថាភាគទី៣៖ ការវិវត្តន៍នៃក្រមខ័ណ្ឌច្បាប់ក្នុងការឆ្លើយតបទៅនឹងកំណែទម្រង់ ច្បាប់ និង យុត្តិធម៌សម្រាប់ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ

ច្បាប់ជាច្រើនត្រូវបានអនុម័ត ដើម្បីជំរុញឱ្យមានដំណើរការប្រើប្រាស់ប្រព័ន្ធវិធានការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ច្បាប់ទាំងនេះនឹងត្រូវធ្វើការពិភាក្សាខាងក្រោម៖

ក្នុងឆ្នាំ២០០១ ច្បាប់ស្តីពីរដ្ឋបាលឃុំ-សង្កាត់ បានអនុម័ត ដោយផ្តល់តួនាទីទៅរដ្ឋបាលឃុំសម្រាប់លើកស្ទួយ តួនាទីដោះស្រាយជម្លោះរវាងប្រជាពលរដ្ឋ[12]។ បន្ថែមលើច្បាប់ខាងលើ មាត្រា៤៧ នៃច្បាប់ភូមិបាល

---

[9] YRIGOYEN FAJARDO, Kong, and Phan, Pathways to Justice: Access to Justice with a focus on the poor, women and indigenous peoples, p. 36.

[10] "Cambodia." ចូលមើលលើកចុងក្រោយ ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ http://www.wpro.who.int/countries/khm/en/

[11] YRIGOYEN FAJARDO, Kong, and Phan, Pathways to Justice: Access to Justice with a focus on the poor, women and indigenous peoples, p.105.

[12] អនុក្រឹតស្តីពីវិមជ្ឈការនៃតួនាទី មុខងារ និងអំណាចដល់ក្រុមប្រឹក្សាឃុំ (២០០២) មាត្រា ៦១។

ឆ្នាំ២០០១ បានបង្កើតនូវគណៈកម្មការដោះស្រាយវិវាទដីធ្លី[13] ដោយមានភារកិច្ចចម្បងដោះស្រាយនូវជម្លោះរបស់ប្រជាពលរដ្ឋទាក់ទងនិងដីមិនទាន់ចុះបញ្ជី ដោយមិនចាំបាច់ប្រើប្រាស់ប្រព័ន្ធតុលាការ[14]។ ប្រសិនបើគណៈកម្មការនេះមិនអាចរកនូវដំណោះស្រាយ សម្រាប់ភាគីជម្លោះនេះអាចនឹងត្រូវបញ្ជូនទៅតុលាការដើម្បីដោះស្រាយ។ សម្រាប់វិវាទការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលត្រូវបានកំណត់ដោយច្បាប់ស្តីពីការងារត្រូវបានបង្កើតឡើងដោយប្រកាសលេខ ០៩៩ នៅក្នុងខែមេសា ឆ្នាំ២០០៤។

ដើម្បីក្លាយទៅជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកកម្ពុជាក៏បានយល់ព្រមបង្កើតនូវច្បាប់ថ្មីច្រើនដោយការប្តេជ្ញាពង្រឹងបទដ្ឋាននៃបទបញ្ញត្តិសម្រាប់ពាណិជ្ជកម្ម និងការវិនិយោគ។ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ត្រូវបានអនុម័តនៅក្នុងឆ្នាំ២០០៦ ដោយកំណត់នូវក្របខណ្ឌសម្រាប់ មជ្ឈត្តកម្មឯកជននៅក្នុងការដោះស្រាយជម្លោះពាណិជ្ជកម្មដោយអនុវត្តតាមបទដ្ឋានអន្តរជាតិ។ មុនការអនុម័តនូវច្បាប់ស្តីពីមជ្ឈត្តកម្មពាណិជ្ជកម្ម កម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញាក្រុងញូវយ៉ក ស្តីពីការទទួលស្គាល់ និងអនុវត្តនូវសេចក្តីសម្រេចអាជ្ញាកណ្តាលបរទេស (New York Convention on the Recognition and Enforcement of Foreign Arbitral Awards) នៅក្នុងឆ្នាំ១៩៦០[15]។ ស្ថិតនៅក្រោមអនុសញ្ញានេះ ប្រទេសកម្ពុជាមានកាតព្វកិច្ចអនុវត្តនូវសេចក្តីសម្រេចអាជ្ញាកណ្តាលបរទេស ប៉ុន្តែហាក់មានភាពមិនច្បាស់លាស់ថា តើមានការអនុវត្តនូវសេចក្តីសម្រេចអាជ្ញាកណ្តាលបរទេសហើយឬនៅទេ? នៅក្នុងឆ្នាំ១៩៩៣ ប្រទេសកម្ពុជាបានចុះហត្ថលេខាទៅលើអនុសញ្ញាស្តីពីការដោះស្រាយវិវាទទាក់ទងនឹងការវិនិយោគ (Convention on the Settlement of Investment Disputes; ICSID) ប៉ុន្តែសភាមិនទាន់ផ្តល់សច្ចាប័នទៅលើអនុសញ្ញានេះនៅឡើយទេ។

ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ក៏បានអនុញ្ញាតឱ្យមានការសម្របសម្រួលនៅក្នុងនិងនៅក្រៅតុលាការផងដែរ ទោះបីជាភាគីបានដាក់បណ្តឹងទៅតុលាការហើយក៏ដោយ។ មាត្រា៩៧ បានចែងថា តុលាការអាចសាកល្បងធ្វើការផ្សះផ្សាបាន ទោះបីជាបណ្តឹងនោះស្ថិតនៅក្នុងដំណាក់កាលណាក៏ដោយ[16]។ មាត្រា២២០ បានកំណត់ថា ការផ្សះផ្សាអាចធ្វើនៅក្រៅតុលាការក៏បាន[17]។ បរិបទផ្នែកច្បាប់ទាំងនេះ មានតួនាទីយ៉ាងសំខាន់នៅក្នុងការទទួលស្គាលពីសារៈសំខាន់នៃការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលារនៅស្ទើរគ្រប់វិស័យ។

---

[13] ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា៤៧ ។

[14] ប្រកាសរបស់អន្តរក្រសួង លេខៈ ០២ BRKN, ឆ្នាំ២០០៣ ស្តីពីការកំណត់កាតព្វកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីទាក់ទងនឹងវិវាទដីធ្លី។

[15] Kong, "Overview of the Cambodian Legal and Judicial System and Recent Efforts at Legal and Judicial Reform" p. 14

[16] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ មាត្រា៩៧ ។

[17] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ មាត្រា២២០ ។

## ផ្នែកទី៣៖ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ផ្តល់លទ្ធភាពមួយចំនួនក្នុងជម្រើសដោះស្រាយបញ្ហា។ សព្វថ្ងៃនេះ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការបានក្លាយទៅជាផ្នែកដ៏សំខាន់នៃទិដ្ឋភាពច្បាប់នៅប្រទេសកម្ពុជា និងនៅប្រទេសដទៃទៀត ដោយសារតែបញ្ហាដែលគេមើលឃើញនៅក្នុងប្រព័ន្ធតុលាការតាមទំនៀមទម្លាប់។ បញ្ហាទាំងនេះរួមមាន៖

- ជាញឹកញាប់ រឿងក្តីត្រូវការពេលវេលាជាច្រើនឆ្នាំក្នុងការជំនុំជម្រះ ។
- ភាគីវិវាទច្រើនស្ថិតនៅក្នុងស្ថានភាពលំបាក នៅពេលដែលវិវាទរបស់ពួកគេត្រូវបាន តម្កល់ មិនចាត់ការ។
- ប្រសិនបើភាគីជួលមេធាវីឱ្យធ្វើជាតំណាងពួកគេភាគច្រើនពួកគេត្រូវបង់ប្រាក់កម្រៃ និងការចំណាយខ្ពស់ដើម្បី បន្តវិវាទរបស់ខ្លួនតទៅទៀត ។
- ជាញឹកញាប់ភាគីនៃបណ្តឹងមានអារម្មណ៍ថា ពួកគេមិនមានលទ្ធភាពគ្រប់គ្រងលើដំណើរការនោះ។
- ជួនកាលភាគីមានការព្រួយបារម្ភអំពីអំពើពុករលួយនៅក្នុងប្រព័ន្ធតុលាការ ។
- ចៅក្រមក៏មានកត្តារាំងស្ទះនៅក្នុងលទ្ធភាពធ្វើសេចក្តីសម្រេចរបស់ខ្លួន ជាទូទៅ ពួកគេគ្រាន់តែអាចបង្គាប់ឱ្យ បង់សំណងខូចខាតដល់ភាគីម្ខាង ឬភាគីម្ខាងទៀតប៉ុណ្ណោះ
- ជាញឹកញាប់ ការវិនិច្ឆ័យនោះតែងបណ្តាលឱ្យមានការខាតបង់ទាំងស្រុងចំពោះភាគីម្ខាង ហើយអាចជះឥទ្ធិពលជា អវិជ្ជមានដល់ទំនាក់ទំនងរវាងភាគីវិវាទ ។

ដោយសារបញ្ហាទាំងនេះ វាមិនមែនជាការដ៏គួរឲ្យភ្ញាក់ផ្អើលទេ ដែលភ័ស្តុតាងជាបទពិសោធន៍នៅក្នុងប្រទេសកម្ពុជា បង្ហាញឱ្យឃើញថា កិច្ចសន្យាអន្តរជាតិភាគច្រើនតែងកំណត់យកវេទិកាដោះស្រាយវិវាទនៅក្រៅប្រទេស ដោយសារការមើលឃើញពីភាពមិនគួរឱ្យជឿជាក់បាននៃតុលាការក្នុងស្រុក។ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិរបស់ធនាគារពិភពលោកបានរាយការណ៍ថា៖

ការប្តឹងទៅតុលាការត្រូវបានសហគ្រិនទាំងឡាយចាត់ទុកថាកម្រនឹងអាចសម្រេចបាន ប៉ុន្តែជម្រើស នៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធផ្សេងទៀតក៏មានភាពខ្វះចន្លោះចម្បង១ចំនួនដែរ ដោយហេតុនេះទើបអាជីវកម្មជាច្រើនជ្រើសយកការកាត់បន្ថយការខាតបង់របស់ពួកគេ ហើយគេចចេញឆ្ងាយពីវិវាទជាជាងស្វះស្វែងរកសិទ្ធិ និងអំណាចតាមផ្លូវច្បាប់របស់ខ្លួន[18]។

[18] ព្រឹត្តបត្របញ្ហាអាជីវកម្ម កម្មវិធីអភិវឌ្ឍវិស័យឯកជនតំបន់ទន្លេមេគង្គ ទំព័រទី១(សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ខែសីហា ឆ្នាំ២០០៧)។

ដោយសារមូលហេតុនេះ ដើម្បីជួយទាក់ទាញវិនិយោគបរទេសសំខាន់ៗ ប្រទេសកម្ពុជាត្រូវបន្តអភិវឌ្ឍបញ្ញើដ៏រឹងមានជម្រើសក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ[19]។

កាលពីប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះ ប្រជាជនជាច្រើនរំពឹងលើដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដើម្បីស្វែង រកចម្លើយក្នុងការដោះស្រាយវិវាទដែលជួយសម្រាល ឬជៀសវាងនូវកំហិតទាំងឡាយដូចដែលបានមើលឃើញនៅក្នុង ប្រព័ន្ធតុលាការដែលមានពីមុនមក។

**ឧទាហរណ៍៖** មជ្ឈត្តការកាន់តែក្លាយជាវិធីសាស្ត្រដ៏ឆាប់រហ័ស និងមានតម្លៃថោកក្នុងការដោះស្រាយវិវាទផ្សេងៗ បើប្រៀបធៀបជាមួយតុលាការ មជ្ឈត្តការគឺជាចម្លើយក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមុនគេបង្អស់ដែលទទួលបានការគាំទ្រយ៉ាងទូលំទូលាយ ហើយនៅតែជាយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជាផ្លូវការ ដែលមានប្រជាប្រិយជាងគេបំផុតនៅក្នុងប្រព័ន្ធច្បាប់ដែលអភិវឌ្ឍភាគច្រើន ។

យ៉ាងណាមិញ នាពេលថ្មីៗនេះសន្ធានកម្មក៏កាន់តែមានការទទួលស្គាល់ផងដែរថាជាយន្តការដោះស្រាយវិវាទមួយ ។ សន្ធានកម្មផ្តល់ឱ្យភាគីនៃវិវាទនូវដំណោះស្រាយដ៏ឆាប់រហ័ស និងមានតម្លៃកាន់តែថោកព្រមជាមួយនិងឱកាសរកដំណោះស្រាយដែលងាយបត់បែន និងដែលអាចរក្សាបាននូវទំនាក់ទំនងជាបន្តរវាងភាគីវិវាទ ។ សន្ធានកម្ម ក៏មានលក្ខណៈស្ម័គ្រចិត្តដែរ ដោយភាគីអាចដោះស្រាយវិវាទនៅពេលណាដែលពួកគេឯកភាពលើការស្រុះស្រួលតែប៉ុណ្ណោះ ។

ជាងនេះទៅទៀត សន្ធានកម្ម និងទម្រង់ផ្សេងទៀតនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការត្រូវបានគេប្រើប្រាស់ជាឧបករណ៍សម្រាប់ស្ថាបនាលទ្ធភាពទទួលបានយុត្តិធម៌។ នៅក្នុងប្រទេសជាច្រើនរួមទាំងប្រទេសកម្ពុជាផងដែរ ប្រព័ន្ធតុលាការផ្លូវការមានតម្លៃថ្លៃជ្រុលហួស សំរាប់ប្រជាជនក្រីក្របំផុតនៅក្នុងសង្គម ។ ពួកគេមិនអាចរាប់រងប្រាក់ប្រដាប់ក្តី និងថ្លៃឈ្នួលមេធាវី ដែលមានភាពចាំបាច់ដល់ពួកគេក្នុងការទទួលបាននូវការសម្រេចសេចក្តីពីតុលាការចំពោះ វិវាទរបស់ពួកគេឡើយ ។ ដោយសារតែទម្រង់ភាគច្រើននៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការអនុញ្ញាតឱ្យភាគីវិវាទដោះស្រាយវិវាទរបស់ពួកគេនៅក្នុងលក្ខណៈកាន់តែក្រៅផ្លូវការ និងមានតម្លៃថោក នោះទម្រង់ទាំងនេះអាចក្លាយជាមធ្យោបាយយ៉ាងសំខាន់ក្នុងការជួយប្រជាជនក្រីក្រដើម្បីដោះស្រាយវិវាទរបស់ពួកគេ ។ ប៉ុន្តែវិធីសាស្ត្រនេះមិនមែនជាជម្រើសចុងក្រោយបង្អស់របស់គូភាគីវិវាទឡើយ ព្រោះគូភាគីវិវាទអាចធ្វើការជ្រើសរើសនូវការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដោយផ្ទាល់ ឬបន្ទាប់ពីការដោះស្រាយក្រៅប្រព័ន្ធតុលាការ មិនទទួលបានជោគជ័យ។

[19] អាចនិយាយបានថា ក្របខ័ណ្ឌគតិយុត្តកំពុងតែប្រដេញជាមួយនឹងកំណើនសេដ្ឋកិច្ចដែលសត្វខ្លារបស់ប្រទេសកម្ពុជា។ធនាគារពិភពលោកបានរាយការណ៍ថា ផលិតផលសរុបក្នុងស្រុករបស់ប្រទេសកម្ពុជាបានកើនដល់ ១៣,៥% ក្នុងឆ្នាំ២០០៥ ១០,៨% ក្នុងឆ្នាំ២០០៦ និង១០,៣ ក្នុងឆ្នាំ២០០៧ មាននៅ http://devdata.worldbank.org/external/CPProfile.asp? PTYPE=CP&CCODE=KHM

# ជំពូកទី២

# ប្រភេទវិវាទឯកជននៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

# ជំពូកទី២

# ប្រភេទវិវាទឯកជននៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

## ផ្នែកទី១៖ វិវាទរដ្ឋប្បវេណី

### កថាភាគទី១៖ និយមន័យនៃវិវាទរដ្ឋប្បវេណី

តាមន័យនិរុត្តិសាស្ត្រ វិវាទមានន័យថា ជាដំណើរទាស់ទែងគ្នា ឬជាដំណើរឈ្លោះប្រកែកគ្នា។ ចំណែកឯ រដ្ឋប្បវេណី បានមកពីការរួមបញ្ចូលគ្នារវាងពាក្យ រដ្ឋ និងបវេណី។ រដ្ឋ សំដៅទៅលើដែនប្រទេស អ្នកនៅក្នុងដែន រាស្ត្រ ឬប្រជាជន រីឯបវេណី គឺជាទំនៀម ពូជពង្ស តំណវង្សត្រកូល។ ដូចនេះ វិវាទរដ្ឋប្បវេណី[20] មានន័យថាជាដំណើរនៃការ ទាស់ទែងគ្នា ឬឈ្លោះប្រកែកគ្នា ទាក់ទងទៅនឹងជីវភាពរស់នៅ ទំនៀមទម្លាប់ ប្រពៃណីរបស់ប្រជាជននៅក្នុងដែនដី នៃប្រទេសណាមួយ ឬសង្គមមួយ។ តាមន័យនីតិសាស្ត្រ វិវាទរដ្ឋប្បវេណី "សំដៅទៅលើវិវាទដែលកើតចេញអំពី ទំនាក់ទំនងគតិយុត្តរវាងបុគ្គលឯកជនដែលមានភាពស្មើគ្នានៅក្នុងសង្គម ពាក់ព័ន្ធនឹងបញ្ហាមួយចំនួនដូចជា កម្មសិទ្ធិ និងកិច្ចសន្យា (ទំនាក់ទំនងទ្រព្យសម្បត្តិ អាពាហ៍ពិពាហ៍ និងសន្តតិកម្ម) ។

ដូចបានដឹងរួចមកហើយថា ច្បាប់ទាំងឡាយអាចត្រូវបានបែងចែកជាពីរប្រភេទធំៗ គឺនីតិសាធារណៈ និង នីតិឯកជន ដែលទស្សនៈភាគច្រើនយល់ឃើញថា ច្បាប់ទាំងពីរនេះត្រូវបានបែងចែកទៅតាមលក្ខណៈនៃទំនាក់ទំនងគតិយុត្តិ។ មានន័យថា នីតិសាធារណៈគឺជាច្បាប់ដែលបញ្ញត្តិអំពីទំនាក់ទំនងរវាងភាគីដែលគ្មានភាពស្មើគ្នា រដ្ឋ និងពលរដ្ឋ។ រីឯនីតិឯកជន គឺជាច្បាប់ដែលបញ្ញត្តិអំពីទំនាក់ទំនងរវាងភាគីដែលគ្មានភាពស្មើគ្នា (ពលរដ្ឋ និងពលរដ្ឋ) រីឯ នីតិឯកជន គឺជាច្បាប់ដែលបញ្ញត្តិអំពីទំនាក់ទំនងគតិយុត្តរវាងភាគីដែលមានភាពស្មើគ្នា(ពលរដ្ឋ និង ពលរដ្ឋជាលក្ខណៈបុគ្គលឯកជន) ដូចជា ក្រមរដ្ឋប្បវេណី ច្បាប់ពាណិជ្ជកម្ម ច្បាប់ស្តីពីសហគ្រាស ច្បាប់ស្តីពីរូបិយាណត្តិ និងប័ណ្ណសងតាមការបញ្ជា ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ច្បាប់កិច្ចសន្យា និងច្បាប់ពិសេសមួយចំនួនទៀតដូចជា ច្បាប់ស្តីពីការងារ ច្បាប់ភូមិបាល។ ដោយមូលហេតុថាក្រមរដ្ឋប្បវេណីមានលក្ខណៈផ្សារភ្ជាប់ទៅនឹងជីវិតឯកជនរបស់ពលរដ្ឋ រវាងពលរដ្ឋ ជាពិសេសពាក់ព័ន្ធជាមួយទំនាក់ទំនងទ្រព្យសម្បត្តិ និងទំនាក់ទំនង ញាតិ ដូច្នេះហើយទើបគេហៅក្រមរដ្ឋប្បវេណីជានីតិឯកជន។ ជាក់ស្តែងមាត្រា១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានប្រើពាក្យរដ្ឋប្បវេណីជំនួសនីតិឯកជន មានន័យថាក្រមរដ្ឋប្បវេណី គឺជាច្បាប់ទូទៅនៃនីតិឯកជន។

[20] យោងតាមខ្លឹមសារក្នុងមាត្រា១នៃក្រមរដ្ឋប្បវេណី លេខនស.រកម.១២០៧/០៣១. ០៨ ធ្នូ ២០០៧ និងករិយាល័យកម្មវិធីអភិវឌ្ឍន៍វិស័យច្បាប់ និងយុត្តធម៌, ក្រសួងយុត្តិធម៌ សេចក្តីណែនាំចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភ្នំពេញ ឆ្នាំ២០១០

**កថាភាគទី២៖ មូលហេតុនៃវិវាទរដ្ឋប្បវេណី**

វិវាទរដ្ឋប្បវេណី សំដៅទៅលើវិវាទទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងទំនាក់ទំនងទ្រព្យសម្បត្តិ (កម្មសិទ្ធ និងកិច្ចសន្យា)និងទំនាក់ទំនងញាតិ (អាពាហ៍ពិពាហ៍ និងសន្តតិកម្ម) ព្រមទាំងវិវាទដែលបានកំណត់នៅក្នុងច្បាប់ពិសេសមួយចំនួនទៀត ដូចជា វិវាទពាណិជ្ជកម្ម វិវាទការងារ វិវាទដីធ្លី[21] ជាដើម។

**១.វិវាទពាក់ព័ន្ធទៅនឹងទំនាក់ទំនងទ្រព្យសម្បត្តិ**

នៅក្នុងសង្គមមានបញ្ហាជាច្រើនពាក់ព័ន្ធនឹងបញ្ហាដីធ្លី [22]និងការមិនអនុវត្តកាតព្វកិច្ច[23]មានដូចជា៖

- បញ្ហានៃការប្រើប្រាស់ដីដែលនៅជាប់គ្នា (ការធ្វើរបង ឬធ្វើសំណង់ ឬការជួសជុស)
- បញ្ហាដែលកើតចេញពីដីបិទជិត ចេញ-ចូល (ដីដែលព័ទ្ធជុំវិញដោយដីរបស់អ្នកដទៃហើយគ្មានច្រកចេញទៅផ្លូវសាធារណៈ)
- បញ្ហារបស់អ្នកកាន់កាប់ដីក្នុងការទាមទារសងសោហ៊ុយ
- ករណីយកិច្ចមិនគោរពកាតព្វកិច្ចសងរបស់អ្នកខ្ចី
- ករណីយកិច្ចមិនគោរពកាតព្វកិច្ចរបស់អ្នកជួល
- ករណីយកិច្ចមិនគោរពកាតព្វកិច្ចរបស់អ្នកប្រវាស់ជាដើម។

**២.វិវាទពាក់ព័ន្ធទៅនឹងទំនាក់ទំនងញាតិ**

វិវាទស្តីពីបញ្ហាគ្រួសារ ច្រើនតែជាវិវាទដែលមានពាក់ព័ន្ធរួមទាំងកូន ឬឪពុកម្តាយ ហើយដែលមិនអាចចាត់ការទៅតាមគោលការណ៍នៃកិច្ចសន្យាបាន។ ហេតុនេះហើយពីឆ្នាំ២០០៣មក ជប៉ុនបានបង្កើតតុលាការគ្រួសារសម្រាប់ចាត់ការផ្តាច់មុខក្នុងការជំនុំជម្រះលើកទី១ នូវរឿងក្តីលែងលះ។ ស្តីពីការជំនុំជម្រះនេះដើម្បីផ្តល់ឱកាសព្រមព្រៀងតាមរយៈការពិគ្រោះរវាងភាគី មុននឹងធ្វើការជំនុំជម្រះ តុលាការច្រើនតែយកគោលការណ៍ធ្វើសន្ធានកម្មមុនជំនុំជម្រះ ហើយពាក់ព័ន្ធនឹងរឿងលែងលះក៏ដូចគ្នាដែរ។

ស្តីពីបញ្ហាគតិយុត្តដែលកើតមានឡើងពាក់ព័ន្ធនឹងការលែងលះ មានដូចជា៖

- ពាក់ព័ន្ធនឹងប្តីប្រពន្ធ មានបញ្ហាបែងចែកទ្រព្យសម្បត្តិ
- បញ្ហាសំណងជម្ងឺចិត្ត
- បញ្ហាចំណាយលើអាពាហ៍ពិពាហ៍ក្នុងអំឡុងពេលរស់នៅបែកគ្នា
- បញ្ហាពាក់ព័ន្ធនឹងកូន

---

[21] ជួប បិតបេរឫទ្ធិ ដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ទំព័រ១។

[22] ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា១ ។

[23] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៣១៣ ។

- បញ្ហាអាហារកិច្ច
- បញ្ហាជួបប្រាស្រ័យទាក់ទង
- បញ្ហាប្រគល់កូនជាដើម។

**កថាភាគទី៣៖ ដំណោះស្រាយវិវាទរដ្ឋប្បវេណី**

តាមក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រឹមតែបានកំណត់ពីគោលបំណងនៃបណ្តឹងរដ្ឋប្បវេណី ក្នុងការការពារសិទ្ធិស្របច្បាប់របស់បុគ្គលឯកជន តាមរយៈការដោះស្រាយវិវាទដោយបង្ខំ[24](ដោយប្រើយន្តការតាមផ្លូវតុលាការរដ្ឋប្បវេណី) តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានអនុញ្ញាតយ៉ាងដាក់លាក់ឱ្យមានការប្រើប្រាស់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ទោះបីជាបន្ទាប់ពីភាគីដើមចោទបានដាក់ពាក្យបណ្តឹងទៅតុលាការរួចហើយក៏ដោយ។ [25] មានន័យថា ក្រមនីតិវិធីរដ្ឋប្បវេណី លើកទឹកចិត្តឱ្យធ្វើការចរចា និងផ្សះផ្សា។ ម្យ៉ាងវិញទៀតនៅក្នុងសេចក្តីពន្យល់ អំពីក្រមនីតិវិធីរដ្ឋប្បវេណី (ភាគ១៖ នីតិវិធីបណ្តឹង) បានពន្យល់យ៉ាងច្បាស់ថា ក្នុងវិវាទរដ្ឋប្បវេណី គូភាគីវិវាទអាចប្រើប្រាស់វិធានការដោះស្រាយវិវាទដោយខ្លួនឯង[26] ដែលរួមមាន ការសះជា (ការចរចា) សន្ធានកម្ម ផ្សះផ្សា និងមជ្ឈត្តកម្ម ឬ វិធាននៃការដោះស្រាយវិវាទដោយបង្ខំ[27] (តាមប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី)។

តាមពិតទៅកម្ពុជានៅមានច្បាប់ពិសេសមួយចំនួន ដែលផ្តល់លទ្ធភាពតាមផ្លូវច្បាប់ និងលើកទឹកចិត្តឱ្យមានការប្រើប្រាស់យន្តការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមុននឹងប្តឹងទៅតុលាការ តាមមធ្យោបាយនៃការចរចា សន្ធានកម្ម និង មជ្ឈត្តកម្ម ដូចជាច្បាប់ស្តីពីការងារ (មាត្រា៣០០ដល់៣០៧) ច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ (មាត្រា៤២) ព្រះរាជក្រឹត្យស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី (មាត្រា៣ អនុក្រឹត្យលេខ៤៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈកម្មការសុរិយោដីប្រការ៧ដល់១១)។

ដូចនេះផ្អែកលើបទដ្ឋានគតិយុត្តខាងលើនេះ ជាពិសេសក្រមនីតិវិធីរដ្ឋប្បវេណីអាចកំណត់បានយ៉ាងច្បាស់លាស់ថា នៅពេលមានវិវាទរដ្ឋប្បវេណី ភាគីវិវាទអាចដោះស្រាយវិវាទតាមវិធាន២យ៉ាងដូចខាងក្រោម៖

(១) វិធាននៃការដោះស្រាយវិវាទដោយខ្លួនឯង ឬយន្តការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដែលជានីតិវិធីដោះស្រាយវិវាទដោយស្ម័គ្រចិត្ត និងដោយឆន្ទានុសិទ្ធិរបស់ភាគី។ វិធាននេះ មាន៣ទៀត គឺការចរចា (ការសះជា) សន្ធានកម្ម និងមជ្ឈត្តកម្ម។

[24] មាត្រា ក្រមនីតិវិធីរដ្ឋប្បវេណី លេខនស.រកម.០៧០៦/០២១, ១០ កក្កដា ២០០៦

[25] មាត្រា៩៧ ក្រមនីតិវិធីរដ្ឋប្បវេណី លេខនស.រកម.០៧០៦/០២១, ១០ កក្កដា ២០០៦ តុលាការអាចធ្វើការផ្សះផ្សាបានទោះបីជាបណ្តឹងស្ថិតនៅដំណាក់កាលណាក៏ដោយ។

[26] វិធានការដោះស្រាយវិវាទក្រៅដោយខ្លួនឯង ជាវិធីដោះស្រាយជម្លោះដោយស្ម័គ្រចិត្ត និងដោយឆន្ទានុសិទ្ធិរបស់ភាគី ដែលត្រូវបានគេហៅថា ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

[27] ការដោះស្រាយវិវាទដោយបង្ខំ គឺជាការដោះស្រាយវិវាទតាមផ្លូវតុលាការ។

(២) វិធាននៃការដោះស្រាយដោយបង្ខំ ឬយន្តការនៃការដោះស្រាយវិវាទតាមផ្លូវតុលាការរដ្ឋប្បវេណី ដែល ជាវិធីដោះស្រាយដោយអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណី។

## ផ្នែកទី២៖ វិវាទការងារ

ជាទូទៅ នៅគ្រប់វិស័យការងារទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាមិនថាវិស័យឯកជន ឬក្របខណ្ឌក្នុងមន្ត្រីរាជការស៊ីវិលនោះទេ សុទ្ធតែមានលក្ខខណ្ឌនៃកាតព្វកិច្ចជួយគ្នាក៏ដូចជាបំពេញឱ្យគ្នា ឬហៅថាការដោះដូរគ្នាទៅវិញទៅមក ដោយម្នាក់ៗសុទ្ធតែទទួលបាននូវផលប្រយោជន៍រៀងៗខ្លួន ដោយក្នុងនោះគឺគេបានយកច្បាប់ការងារមកអនុវត្តក្នុងការបំពេញដែលគេហៅថា "កិច្ចសន្យាការងារ" គេបង្កើតកិច្ចសន្យានេះឡើង គឺដើម្បីការពារ ឬ ជៀសវាងមានវិវាទ ឬការមិនពេញចិត្តណាមួយដោយភាគីជានិយោជក និងភាគីជានិយោជិត។

តែក្នុងកិច្ចសន្យា នោះអាចនឹងបង្កើតជាវិវាទណាមួយ នៅពេលភាគីទាំងពីរមិនបានបំពេញកាតព្វកិច្ច ឬបំពាននៃកិច្ចសន្យាក្រោយពេលចុះកិច្ចសន្យាព្រមព្រៀងគ្នារួច ដោយហេតុដូចនេះទើបក្នុងច្បាប់ការងារឆ្នាំ១៩៩៧ ក៏ចែងពីការដោះស្រាយវិវាទការងារផងដែរ នោះគឺ "វិវាទការងារ" ។

វិវាទការងារ គឺជាវិវាទដែលទាក់ទងទៅនឹងសិទ្ធិស្របច្បាប់ និងជាវិវាទដែលទាក់ទងទៅនឹងផលប្រយោជន៍នាពេលអនាគតរវាងនិយោជក ឬនាយកសហគ្រាស ជាមួយនឹងកម្មករនិយោជិត ឬជនដែលស្ថិតនៅក្រោមច្បាប់ ស្តីពីការងារ ឆ្នាំ១៩៩៧ ។ យោងទៅតាមច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ វិវាទការងារត្រូវបានបែងចែកចេញជា ០២ (ពីរ) ករណីគឺ៖ វិវាទការងារបុគ្គល និងវិវាទការងាររួម[28]។

### កថាភាគទី១៖ ប្រភេទនៃវិវាទការងារ

#### ១.វិវាទការងារបុគ្គល

វិវាទការងារបុគ្គល គឺជាវិវាទដែលកើតឡើងរវាងនិយោជក និងកម្មករនិយោជិតម្នាក់ ឬច្រើននាក់ ឬអ្នករៀនធ្វើការម្នាក់ ឬច្រើននាក់តាមរឿងរៀងៗខ្លួន ហើយទាក់ទងនិងការបកស្រាយ ឬការអនុវត្តបទបញ្ញត្តិនៃកិច្ចសន្យាការងារ ឬកិច្ចសន្យាហ្វឹកហ្វឺនកម្មករនិយោជិត ឬបទបញ្ញត្តិការងារនៃអនុសញ្ញារួមព្រមទាំងច្បាប់បញ្ញត្តិជាធរមាន[29]។ ឬក៏អាចនិយាយអត្ថន័យដោយសង្ខេបបានថា វិវាទការងារបុគ្គល គឺជាវិវាទពាក់ព័ន្ធទៅនឹងនិយោជក និងកម្មករនិយោជិតម្នាក់ ឬច្រើននាក់ដាច់ដោយឡែកពីគ្នា[30]។

---

[28] គង់ ឆាយឡេង, The HR Daily តើអ្វីទៅជាវិវាទការងារ? ហើយត្រូវធ្វើដូចម្តេច បើបុគ្គលិកប្តឹងក្រុមហ៊ុនរបស់អ្នក? https://www.thehrdaily.com/management-and-leadership/what-is-a-labor-dispute-and-what-if-employees-sue-your-company/?fbclid=IwAR0LYAinvkcGNsdwOlXm2TMK-1LXSNgPfgm5nlF086nbyjbOlCquQXjbsbI (ចុចមើលចុងក្រោយ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣)។

[29] មាត្រា៣០០ ច្បាប់ការងារ លេខជស.រកម.០៣៩៧/០១, ៣១ មីនា ១៩៩៧។

[30] ទំព័រ៥៩ ILO, សៀវភៅណែនាំអំពីច្បាប់ស្តីពីការងារនៃប្រទេសកម្ពុជាសម្រាប់វិស័យកាត់ដេរ ឆ្នាំ២០១៣។

**២.វិវាទការងាររួម**

វិវាទការងាររួម គឺជាវិវាទដែលកើតឡើងរវាងនិយោជកម្នាក់ ឬច្រើននាក់ នឹងបុគ្គលិករបស់ខ្លួនមួយចំនួនអំពីរឿងល័ក្ខខ័ណ្ឌក្នុងការងារ ការប្រើប្រាស់សិទ្ធិដែលប្រគល់ឱ្យអង្គការវិជ្ជាជីវៈការត្រូវទទួលស្គាល់អង្គការវិជ្ជាជីវៈក្នុងសហគ្រាស បញ្ហានៃការទាក់ទងរវាងនិយោជក និងកម្មករនិយោជិតហើយការវិវាទនេះអាចបណ្តាលឱ្យសហគ្រាសប្រព្រឹត្តទៅពុំបានស្រួល ឬធ្វើឱ្យខូចសន្តិភាពសង្គម[31]។

ឬក៏យើងអាចនិយាយអត្ថន័យដោយសង្ខេបបានថា វិវាទការងាររួមពាក់ព័ន្ធទៅនឹងកម្មករនិយោជិតមួយក្រុម និងនិយោជនម្នាក់ ឬច្រើននាក់។ ប្រសិនបើសហជីពមួយពាក់ព័ន្ធនឹងវិវាទមួយ ពេលនោះជាទូទៅគេត្រូវចាត់ទុកថាជាវិវាទការងាររួម។

វិវាទការងាររួមក៏អាចពាក់ព័ន្ធទៅនឹងកម្មករនិយោជិតដែលគ្មានសហជីពផងដែរ ប្រសិនបើគេធ្វើឡើងជាក្រុម[32]។

**កថាភាគទី២៖ មូលហេតុនៃវិវាទការងារ**

មានមូលហេតុច្រើនណាស់ ដែលបុគ្គលិករបស់អ្នកដាក់ពាក្យបណ្តឹងប្តឹងក្រុមហ៊ុនរបស់អ្នកក្នុងនោះរួមមានដូចជា៖

- ការបញ្ឈប់បុគ្គលិកខុសនីតិវិធីច្បាប់
- ផ្តល់ប្រាក់ខែមិនត្រឹមត្រូវ
- គ្រោះថ្នាក់ ឬរងរបួសដោយសារតែភាពធ្វេសប្រហែសរបស់ក្រុមហ៊ុន
- ការរើសអើងប្រកាន់ពណ៌សម្បុរ ពូជសាសន៍ ភេទ អាយុ...
- ការរំលោភបំពានផ្លូវភេទ ឬលក្ខខណ្ឌការងារមិនអាចអនុវត្តបានជាដើម
- ការបណ្តេញកម្មករនិយោជិត ពីការងារដោយមិនបានជូនដំណឹងជាមុន
- ការបញ្ឈប់កម្មករនិយោជិត ពីការងារដោយមិនគោរពនិងអនុវត្តតាមច្បាប់ស្តីពីការងារ
- ការមិនអនុវត្តតាមបទបញ្ជាការងារ ប្រយោជន៍មិនមែនរូបិយវត្ថុផ្សេងទៀត
- និងបទបញ្ញត្តិដែលទាក់ទងដល់បរិក្ខារប្រើប្រាស់និងផល
- ការបន្ថែមសិទ្ធិដល់កម្មករនិយោជិត ការអនុវត្តការងារមិនត្រឹមត្រូវ
- ការបញ្ចប់មុខងារ ការព្យួរការងារ ការព្រមាន និងការដាក់វិន័យដល់កម្មករនិយោជិត
- ការយឺតយ៉ាវក្នុងការបើកប្រាក់ខែ

[31] មាត្រា៣០២ ច្បាប់ការងារ លេខជស.រកម.០៣៩៧/០១, ៣១ មីនា ១៩៩៧។

[32] ILO, សៀវភៅណែនាំអំពីច្បាប់ស្តីពីការងារនៃប្រទេសកម្ពុជាសម្រាប់វិស័យកាត់ដេរ ឆ្នាំ២០១៣ ទំព័រ៥៩។

- ការបើកប្រាក់ខែឱ្យកម្មករនិយោជិតតិចជាងចំនួនប្រាក់ខែអប្បបរមាដែលបានកំណត់ដោយក្រសួងទទួលបន្ទុកវិស័យការងារ
- ការបង្ខំឱ្យធ្វើការលើសម៉ោង
- ការមើលងាយជេរប្រមាថកម្មករនិយោជិត
- ការកាត់ប្រាក់ឈ្នួលស្រេចតែចិត្ត[33]។

**កថាភាគទី៣៖ ដំណោះស្រាយវិវាទការងារ**

វិវាទអាចកើតឡើងនៅកន្លែងធ្វើការទោះជាការចាត់ចែងល្អយ៉ាងណាក៏ដោយ។ ដោយហេតុនេះហើយនិយោជកនិងកម្មករនិយោជិតគួរប្រមើលមើលពីវិវាទទាំងឡាយ ហើយបង្កើតឱ្យមានយុទ្ធសាស្ត្រនៅក្នុងការដោះស្រាយវិវាទនៅពេលដែលវាកើតឡើង។

លើកលែងតែនិយោជកនិងកម្មករនិយោជិតព្រមព្រៀងគ្នាលើប្រព័ន្ធផ្សេងមួយទៀតនាំឱ្យការដោះស្រាយវិវាទពួកគេត្រូវតែ អនុវត្តន៍តាមនីតិវិធីនៃការដោះស្រាយវិវាទដូចមានចែងក្នុងជំពូកទី១២ នៃច្បាប់ស្តីពីការងារ។

យោងតាមច្បាប់ស្តីពីការងារ និយោជក និងកម្មករនិយោជិត អាចដោះស្រាយវិវាទរបស់ពួកគេតាមវិធីមួយចំនួន។

នីតិវិធីទាំងនោះរួមមាន៖

- ការចរចា
- ការផ្សះផ្សា
- ការដោះស្រាយដោយអាជ្ញាកណ្តាល
- កូដកម្ម/ឡុកអាវ
- ប្តឹងទៅតុលាការ។

ដំណាក់កាលទាំងឡាយដែលកម្មករនិយោជិតនិងនិយោជកត្រូវអនុវត្តដើម្បីដោះស្រាយវិវាទគឺអាស្រ័យទៅលើថាតើវាជាវិវាទបុគ្គល ឬជាវិវាទការងាររួម។

[33] ចំណេះដឹងទូទៅ, KH Research.com សំណួរ ចម្លើយ ទាក់ទងពីចំណេះដឹងពីស្ថាប័នសង្គម និងសិទ្ធិមនុស្សក្នុងការងារ(២),(ថ្ងៃទី៨ ខែមករា ឆ្នាំ២០១៩)។
https://www.khsearch.com/qna/13617?fbclid=IwAR0FlXjDRWoo75e7weAFlxFk97TpVik6R7-9C_GqAs71H07VAsg7iqlBM9k (ចុចមើលចុងក្រោយថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣) ។

### ១.នីតិវិធីដោះស្រាយវិវាទបុគ្គលនៅក្រៅប្រព័ន្ធតុលាការ

ការដោះស្រាយវិវាទបុគ្គល បើតាមច្បាប់ត្រូវឆ្លងកាត់តាមយន្តការ៣ដំណាក់កាលគឺ **ក**.ដោះស្រាយនៅសហគ្រាសឬគ្រឹះស្ថានរបស់ខ្លួនផ្ទាល់(ការចរចា) **ខ**.ដោះស្រាយវិវាទការងារនៅថ្នាក់ក្រសួងតាមការប្តឹងទៅអធិការការងារ ឬក៏អាចហៅម្យ៉ាងបានទៀតថាមន្ត្រីផ្សះផ្សាដើម្បីការដោះស្រាយដោយផ្អែកលើច្បាប់ (ការផ្សះផ្សា) **គ**.ដោះស្រាយវិវាទការងារដោយតុលាការ[34]។

#### ក. ការដោះស្រាយវិវាទការងារបុគ្គលនៅសហគ្រាសឬគ្រឹះស្ថានរបស់ខ្លួនផ្ទាល់

មុននឹងប្តឹងទៅមន្ត្រីផ្សះផ្សា គ្រប់វិវាទការងារទាំងឡាយត្រូវធ្វើការដោះស្រាយឱ្យអស់លទ្ធភាពជាមុនសិននៅថ្នាក់សហគ្រាសឬគ្រឹះស្ថាន[35]។ នៅរាល់ពេលបញ្ចប់ការដោះស្រាយវិវាទការងារ ភាគីវិវាទត្រូវធ្វើកំណត់ហេតុរួមអំពីលទ្ធផលនៃការដោះស្រាយ ដោយមានបញ្ជាក់ច្បាស់លាស់ពីការព្រមព្រៀងឬមិនព្រមព្រៀងគ្នាលើចំណុចណាមួយ។ កំណត់ហេតុនេះត្រូវចុះហត្ថលេខាដោយភាគីវិវាទ[36]។ ភាគីវិវាទត្រូវដោះស្រាយវិវាទការងារនៅថ្នាក់សហគ្រាសគ្រឹះស្ថាន ដោយគោរពនូវគោលការណ៍សុចរឹត ស្មោះត្រង់ សន្តិវិធី និងដោយភាពយោគយល់គ្នា[37]។ ក្រោយពីបញ្ចប់នីតិវិធីដោះស្រាយវិវាទការងារនៅថ្នាក់សហគ្រាស ឬគ្រឹះស្ថាន ភាគីវិវាទអាចប្តឹងមក មន្ត្រីផ្សះផ្សា ដើម្បីដោះស្រាយបន្តលើចំណុចវិវាទដែលភាគីមិនព្រមព្រៀងគ្នា[38]។ ភាគីវិវាទមានសិទ្ធិជ្រើសតាំងអ្នកតំណាងក្នុងការដោះស្រាយវិវាទការងារនៅថ្នាក់សហគ្រាសឬ គ្រឹះស្ថាន និងនៅថ្នាក់ក្រសួង។

អ្នកតំណាងភាគីវិវាទត្រូវតែជាបុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ស្របតាមបទបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី និងច្បាប់ជាធរមាន[39]។

#### ខ. ការដោះស្រាយវិវាទការងារបុគ្គលនៅថ្នាក់ក្រសួង

ក្នុងរយះពេល៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលបណ្តឹងពីភាគីណាមួយ មន្ត្រីផ្សះផ្សា ត្រូវធ្វើលិខិតអញ្ជើញទៅភាគីទាំងអស់នៃវិវាទ ឱ្យមកផ្តល់ព័ត៌មាន និងឯកសារជាភស្តុតាងនានា ដើម្បីជាមូលដ្ឋានក្នុងការផ្សះផ្សាវិវាទ។ ការសាកសួរព័ត៌មានត្រូវធ្វើដាច់ដោយឡែកពីគ្នា។ គ្រប់ពេលសាកសួរព័ត៌មាន មន្ត្រីផ្សះផ្សាត្រូវធ្វើកំណត់ហេតុ ដោយមានចុះហត្ថលេខាមន្ត្រីផ្សះផ្សា និងភាគីដែលផ្តល់ព័ត៌ ហើយត្រូវផ្តល់កំណត់ហេតុនេះជូន

---

[34] ប្រកាសស្តីពីនីតិវិធីនៃការដោះស្រាយវិវាទបុគ្គល, លេខ៣១៨សកបយ, ២៩ វិច្ឆិកា ២០០១។

[35] មាត្រា៥ នៃសេចក្តីព្រាងច្បាប់ ស្តីពីនីតិវិធីនៃការជម្រះក្តីវិវាទការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

[36] មាត្រា៦ នៃសេចក្តីព្រាងច្បាប់ ស្តីពីនីតិវិធីនៃការជម្រះក្តីវិវាទការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

[37] មាត្រា៧ នៃសេចក្តីព្រាងច្បាប់ ស្តីពីនីតិវិធីនៃការជម្រះក្តីវិវាទការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

[38] មាត្រា៨ នៃសេចក្តីព្រាងច្បាប់ ស្តីពីនីតិវិធីនៃការជម្រះក្តីវិវាទការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

[39] មាត្រា៩ នៃសេចក្តីព្រាងច្បាប់ ស្តីពីនីតិវិធីនៃការជម្រះក្តីវិវាទការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ភាគីដែលផ្តល់ព័ត៌មាន១ (មួយ) ច្បាប់[40]។ ភាគីនៃវិវាទបុគ្គលឬអ្នកតំណាងនៃជននោះត្រូវចូលមកផ្តល់ព័ត៌មានតាមការកោះអញ្ជើញរបស់មន្ត្រីផ្សះផ្សា។ ក្នុងករណីដើមបណ្តឹងឬអ្នកតំណាងនៃជននោះមិនមកផ្តល់ព័ត៌មានជូនមន្ត្រីផ្សះផ្សា តាមកាលកំណត់ ឬក្នុងរយៈពេល៧ (ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ បន្ទាប់ពីថ្ងៃកំណត់ ដោយគ្មានមូលហេតុសមស្របពាក្យប្តឹងនោះត្រូវចាត់ទុកជាមោឃៈ។ ក្នុងករណីចុងចម្លើយឬអ្នកតំណាងនៃជននោះមិនបង្ហាញខ្លួនតាមកាលកំណត់ ឬក្នុងរយៈពេល៧ (ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ បន្ទាប់ពីថ្ងៃកំណត់ដោយគ្មានមូលហេតុសមស្រប វិវាទត្រូវចាត់ទុកថាមិនសះជា ហើយចុងចម្លើយត្រូវចាត់ទុកថាមានកំហុសដូចការចោទប្រកាន់របស់ដើមបណ្តឹងទាំងស្រុង[41]។

បន្ទាប់ពីការសាកសួរនិងប្រមូលព័ត៌មាននិងឯកសារនានាហើយ មន្ត្រីផ្សះផ្សា ត្រូវធ្វើលិខិតអញ្ជើញភាគីទាំងសងខាងមកធ្វើការផ្សះផ្សា ដោយយកច្បាប់ បទបញ្ជា អនុសញ្ញារួម ឬកិច្ចសន្យាការងារជាមូលដ្ឋាន។ មន្ត្រីផ្សះផ្សាត្រូវធ្វើការផ្សះផ្សាវិវាទបុគ្គល ក្នុងរយៈពេល៣ (បី) សប្តាហ៍យ៉ាងយូរបន្ទាប់ពីបានទទួលពាក្យប្តឹង[42]។ មន្ត្រីផ្សះផ្សាត្រូវធ្វើកំណត់ហេតុនៅរាល់ពេលប្រជុំផ្សះផ្សា ដោយមានបញ្ជាក់ច្បាស់លាស់ពីចំណុចសះជាឬមិនសះជា។ កំណត់ហេតុនោះត្រូវចុះហត្ថលេខាដោយមន្ត្រីផ្សះផ្សា និងភាគីវិវាទទាំងសងខាង ហើយត្រូវចម្លងជូនភាគីវិវាទ[43]។ ការព្រមព្រៀងដែលបានធ្វើនៅចំពោះមុខមន្ត្រីផ្សះផ្សា គឺជាការព្រមព្រៀងដែលយកជាការបានចំពោះមុខច្បាប់[44]។ ក្នុងករណីមិនសះជា មន្ត្រីផ្សះផ្សាត្រូវជម្រាបទៅភាគី អំពីសិទ្ធិរបស់សាមីភាគីដែលអាចធ្វើពាក្យប្តឹងជាបន្តទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។ មន្ត្រីផ្សះផ្សាធ្វើរបាយការណ៍ស្តីពីការផ្សះផ្សាវិវាទបុគ្គលដែលមិនសះជា ទុកជូនភាគីវិវាទបុគ្គល ជាឯកសារយោងដើម្បីប្តឹងទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល[45]។

**១.១.ប្រកាស ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទបុគ្គល**

ក្នុងការដោះស្រាយវិវាទបុគ្គល មុននិងប្តឹងទៅតុលាការ ភាគីណាមួយអាចប្តឹងជាលាយលក្ខណ៍អក្សរទៅអធិការការងារ ដើម្បីធ្វើការផ្សះផ្សាជាមុនសិន។ នាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាស្ថិតនៅអាគារលេខ ២៨ ផ្លូវសម្តេចព្រះធម្មលិខិតអ៊ុក ផ្លូវលេខ១៨៤ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ មានសមត្ថកិច្ចទទួលខុសត្រូវផ្សះផ្សាវិវាទការងារនៅរាជធានីភ្នំពេញ។ មន្ទី

[40] មាត្រា១០នៃសេចក្តីព្រាងច្បាប់ ស្តីពីនីតិវិធីនៃការជម្រះក្តីវិវាទការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

[41] មាត្រា១១ នៃសេចក្តីព្រាងច្បាប់ ស្តីពីនីតិវិធីនៃការជម្រះក្តីវិវាទការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

[42] មាត្រា១២ នៃសេចក្តីព្រាងច្បាប់ ស្តីពីនីតិវិធីនៃការជម្រះក្តីវិវាទការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

[43] មាត្រា១៣ នៃសេចក្តីព្រាងច្បាប់ ស្តីពីនីតិវិធីនៃការជម្រះក្តីវិវាទការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

[44] មាត្រា១៤ នៃសេចក្តីព្រាងច្បាប់ ស្តីពីនីតិវិធីនៃការជម្រះក្តីវិវាទការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

[45] មាត្រា១៥ នៃសេចក្តីព្រាងច្បាប់ ស្តីពីនីតិវិធីនៃការជម្រះក្តីវិវាទការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

សង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត-ក្រុងដទៃទៀត មានសមត្ថកិច្ចទទួលខុសត្រូវផ្សះផ្សាវិវាទការងារនៅខេត្ត-ក្រុងរៀងៗខ្លួន[46]។

ក្រោយពីបានទទួលបណ្តឹងពីភាគីណាមួយ អធិការងារត្រូវធ្វើលិខិតអញ្ជើញទៅភាគីទាំងអស់មកផ្តល់ព័ត៌មាន និងឯកសារជាភស្តុតាងនានាដែលខ្លួនចង់បាន ដើម្បីផ្សះផ្សាវិវាទឱ្យបានសមស្រប។ ការសាកសួរព័ត៌មានបន្ថែមនេះ ត្រូវធ្វើឡើងមួយភាគីម្តងដាច់ដោយឡែកពីគ្នា។ គ្រប់ពេលសាកសួរព័ត៌មានបន្ថែម ត្រូវធ្វើកំណត់ហេតុទុកជាឯកសារដោយមានចុះហត្ថលេខាអធិការងារ និងភាគីដែលផ្តល់ព័ត៌មាននោះផង។ កំណត់ហេតុនេះត្រូវផ្តល់ជូនភាគីដែលផ្តល់ព័ត៌មានមួយច្បាប់ផង[47]។ បើភាគីដើមចោទ ឬតំណាងនៃជននេះ មិនព្រមអញ្ជើញទៅផ្តល់ព័ត៌មានបន្ថែមជូនអធិការងារតាមការកំណត់ ឬក្នុងរយៈពេលបីថ្ងៃយ៉ាងយូបន្ទាប់ពីថ្ងៃកំណត់ (គិតតែថ្ងៃធ្វើការ) ដោយគ្មានមូលហេតុដោយសមស្របទេនោះ ពាក្យប្តឹងនោះត្រូវទុកជាមោឃៈ។ បើភាគីចុងចោទ ឬតំណាងនៃជននេះ មិនព្រមចូលបង្ហាញខ្លួនតាមការកំណត់ ឬក្នុងរយៈពេលបីថ្ងៃយ៉ាងយូបន្ទាប់ពីថ្ងៃកំណត់ (គិតតែថ្ងៃធ្វើការ) ដោយគ្មានមូលហេតុសមស្របទេនោះ រឿងវិវាទត្រូវចាត់ទុកមិនសះជា ហើយត្រូវចាត់ទុកថា ភាគីចុងចោទមានកំហុសដូចការចោទប្រកាន់របស់ភាគីដើមចោទទាំងស្រុង[48]។

បន្ទាប់ពីទទួលព័ត៌មានសព្វគ្រប់អស់ហើយ អធិការងារត្រូវធ្វើលិខិតអញ្ជើញម្តងទៀតឱ្យភាគីទាំងសងខាងចូលរួមប្រជុំជាមួយគ្នាដើម្បីធ្វើការផ្សះផ្សា។

អធិការការងារត្រូវធ្វើការផ្សះផ្សាវិវាទបុគ្គលក្នុងរយៈបីសប្តាហ៍យ៉ាងយូបន្ទាប់ពីបានទទួលពាក្យប្តឹង។

ភាគីវិវាទអាចឱ្យគេជួយអម ឬឱ្យគេតំណាងខ្លួនបាន។

បើភាគីដើមចោទ ឬតំណាងនៃជននេះមិនចូលរួមប្រជុំតាម ហើយគ្មានបញ្ជាក់មូលហេតុសមស្របទេនោះ រឿងវិវាទត្រូវចាត់ទុកថាមិនសះជា ហើយត្រូវចាត់ទុកថាភាគីចុងចោទមានកំហុសដូចការចោទប្រកាន់របស់ភាគីដើមចោទទាំងស្រុង[49]។ លិខិតអញ្ជើញដែលមានចែងក្នុងប្រការ២ និងប្រការ៤ នៃប្រកាសស្តីពីនីតិវិធីនៃការដោះស្រាយវិវាទបុគ្គល ត្រូវផ្ញើរជូនភាគីតាមសំបុត្រអនុសិដ្ឋ ឬលិខិតជូនផ្ទាល់ដៃ ដែលមានចុះហត្ថលេខាបញ្ជាក់ថាបានទទួលហើយ[50]។ ជនទាំងឡាយនឹងអាចជួយអម ឬធ្វើតំណាងរបស់ភាគីវិវាទបានលុះត្រាតែជននោះជាមនុស្សពេញវ័យដែលច្បាប់ទទួលស្គាល់ ហើយអាចសម្រេចកិច្ចការបានផង[51]។ ត្រូវធ្វើកំណត់ហេតុនៅរាល់

[46] ប្រការ១ នៃប្រកាស ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទបុគ្គល។

[47] ប្រការ២ នៃប្រកាស ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទបុគ្គល។

[48] ប្រការ៣ នៃប្រកាស ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទបុគ្គល។

[49] ប្រការ៤ នៃប្រកាស ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទបុគ្គល។

[50] ប្រការ៥ នៃប្រកាស ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទបុគ្គល។

[51] ប្រការ៦ នៃប្រកាស ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទបុគ្គល។

ពេលប្រជុំផ្សះផ្សាដោយមានបញ្ជាក់ច្បាស់លាស់ពីការយល់ព្រម ឬមិនយល់ព្រមសះជានិងគ្នា។ កំណត់ហេតុនោះ ត្រូវចុះហត្ថលេខាដោយអធិការការងារព្រមទាំងហត្ថលេខារបស់ភាគីទាំងសងខាង និងត្រូវចម្លងចែកភាគីផង[52]។ ការព្រមព្រៀងដែលបានធ្វើនៅចំពោះមុខអធិការងារ គឺជាការព្រមព្រៀងយកជាការបានចំពោះមុខច្បាប់[53]។

ក្នុងករណីមិនសះជា ដោយរាប់ទាំងការមិនសះជាដែលមានកំណត់ក្នុងប្រការ៣ និងប្រការ៤ ដូចមានចែងក្នុងប្រកាស ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទបុគ្គល អធិការងារត្រូវជម្រាបទៅភាគី អំពីសិទ្ធិរបស់ភាគីដើមចោទដែលអាចធ្វើពាក្យប្តឹងជាបន្តទៅតុលាការមានសមត្ថកិច្ច ទៅតាមបែបបទដែលមានកំណត់ក្នុងច្បាប់[54]។

## ២.នីតិវិធីដោះស្រាយវិវាទរួមនៅក្រៅប្រព័ន្ធតុលាការ

ការដោះស្រាយវិវាទរួម បើតាមច្បាប់ត្រូវឆ្លងកាត់តាមយន្តការ៤ដំណាក់កាលគឺ **ក**.ដោះស្រាយនៅសហគ្រាសឬគ្រឹះស្ថានរបស់ខ្លួនផ្ទាល់ (ការចរចា) **ខ**.ដោះស្រាយវិវាទការងារនៅថ្នាក់ក្រសួងតាមការប្តឹងទៅ អធិការការងារឬក៏អាចហៅម្យ៉ាងទៀតថាមន្ត្រីផ្សះផ្សាដើម្បីធ្វើការដោះស្រាយដោយផ្អែកលើច្បាប់ (ការផ្សះផ្សា) **គ**.ការដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល (មជ្ឈត្តការ) **ឃ**.ដោះស្រាយវិវាទការងារដោយតុលាការ។

### ក. ការផ្សះផ្សា

បើក្នុងអនុសញ្ញាគ្មានបានគ្រោងនីតិវិធីសម្រាប់ដោះស្រាយទេ ភាគីត្រូវជូនដំណឹងអំពីវិវាទការងាររួម ទៅអធិការងារនៃខេត្ត ក្រុងខ្លួន។ ប៉ុន្តែ ចំពោះវិវាទការងាររួមដែលភាគីពុំបានឱ្យដំណឹងមកខ្លួនទេនោះ អធិការងារអាចចាត់ការ ផ្សះផ្សាតាមនីតិវិធីដែលមានបញ្ញត្តិទុក ក្រោយពីបានដំណឹងអំពីវិវាទនោះភ្លាម[55]។ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ ចាត់តាំងអ្នកផ្សះផ្សាម្នាក់ ក្នុងរយៈពេលសែសិបប្រាំបីម៉ោងគិតចាប់ពីទទួលបានពាក្យបណ្តឹង ឬបានដឹងដោយខ្លួនឯង ពីវិវាទការងាររួម[56]។ ការផ្សះផ្សា ត្រូវធ្វើក្នុងរយៈពេលដប់ប្រាំថ្ងៃ គិតចាប់ពីពេលបានទទួលសេចក្តីបង្គាប់ពីរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ។ ការផ្សះផ្សានេះ អាចធ្វើឡើងវិញបានតែតាមសំណូមពររួមនៃភាគីវិវាទ[57]។ នៅពេលកំពុងផ្សះផ្សា ភាគីវិវាទត្រូវបញ្ជប់គ្រប់វិធានការនៃការវិវាទ។ ភាគីទាំងនោះត្រូវតែចូលរួមនៅគ្រប់ពេលប្រជុំដែលអ្នកផ្សះផ្សាបានកោះអញ្ជើញ។ អវត្តមានដែលគ្មានការបញ្ជាក់មូលហេតុត្រឹមត្រូវ ក្នុងពេលប្រជុំណាមួយនៃការដោះស្រាយវិវាទ ត្រូវទទួលពិន័យដូចមានចែងនៅក្នុងវិធាននៃ ជំពូកទី១៦[58]។

---

[52] ប្រការ៧ នៃប្រកាស ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទបុគ្គល។

[53] ប្រការ៨ នៃប្រកាស ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទបុគ្គល។

[54] ប្រការ៩ នៃប្រកាស ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទបុគ្គល។

[55] មាត្រា៣០៣ នៃច្បាប់ស្តីពីការងារ ១៩៩៧។

[56] មាត្រា៣០៤ នៃច្បាប់ស្តីពីការងារ ១៩៩៧។

[57] មាត្រា៣០៥ នៃច្បាប់ស្តីពីការងារ ១៩៩៧។

[58] មាត្រា៣០៦ នៃច្បាប់ស្តីពីការងារ ១៩៩៧។

ការព្រមព្រៀងសះជាដែលបានចុះហត្ថលេខាដោយភាគី និងបានចុះទិដ្ឋាការដោយអ្នកផ្សះផ្សា មានតម្លៃ និងអានុភាពដូចគ្នានិងអនុសញ្ញារួមរវាងភាគី និងរវាងអ្នកដែលឱ្យគេតំណាងខ្លួន។ ប៉ុន្តែ ប្រសិនបើភាគីតំណាងកម្មករនិយោជិតពុំមែនជាអង្គការសហជីពវិជ្ជាជីវៈណាមួយទេ ការព្រមព្រៀងនេះមិនជំទាស់ទាំងចំពោះអង្គការសហជីពនោះ ទាំងចំពោះកម្មករនិយោជិតដែលឱ្យគេតំណាងខ្លួន[59]។

បើគ្មានការព្រមព្រៀងនិងគ្នាទេ អ្នកផ្សះផ្សាត្រូវកត់ត្រាបញ្ជាក់នូវចំណុចទាំងឡាយដែលការផ្សះផ្សាមិនសះជាហើយត្រូវសរសេររបាយការណ៍អំពីវិវាទនេះ។ អ្នកផ្សះផ្សាត្រូវបញ្ជូនសំណុំលិខិតទាំងអស់នោះទៅជូនរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកនៃវិស័យការងារ យ៉ាងយូរបំផុតក្នុងរយៈពេលសែសិបប្រាំបីម៉ោង ក្រោយពេលបញ្ចប់ការផ្សះផ្សា[60]។

**ខ. ការសំរេចនៃអាជ្ញាកណ្តាល**

ក្នុងករណីដែលការផ្សះផ្សាពុំបានសះជា វិវាទការងារត្រូវដាក់ឱ្យដោះស្រាយតាមៈ

ក. ឬមួយនីតិវិធីដែលមានចែងក្នុងអនុសញ្ញារួមអំពីអាជ្ញាកណ្តាល ប្រសិនបើមាន

ខ. ឬមួយនីតិវិធីផ្សេងទៀត ដែលមានការយល់ព្រមពីភាគីទាំងអស់នៃវិវាទ

គ. ឬមួយក៏នីតិវិធី អំពីអាជ្ញាកណ្តាលដែលមានចែងក្នុងផ្នែកនេះ[61]។

ចំពោះករណីដែលមានចែងក្នុង កថាខណ្ឌ គ នៃមាត្រា៣០៩ នៃច្បាប់ស្តីពីការងារ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ ត្រូវប្តឹងទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលបីថ្ងៃក្រោយពីបានទទួលរបាយការណ៍ដែលមានចែងក្នុង មាត្រា៣០៨ នៃច្បាប់ស្តីពីការងារ ពីអ្នកផ្សះផ្សា។

ក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវធ្វើការរួមប្រជុំជាដាច់ខាត ក្នុងរយៈពេលបីថ្ងៃ បន្ទាប់ពីបានទទួលបណ្តឹង[62]។

សមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវជ្រើសរើសក្នុងចំណោមចៅក្រម សមាជិកនៃគណកម្មការប្រឹក្សាការងារ ហើយនិងជាទូទៅ បណ្តាឥស្សរជនដែលគេស្គាល់ថាមានគុណសម្បត្តិខាងផ្លូវចរិយា និងមានសមត្ថភាពខាងសេដ្ឋកិច្ច និងសង្គមកិច្ច ហើយមាននាមក្នុងបញ្ជីតែងតាំងរៀងរាល់ឆ្នាំដោយ ប្រកាស ក្រសួងទទួលបន្ទុកវិស័យការងារ[63]។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល គ្មានភារកិច្ចពិនិត្យបញ្ហាដទៃ ក្រៅពីបញ្ហាដែលមានបញ្ជាក់ក្នុងកំណត់ហេតុមិនព្រមសះជា ឬបញ្ហាដែលកើតក្រោយការធ្វើកំណត់ហេតុ ជាផលវិបាកផ្ទាល់នៃការវិវាទនោះតែប៉ុណ្ណោះ។ ចំពោះការវិវាទដែលទាក់ទងនិងការបកស្រាយ និងការអនុវត្តន៍ បញ្ញត្តិច្បាប់ ឬអនុសញ្ញារួមណាមួយ ក្រុមប្រឹក្សាដោះស្រាយដោយសមធម៌ចំពោះការវិវាទឯទៀតទាំងអស់។

[59] មាត្រា៣០៧ នៃច្បាប់ស្តីពីការងារ ១៩៩៧។

[60] មាត្រា៣០៨ នៃច្បាប់ស្តីពីការងារ ១៩៩៧។

[61] មាត្រា៣០៩ នៃច្បាប់ស្តីពីការងារ ១៩៩៧។

[62] មាត្រា៣១០ នៃច្បាប់ស្តីពីការងារ ១៩៩៧។

[63] មាត្រា៣១១ នៃច្បាប់ស្តីពីការងារ ១៩៩៧។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានអំណាចធំទូលាយ ដើម្បីស៊ើបអំពីសេដ្ឋកិច្ចនៃសហគ្រាស និងស្ថានភាពខាងសង្គមកិច្ច នៃកម្មករនិយោជិតដែលជាសាមីខ្លួនក្នុងការវិវាទ។

ក្រុមប្រឹក្សានេះមានអំណាចអង្កេតបានគ្រប់រឿង នៅទីកន្លែងសហគ្រាស ឬអង្គការវិជ្ជាជីវៈផ្សេងៗ ព្រមទាំងអាចមានអំណាចចាត់ឱ្យភាគីជូនឯកសារ ឬព័ត៌មានខាងសេដ្ឋកិច្ច គណនេយ្យ ស្ថិតិ ហិរញ្ញវត្ថុ ឬរដ្ឋបាល ដែលមានប្រយោជន៍ក្នុងការបំពេញបេសកម្មខ្លួន។ ក្រុមប្រឹក្សានេះអាចសុំឱ្យអ្នកជំនាញការជួយបានទៀតផង។

សមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវលាក់អាថិកំបាំងវិជ្ជាជីវៈ ចំពោះព័ត៌មាន និងឯកសារទាំងឡាយដែលគេបានបញ្ជូនមកឱ្យខ្លួនពិនិត្យ និងចំពោះហេតុការណ៍ទាំងអស់ដែលខ្លួនបានដឹងក្នុងការបំពេញបេសសកកម្មខ្លួន។ ការរួមប្រជុំនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវតែប្រព្រឹត្តទៅដោយបិទទ្វារ[64]។

ក្នុងរយៈពេលដប់ប្រាំថ្ងៃ រាប់ពីថ្ងៃដែលខ្លួនបានទទួលសំណុំរឿង ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបញ្ជូនសេចក្តីសម្រេចរបស់ខ្លួនទៅ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ ហើយរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារចាត់ការឱ្យដំណឹងទៅភាគីភ្លាម។ ភាគីមានសិទ្ធិប្តឹងជំទាស់និងដំណោះស្រាយរបស់អាជ្ញាកណ្តាលនេះ ដោយជូនដំណឹងទៅ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ តាមសំបុត្រអនុសិដ្ឋ ឬតាមមធ្យោបាយដែលទុកជាបានការផ្សេងទៀត ក្នុងរយៈពេលប្រាំបីថ្ងៃពេញ ចាប់ពីថ្ងៃទទួលដំណឹង[65]។ សេចក្តីសន្និដ្ឋាននៃដំណោះស្រាយរបស់អាជ្ញាកណ្តាល ដែលគ្មានភាគីកិច្ចប្តឹងជំទាស់ទេអាចយកទៅអនុវត្តបានភ្លាម។

ដំណោះស្រាយរបស់អាជ្ញាកណ្តាលដែលអាចយកទៅអនុវត្តបានហើយ ត្រូវតំកល់ទុក និងចុះបញ្ជីការទៅតាមបែបបទដូចគ្នានិងអនុសញ្ញារួមដែរ[66]។ កំណត់ហេតុព្រមព្រៀងសះជា និងដំណោះស្រាយរបស់អាជ្ញាកណ្តាលដែលគ្មាននរណាប្តឹងជំទាស់ទេនោះ ត្រូវបិទផ្សាយនៅទីស្ថានទាំងឡាយនៃសហគ្រាស ដែលមានកើតវិវាទ និងក្នុងការិយាល័យនៃអធិការដ្ឋានការងារនៃខេត្ត / ក្រុង[67]។

**២.១.ប្រកាស ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទការងាររួម**

ចំពោះការដោះស្រាយវិវាទការងាររួម បើក្នុងអនុសញ្ញារួមមិនបានគ្រោងនីតិវិធីសម្រាប់ដោះស្រាយទេគ្រប់រឿងវិវាទត្រូវតែភាគីណាមួយប្តឹងទៅអធិការកិច្ចការងារ។ នាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ស្ថិតនៅអាគារលេខ២៨ វិថីសម្តេចព្រះធម្មលិខិតអ៊ុក ផ្លូវលេខ១៨៤ សង្កាត់ជ័យជំនះ ខ័ណ្ឌដូនពេញ មានសមត្ថកិច្ចទទួលខុសត្រូវដោះស្រាយវិវាទការងាររួម ដែលកើត

[64] មាត្រា៣១២ នៃច្បាប់ស្តីពីការងារ ១៩៩៧។

[65] មាត្រា៣១៣ នៃច្បាប់ស្តីពីការងារ ១៩៩៧។

[66] មាត្រា៣១៤ នៃច្បាប់ស្តីពីការងារ ១៩៩៧។

[67] មាត្រា៣១៥ នៃច្បាប់ស្តីពីការងារ ១៩៩៧។

មាននៅរាជធានីភ្នំពេញ។ មន្ទីសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុងដទៃទៀត មានសមត្ថកិច្ចទទួលខុសត្រូវដោះស្រាយវិវាទការងាររួម ដែលកើតមាននៅខេត្ត-ក្រុងរៀងៗខ្លួន[68]។

ក្រោយពីបានទទួលពាក្យបណ្តឹងរបស់ភាគីណាមួយ អធិការងារត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីចាត់តាំងអ្នកផ្សះផ្សាម្នាក់ក្នុងរយៈពេល៤៨ម៉ោង។ បន្ទាប់មកអ្នកផ្សះផ្សាត្រូវធ្វើលិខិតអញ្ជើញទៅភាគីទាំងអស់មកផ្តល់ព័ត៌មាន ឯកសារជាភស្តុតាងនានាដើម្បីផ្សះផ្សាវិវាទអោយបានសមស្រប។ ការសាកសួរព័ត៌មានបន្ថែម ត្រូវធ្វើឡើងមួយភាគីម្តងៗដាច់ដោយឡែកពីគ្នា។ គ្រប់ពេលសាកសួរព័ត៌មានបន្ថែមត្រូវធ្វើកំណត់ហេតុទុកជាឯកសារ ដោយមានចុះហត្ថលេខាអ្នកផ្សះផ្សា និងភាគីដែលផ្តល់ព័ត៌មាននោះផង។ ភាគីទាំងពីរត្រូវតែចូលរួមប្រជុំតាមការអញ្ជើញរបស់អ្នកផ្សះផ្សា។

បើភាគីណាមួយមិនចូលរួមប្រជុំនោះទេ អ្នកផ្សះផ្សាត្រូវរាយការណ៍ ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីចាត់វិធានការទៅតាមច្បាប់ស្តីពីការងារ[69]។ ក្នុងករណីដែលបានទទួលព័ត៌មានសព្វគ្រប់ពីភាគីទាំងអស់ហើយ អ្នកផ្សះផ្សាត្រូវធ្វើលិខិតអញ្ជើញម្តងទៀតអោយភាគីដែលពាក់ព័ន្ធទាំងអស់មកចូលរួមប្រជុំទាំងអស់គ្នា ដើម្បីធ្វើការផ្សះផ្សា។ ការផ្សះផ្សាត្រូវធ្វើក្នុងរយៈពេល១៥ថ្ងៃ គិតចាប់ពីពេលដែលបានទទួលសេចក្តីបង្គាប់ពីរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។ ការផ្សះផ្សានេះអាចធ្វើឡើងវិញបានតែតាមសំណូមពររួមនៃភាគីវិវាទ។ ភាគីទាំងពីរត្រូវតែចូលរួមប្រជុំតាមការអញ្ជើញរបស់អ្នកផ្សះផ្សា។ បើភាគីណាមួយមិនចូលរួមប្រជុំទេនោះ អ្នកផ្សផ្សាត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីចាត់វិធានការទៅតាមច្បាប់ស្តីពីការងារ[70]។ លិខិតអញ្ជើញដែលមានចែងក្នុងប្រការ២ និងប្រការ៣ នៃប្រកាស ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទការងាររួម ត្រូវផ្ញើរជូនភាគីវិវាទតាមសំបុត្រអនុសិដ្ឋដែលមានហត្ថលេខាបញ្ជាក់ថាបានទទួលហើយ ឬលិខិតជូនផ្ទាល់ដៃដោយមានចុះហត្ថលេខាថាបានទទួល[71]។ ភាគីវិវាទអាចអោយគេជួយអម ឬអោយគេតំណាងខ្លួនបាន។ ជនទាំងឡាយដែលអាចជួយអម ឬធ្វើជាតំណាងរបស់ភាគីវិវាទមបាន លុះត្រាតែជនទាំងនោះជាមនុស្សពេញវ័យដែលច្បាប់ទទួលស្គាល់ ហើយអាចសម្រេចកិច្ចការបានផង[72]។ ត្រូវធ្វើកំណត់ហេតុនៅរាល់ពេលប្រជុំ

[68] ប្រការ១ នៃប្រកាស ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទការងាររួម។
[69] ប្រការ២ នៃប្រកាស ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទការងាររួម។
[70] ប្រការ៣ នៃប្រកាស ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទការងាររួម។
[71] ប្រការ៤ នៃប្រកាស ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទការងាររួម។
[72] ប្រការ៥ នៃប្រកាស ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទការងាររួម។

ដោយមានបញ្ជាក់ច្បាស់លាស់ពីការយល់ព្រម ឬមិនយល់ព្រមសះជានិងគ្នា។ កំណត់ហេតុនោះត្រូវចុះទិដ្ឋាការដោយអ្នកផ្សះផ្សាព្រមទាំងហត្ថលេខារបស់ភាគីដែលពាក់ព័ន្ធ និងត្រូវចម្លងចែកភាគីទាំងអស់[73]។

ការព្រមព្រៀងសះជាដែលបានចុះហត្ថលេខាដោយភាគី និងបានចុះទិដ្ឋាការដោយអ្នកផ្សះផ្សា មានតម្លៃ និងអានុភាពដូចគ្នា និងអនុសញ្ញារួមរវាងភាគី និងរវាងអ្នកដែលអោយគេតំណាងខ្លួន។ ប៉ុន្តែប្រសិនបើភាគីតំណាងកម្មករនិយោជិតពុំមែនជាអង្គការសហជីពវិជ្ជាជីវៈណាមួយទេ ការព្រព្រៀងនេះមិនជំទាស់ទាំងចំពោះអង្គការសហជីពនោះ ទាំងចំពោះកម្មករនិយោជិតដែលអោយគេតំណាងខ្លួន[74]។ ចំពោះវិវាទការងាររួមដែលភាគីពុំបានប្តឹង ឬអោយដំណឹងមកអធិការកិច្ចការងារទេនោះ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនិតិសម្បទា អាចចាត់ការផ្សះផ្សាតាមនីតិវិធីដែលកំណត់ក្នុងប្រការ២ ប្រការ៣ ប្រការ៤ ប្រការ៥ និងប្រការ៦ នៃប្រកាស ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទការងាររួម ក្រោយពីបានដំណឹងពីវិវាទនេះភ្លាម[75]។ វិវាទការងាររួមណាដែលមានប៉ះពាល់ ឬអាចបណ្តាលអោយប៉ះពាល់ដល់សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ អធិការកិច្ចការងារ ក្រោយពីបានទទួលដំណឹងស្តីពីវិវាទនេះ ត្រូវធ្វើរបាយការណ៍ជាបន្ទាន់ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីចាត់តាំងអ្នកផ្សះផ្សា និងចាត់ការធ្វើការផ្សះផ្សាភ្លាមៗ ចុះសាកសួរព័ត៌មាន និងធ្វើការផ្សះផ្សាដល់ទីកន្លែងតែម្តង[76]។ បើមានអនុសញ្ញាបានគ្រោងពីនីតិវិធីច្បាស់លាស់ សម្រាប់ដោះស្រាយវិវាទការងាររួមហើយនោះ វិវាទការងាររួមត្រូវតែដោះស្រាយតាមនីតិវិធីនៃអនុសញ្ញានេះ[77]។

ចំពោះវិវាទការងាររួមដែលធ្វើការផ្សះផ្សាមិនព្រមសះជា អ្នកផ្សះផ្សាត្រូវរាយការណ៍ជាបន្ទាន់ ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីមានវិធានការដោះស្រាយបន្ត[78]។

## ផ្នែកទី៣៖ វិវាទពាណិជ្ជកម្ម

វិវាទពាណិជ្ជកម្ម គឺជាវិវាទដែលកើតឡើងពីការធ្វើពាណិជ្ជកិច្ច ហើយដែលត្រូវបានកំណត់ដោយច្បាប់ជាតិ និងច្បាប់អន្តរជាតិ ព្រមទាំងទំលាប់ក្នុងការធ្វើពាណិជ្ជកម្មផងដែរ ។ គូភាគីដែលអនុវត្តពាណិជ្ជកិច្ច និងជា

[73] ប្រការ៦ នៃប្រកាស ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទការងាររួម។
[74] ប្រការ៧ នៃប្រកាស ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទការងាររួម។
[75] ប្រការ៨ នៃប្រកាស ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទការងាររួម។
[76] ប្រការ៩ នៃប្រកាស ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទការងាររួម។
[77] ប្រការ១០ នៃប្រកាស ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទការងាររួម។
[78] ប្រការ១១ នៃប្រកាស ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទការងាររួម។

គូរភាគីវិវាទ អាចជាពាណិជ្ជករនិងពាណិជ្ជករ ឬពាណិជ្ជករនិងជនមិនមែនពាណិជ្ជករ ដោយអាស្រ័យទៅតាមប្រភេទ និងបែបផែននៃអាជីវកម្ម [79]។

**កថាភាគទី១៖ មូលហេតុនៃវិវាទពាណិជ្ជកម្ម**

នៅក្នុងការធ្វើពាណិជ្ជកម្មនាពេលបច្ចុប្បន្នតែងតែជួបប្រទះបញ្ហាជាច្រើនដែលកើតឡើងរវាងពាណិជ្ជករ និងពាណិជ្ជករ ឬពាណិជ្ជករនិងជនមិនមែនជាពាណិជ្ជករ បញ្ហាទាំងនោះរួមមានដូចជា៖

- ជាទំនាស់ដែលកើតឡើងរវាងពាណិជ្ជករ និងពាណិជ្ជករ នៅក្នុងសកម្មភាពពាណិជ្ជកម្មរបស់ពួកគេ
- ជាទំនាស់ដែលកើតឡើងក្នុងសកម្មភាពពាណិជ្ជកម្ម
- ជាទំនាស់រវាងសមាជិកក្រុមហ៊ុនរបស់ក្រុមហ៊ុនពាណិជ្ជកម្ម
- ជាទំនាស់ដែលទាក់ទងនឹងការចុះបញ្ជីពាណិជ្ជកម្ម
- ករណីក្ស័យធនក្នុងសំណុំរឿងពាណិជ្ជកម្ម
- ការបំពានកិច្ចសន្យាពាណិជ្ជកម្ម
- ការមិនគោរពកាតព្វកិច្ចក្នុងកិច្ចសន្យាពាណិជ្ជកម្ម
- បញ្ហាអំពីអាជ្ញាយុកាលនៃការទាមទារបំណុល
- បញ្ហានៅពេលធ្វើសន្តតិកម្មនៃកិច្ចសន្យាពាណិជ្ជកម្ម
- ការបំពានកាតព្វកិច្ចពាណិជ្ជកម្មរបស់អ្នកលក់
- ការបំពានកាតព្វកិច្ចពាណិជ្ជកម្មរបស់អ្នកទិញ[80]។

**កថាភាគទី២៖ ដំណោះស្រាយវិវាទពាណិជ្ជកម្ម**

ក្នុងការធ្វើអាជីវកម្ម អាជីវករតែងតែថ្លឹងថ្លែងរវាងហានិភ័យ និងផលចំណេញ ។ ប៉ុន្តែ នៅពេលដែលបរិយាកាស អាជីវកម្មគ្មានស្ថេរភាព ឬមិនអាចព្យាករទុកមុនបាន នោះវានឹងបង្កការលំបាកក្នុងការថ្លឹងថ្លែងរវាងហានិភ័យ និងផលចំណេញ ។ ហេតុដូច្នេះហើយ ប្រព័ន្ធច្បាប់ល្អ និងច្បាស់លាស់សម្រាប់ការធ្វើអាជីវកម្ម មានសារៈសំខាន់ណាស់ក្នុងការជំរុញ វិនិយោគ និងកំណើនសេដ្ឋកិច្ច។ ប្រទេសជាច្រើនដែលមានប្រព័ន្ធច្បាប់ខ្សោយ និងមានយន្តការដោះស្រាយវិវាទពាណិជ្ជកម្មស្មុគស្មាញ មានកំណើនសេដ្ឋកិច្ចទាប ជាងសក្តានុពលប្រសិនបើប្រព័ន្ធច្បាប់ របស់គេធ្វើការប្រសើរជាងនេះ។ នេះដោយសារតែអាជីវកម្មស្ទាក់ស្ទើរក្នុងការចុះកិច្ចសន្យា ឬធ្វើពាណិជ្ជកម្មផ្សេងៗ នៅពេលដែលគេមិនមាន ការជឿជាក់ថាប្រព័ន្ធច្បាប់នឹងអាចអនុវត្តកិច្ចសន្យារបស់គេបាន។ ការណ៍នេះនាំឱ្យមានកំណើនទាប ហើយធ្វើឱ្យមានការខូចខាត ដល់សកម្មភាពវិនិយោគ។

[79] សៀវភៅមេរៀន ដោះស្រាយវិវាទពាណិជ្ជកម្ម សាស្ត្រាចារ្យ ជ័យ រិទ្ធី។

[80] សៀវភៅមេរៀន នីតិពាណិជ្ជកម្ម សាស្ត្រាចារ្យ កង់ ស៊ីផាន់ណារ៉ា។

ក្នុងករណីប្រទេសកម្ពុជា ថ្វីបើសេដ្ឋកិច្ចមានលក្ខណៈវិជ្ជមាន ដោយមានកំណើនខ្លាំងជាច្រើនឆ្នាំកន្លងមក ប្រព័ន្ធច្បាប់ល្អប្រសើរជាងនេះ នឹងកម្ពុជាមានវិនិយោគទុនច្រើនជាងនេះទៅទៀត និងប្រហែលជាអាចជំរុញឱ្យមានកំណើនសេដ្ឋកិច្ចខ្ពស់ជាងពេលបច្ចុប្បន្ន។ បើយើងក្រលេកមើលទៅអនាគត ការលំអរប្រព័ន្ធដោះស្រាយវិវាទពាណិជ្ជកម្ម និងប្រព័ន្ធច្បាប់នៅកម្ពុជា មានសារៈសំខាន់ណាស់សម្រាប់ឱ្យកម្ពុជារក្សាកំណើនដ៏ខ្ពស់នេះក្នុងរយៈពេលវែង។ នេះជាហេតុផលដែលការបង្កើតមជ្ឈមណ្ឌលដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺជាជំហានវិជ្ជមានមួយ[81]។

នៅពេលដែលមានវិវាទពាណិជ្ជកម្ម អាជីវកម្មនៅកម្ពុជាតែងតែយល់ថាជំរើសរបស់ពួកគេក្នុងការដោះស្រាយវិវាទពាណិជ្ជកម្មតាមរយៈ ក្រៅប្រព័ន្ធតុលាការ និងតាមរយៈតុលាការដែលជំរើសទាំងនោះរួមមាន៖

- ការចរចារ
- ការផ្សះផ្សា
- សន្ទានកម្ម
- មជ្ឈត្តការ
- តុលាការ ជាដើម[82]។

[81] ព្រឹត្តិប័ត្រ ស្តីពីបញ្ហាអាជីវកម្ម ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៧។
[82] សៀវភៅមេរៀន ដោះស្រាយវិវាទពាណិជ្ជកម្ម សាស្ត្រាចារ្យ ជ័យ រិទ្ធី ទំព័រ៦

# ជំពូកទី៣
# នីតិវិធីនៃការដោះស្រាយវិវាទ
# ក្រៅប្រព័ន្ធតុលាការ

# ជំពូកទី៣
# នីតិវិធីនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

## ផ្នែកទី១៖ ការចរចា

### កថាភាគទី១៖ និយមន័យនៃកាចរចា

ការចរចា គឺជាដំណើរការនៃការឆ្លើយឆ្លងគ្នាទៅវិញទៅមក ដែលតាមរយៈនេះ ភាគីទាំងអស់ដាក់ជូន ឬពិចារណាលើសំណើផ្សេងៗ រហូតដល់សំណើមួយត្រូវបានធ្វើឡើងហើយត្រូវបានគេទទួលយក[83]។

ការចរចា គឺជាទម្រង់ដ៏សាមញ្ញបំផុតនៃដំណើរការដោះស្រាយវិវាទនៅទូទាំងពិភពលោកដែលគេឃើញមានទាំងនៅក្នុងយុត្តាធិការនៃច្បាប់ស៊ីវិល (Civil Law) និងច្បាប់អង់គ្លេស (Common Law) ។ ការចរចា អាចដោះស្រាយវិវាទធំ និងតូច ហើយអាចជាដំណើរការដ៏ស្មុគស្មាញបំផុត ឬសាមញ្ញធម្មតាមួយ។ មនុស្សតែងតែធ្វើការចរចាគ្រប់ពេលទាំងអស់។ វាគឺជាទម្រង់សំខាន់បំផុតនៃការប្រាស្រ័យទាក់ទងរវាងមនុស្ស និងមនុស្ស។ មនុស្សធ្វើការចរចាទោះបីជានៅពេលគ្មានវិវាទក៏ដោយ។ ឧទាហរណ៍ នៅពេលដែលបុគ្គលណាម្នាក់ព្យាយាមបញ្ចុះបញ្ចូលឱ្យក្រុមគ្រួសាររបស់ខ្លួនទៅធ្វើដំណើរកំសាន្ត ការចរចាអំពីកន្លែងដែលត្រូវទៅ ឬពេលវេលាចេញដំណើរ អាចនឹងកើតមាន។

ការចរចាអាចធ្វើឡើងតាមវិធីច្រើនយ៉ាងដូចជា ការចរចាដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ។ ការចរចាអាចធ្វើឡើងដោយផ្ទាល់រវាងភាគីនាក់ ឬតាមរយៈតំណាងរបស់ភាគីទាំងនោះ។ ការចរចារអាចធ្វើឡើងតាមបែបធម្មតា ឬមានលក្ខណៈផ្លូវការ។ គេអាចធ្វើការចរចាតាមរយៈសំបុត្រ ឬអ៊ីម៉ែលផងដែរ។ នៅក្នុងប្រទេសកម្ពុជា ការចរចាច្រើនតែធ្វើឡើងនៅចំពោះមុខគ្នាផ្ទាល់ ប៉ុន្តែគេក៏អាចចរចាតាមរយៈទូរសព្ទផងដែរ។ នៅពេលមានការចរចាពាក់ព័ន្ធនឹងវិវាទតាមផ្លូវច្បាប់ ការចរចាអាចនឹងរួមផ្សំទៅដោយមធ្យោបាយទំនាក់ទំនងទាំងអស់នេះ។

នៅក្នុងច្បាប់របស់ប្រទេសកម្ពុជាគាំទ្រឱ្យមានការចរចា។ ក្រមនីតិវិធីរដ្ឋប្បវេណីរបស់ប្រទេសកម្ពុជាលើកទឹកចិត្តឱ្យមានការស្រុះស្រួលគ្នាតាមការចរចារវាងភាគីពីរនាក់[84]។

យុត្តាធិការជាច្រើនផ្តល់ភាពអនុគ្រោះដល់ដំណោះស្រាយវិវាទតាមរយៈការចរចា ដោយសារតែមានហេតុផលមួយដែលល្អប្រសើរ។ ដោយហេតុថាយុត្តាធិការជាច្រើនមានបញ្ជីរឿងក្តីជាច្រើនដែលមិនទាន់វិនិច្ឆ័យ វិធីតែម្យ៉ាងគត់ក្នុងការដោះស្រាយវិវាទឱ្យទាន់ពេលវេលា គឺលើកទឹកចិត្តឱ្យភាគីវិវាទពិភាក្សាអំពីបញ្ហានោះជាមួយគ្នាហើយព្យាយាមឈានទៅរកការព្រមព្រៀងគ្នាមួយដែលល្អប្រសើរ[85]។

[83] សៀវភៅដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មេធាវី ស្ទីវិន អ៊ែម អូស្ទើរមីឡឺរ (បោះពុម្ពលើកទី២ ខែមករា ឆ្នាំ២០១០)។

[84] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៩៧ (ឆ្នាំ២០០៦)។

[85] សៀវភៅដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មេធាវី ស្ទីវិន អ៊ែម អូស្ទើរមីឡឺរ (បោះពុម្ពលើកទី២ ខែមករា ឆ្នាំ២០១០)។

## កថាភាគទី២៖ ដំណាក់កាលនៃការចរចា

ក្រៅពីការហាមឃាត់ចំពោះការបំភ័ន្ត ឬបង្ខិតបង្ខំ ដំណើរការចរចាមិនមានប្រើវិធានអ្វីឱ្យជាក់លាក់នោះទេ។ មិនមានច្បាប់ឬលក្ខន្តិកៈណាមួយដែលណែនាំអំពីដំណើរការចរចាឡើយ។ ប៉ុន្តែគេអាចសិក្សាស្វែងយល់អំពីដំណើរការរបស់វាបានកាន់តែប្រសើរ តាមរយៈដំណាក់កាលចំនួនបីធំៗដូចខាងក្រោមៈ

1. ដំណាក់កាលត្រៀម
2. ដំណាក់កាលចាប់ផ្តើម
3. ដំណាក់កាលបញ្ចប់

ការចរចានីមួយៗមានភាពខុសៗគ្នា ចំពោះការទិញទំនិញនៅផ្សារ ភាគច្រើននៃដំណាក់កាលទាំងនេះនឹងកន្លងទៅតែក្នុងរយៈពេលប៉ុន្មានវិនាទីតែប៉ុណ្ណោះ។ នៅក្នុងការចរចាផ្លូវច្បាប់មានលក្ខណៈស្មុគស្មាញ ដំណាក់កាលទាំងនោះអាចត្រូវការរយៈពេលជាច្រើនថ្ងៃ ឬជាច្រើនសប្តាហ៍ដើម្បីបំពេញ[86]។

### ១.ដំណាក់កាលត្រៀម

- ស្វែងរកអង្គហេតុ
- វិភាគច្បាប់
- ស្វែងយល់អំពីផលប្រយោជន៍ និងគោលដៅរបស់អតិថិជន
- កំណត់តម្លៃ
- ពិចារណាលើការទាមទាររបស់ភាគីដទៃទៀត
- បង្កើតយុទ្ធសាស្ត្រ

ដំណាក់កាលទីមួយនៃការចរចា គឺជាដំណាក់កាលត្រៀម។ នៅក្នុងដំណាក់នេះ ភាគី និងមេធាវីរបស់ខ្លួនត្រូវពិនិត្យ មើលរឿងក្តីយ៉ាងប្រុងប្រយ័ត្ន ហើយព្យាយាមធ្វើសេចក្តីសន្និដ្ឋានជាមូលដ្ឋានមួយចំនួន មុននឹងចាប់ផ្តើមដំណើរការចរចា។ ជំហានទីមួយរបស់មេធាវី គឺធ្វើការស្រាវជ្រាវ និងស្វែងរកអង្គហេតុដែលពាក់ព័ន្ធនឹងរឿងក្តីទាំងអស់។ មានន័យថា ជាការសម្ភាសជាមួយមនុស្សម្នាក់ ឬច្រើននាក់ដោយផ្ទាល់។ វាក៏អាចពាក់ព័ន្ធនឹងការពិនិត្យមើលឡើងវិញនូវភស្តុតាងជាឯកសារ ដូចជា កិច្ចសន្យា ឬវិក័យប័ត្រផ្សេងៗ។

បន្ទាប់ពីមេធាវីយល់ច្បាស់អំពីអង្គហេតុមក ជំហានបន្ទាប់គឺវិភាគច្បាប់ ដោយផ្អែកលើអង្គហេតុទាំងនោះ។ ច្បាប់អាចមិនមានចម្លើយមិនច្បាស់លាស់។ បើមិនដូចច្នេះទេ បទដ្ឋានច្បាប់អាចមានភាពច្បាស់លាស់ ប៉ុន្តែអង្គហេតុអាចមានភាពចំរូងចំរាស់។ ត្រង់ចំណុចនេះ ប្រការដែលសំខាន់គឺ មេធាវីត្រូវព្យាយាមបង្កើតអំណះ

[86] សៀវភៅដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មេធាវី ស៊ីរិន អ៊ែម អូស្នើរមីឡឺរ៍ (បោះពុម្ពលើកទី២ ខែមករា ឆ្នាំ២០១០)។

អំណាចផ្លូវច្បាប់ឱ្យបានច្រើនតាមដែលអាចធ្វើបាន ព្រមទាំងវាយតម្លៃដោយមិនលម្អៀងអំពីចំណុចខ្លាំងនៃអំណាៈអំណាចទាំងនោះ។

ជំហានបន្ទាប់មកទៀត គឺត្រូវស្វែងយល់អំពីផលប្រយោជន៍ និងគោលដៅរបស់កូនក្តី។ ប្រការនេះទាមទាឱ្យមេធាវីសួរសំណួរជាមូលដ្ឋានបន្ថែមទៀត ដូចជាអាជីវកម្ម សម្ព័ន្ធភាព ការភ័យព្រួយ បំណង់ប្រាថ្នា និងគោលដៅរបស់កូនក្តី។ល។ ខាងក្រោមនេះគឺជាបញ្ជីនៃផលប្រយោជន៍មួយចំនួនដែលកូនក្តីអាចមានក្រៅពីបញ្ហាប្រាក់កាសៈ

- ការរក្សាការសម្ងាត់
- សុវត្ថិភាពរាងកាយ
- ការរក្សាកេរ្តិ៍ឈ្មោះ
- ការរក្សាទំនាក់ទំនងល្អជាមួយភាគីម្ខាងទៀត
- ការបន្តការងារ
- ការទទួលស្គាល់ចំពោះកិច្ចប្រឹងប្រែងរបស់កូនក្តីនោះ
- ការទទួលបាននូវការសម្តែងភាពសោកស្តាយ ទឹកចិត្តអាណិតអាសូរ ឬការសុំទោស
- ការមាន ថ្ងៃឡើងតុលាការ របស់កូនក្តីនោះ
- ឱ្យភាគីម្ខាងទៀតស្តាប់ និងយល់ពីកូនក្តីនោះ
- ការសង្គ្រោះមុខមាត់
- ការធ្វើភាគីម្ខាងទៀតអាម៉ាសមុខ ឬអៀនខ្មាស់ជាសាធារណៈ
- ការចង់ផ្សាភ្ជាប់ខ្លួនទៅនឹងវប្បធម៌ គ្រួសារ ឬអង្គការស្ថាប័នណាមួយ
- ការបញ្ជាក់ឱ្យឃើញថាកូនក្តីនោះជាអ្នកត្រូវ

នៅក្នុងករណីខ្លះ ផលប្រយោជន៍ និងគោលដៅទាំងនេះអាចមានសារៈសំខាន់ជាងប្រាក់កាសសម្រាប់ភាគីម្ខាង។ ឧទាហរណ៍ កូនក្តីអាចមានអំណាៈអំណាចរឹងមាំផ្អែកលើទស្សនៈផ្លូវច្បាប់ ប៉ុន្តែផលប្រយោជន៍របស់កូនក្តីនោះអាចជាការជៀសវាងនូវការប្រឈមមុខជាសាធារណៈ។ ឬក៏ថា កូនក្តីអាចត្រូវការដំណោះស្រាយមួយដែលឆាប់រហ័សដោយសារតែការលំបាកផ្នែកហិរញ្ញវត្ថុ ពេលកំណត់នៃអាជីវកម្ម ដែលការនេះធ្វើឱ្យដំណោះស្រាយដែលឆាប់រហ័សកាន់តែមានសារៈសំខាន់ ជាងការទទួលបានជាអតិបរមាពីការព្រមព្រៀងស្រុះស្រួល។

ដូចបានពិភាក្សាពីខាងដើមក្នុងជំពូកនេះ ក្រោយពេលដែលអង្គហេតុ ការវិភាគច្បាប់ និងផលប្រយោជន៍ត្រូវបានស្វែងយល់រួច មេធាវីអាចគណនាតម្លៃ ពោលគឺជម្រើសប្រសើរបំផុតរបស់កូនក្តីក្រៅពីការព្រមព្រៀងតាមរយៈការចរចា។

ក្រោយពីបានគណនា តម្លៃ របស់កូនក្តីរួច មេធាវីត្រូវពិនិត្យលើរឿងក្តីតាមទស្សនៈរបស់ភាគីម្ខាងទៀត។ ប្រហែលជាភាគីម្ខាងទៀតមិនយល់ស្របលើអង្គហេតុ ហើយជឿថាភាគីរបស់អ្នក ឬភាគីម្ខាងទៀត មានកំហុស។ ប្រហែលជាភាគីម្ខាងទៀតមានផលប្រយោជន៍ដែលសំខាន់ ដែលទំនងនឹងធ្វើឱ្យគេកាន់តែចង់ដោះស្រាយរឿងក្តីនោះថែមទៀត។

ក្រោយពេលជំហានខាងលើត្រូវបានបំពេញរួច មេធាវិត្រូវបង្កើតយុទ្ធសាស្ត្រសម្រាប់ការចរចា។ យុទ្ធសាស្ត្រនេះត្រូវផ្តោតលើរបៀបបង្ហាញការទាមទាទៅភាគីម្ខាងទៀត តើសម្បទានអ្វីខ្លះដែលកូនក្តីរបស់អ្នកអាចធ្វើជាយថាហេតុ តើផលប្រយោជន៍ដែលសំខាន់មានអ្វីខ្លះ ដំណោះស្រាយដែលអាចមាន ព្រមទាំង តម្លៃ ឬតម្លៃបម្រុង។ យុទ្ធសាស្ត្រនេះអាចកំណត់ឡើងដោយការឆ្លើយសំណួរនៅក្នុងទំព័រនិទានុប្បវត្តិនៃកាចរចា ដែលមានចំណងជើងថា ការរៀបចំផែនការសម្រាប់កាចរចា ដែលស្ថិតនៅចុងបញ្ចប់នៃជំពូកនេះ។ ត្រូវពិនិត្យមើលយុទ្ធសាស្ត្រនេះឡើងវិញជាមួយកូនក្តីដើម្បីធានាថាកូនក្តីពេញចិត្តចំពោះយុទ្ធសាស្ត្រទាំងនេះ រីឯកូនក្តីវិញក៏ត្រូវផ្តល់សិទ្ធិអំណាចពេញលេញដល់មេធាវីក្នុងការចរចាដោយអនុលោមតាមយុទ្ធសាស្ត្រនេះផងដែរ។

**២.ដំណាក់កាលចាប់ផ្តើម**

ជាញឹកញាប់ ដំណាក់កាលចាប់ផ្តើមនៃការចរចាត្រូវបានបំភ្លេចចោល ដោយចាត់ទុកថាវាមិនសំខាន់។ ផ្ទុយទៅវិញដំណាក់កាលនេះមានភាពចាំបាច់ចំពោះភាពជោគជ័យនាពេលក្រោយមកទៀត។ នៅក្នុងដំណាក់កាលនេះ មេធាវីធ្វើទំនាក់ទំនងគ្នាទៅវិញទៅមក ដើម្បីពិភាក្សាអំពីបែបបទនៃការចរចា ដូចជា តើគួរតែមានការចរចាដែរ ឬទេ? និងតើការចរចាទាំងនេះត្រូវធ្វើឡើងនៅ ពេលណា នៅកន្លែងណា និងដោយរបៀបណា។

- តើគួរតែមានការចរចាដែរ ឬទេ
- តើការចរចាទាំងនេះត្រូវធ្វើឡើង នៅពេលណា
- តើការចរចាទាំងនេះត្រូវធ្វើឡើង នៅកន្លែងណា
- តើការចរចាទាំងនេះត្រូវធ្វើឡើង ដោយរបៀបណា

សំណួរថា (គួរឬទេ) តើគួរមានការចរចាដែរឬទេ មានសារៈសំខាន់ណាស់។ នៅក្នុងករណីមួយចំនួន ភាគីទីមួយដែលស្នើឱ្យមានការចរចា អាចត្រូវបានគេមើលឃើញថាជាការបង្ហាញពីភាពទន់ខ្សោយរបស់ខ្លួន។ ប្រសិនបើមានករណីបែបនេះមែន មេធាវីត្រូវគិតដោយប្រុងប្រយ័ត្នអំពីរបៀបបង្ហាញសំណើរនោះ។ ជាគោលការណ៍ទូទៅ ប្រសិនបើភាគីមានផលប្រយោជន៍កាន់តែតិចនៅក្នុងការចរចា ភាគីនោះកាន់តែមានជំហររឹងមាំស្តែងឡើង។ អាស្រ័យហេតុនេះការព្យាយាមបង្ហាញការមិនមានចំណាប់អារម្មណ៍នៅក្នុងការចរចា ប៉ុន្តែនៅតែយល់ព្រមចូលរួមក្នុងការចរចា ជួនកាលក៏ជាប្រការដែលមានសារៈប្រយោជន៍ដែរ។

- **នៅពេលណា**

ជួនកាល សំណួរផ្សេងទៀតត្រូវបានចាត់ទុកថាជាបែបបទផ្លូវការសុទ្ធសាធ។ ប៉ុន្តែ សំណួរទាំងនេះអាចមានសារៈសំខាន់ផងដែរ។ ពាក់ព័ន្ធនឹងសំណួរថា នៅពេលណា ផលប្រយោជន៍ខ្ពស់របស់ភាគីក្នុងការឱ្យមានការចរចាជាបន្ទាន់ អាចចង្អុលបង្ហាញកម្រិតមួយនៃតម្រូវការ ឬសេចក្តីអស់សង្ឃឹម។ ឬភាគីនោះអាចមានការភ័យខ្លាចថា វិវាទនោះនឹងត្រូវបើកចំហរជាសាធារណៈដែលអាចបង្កមហន្តរាយធ្ងន់ធ្ងរដល់ខ្លួនបាន។

- **នៅកន្លែងណា**

សំណួរ នៅកន្លែងណា និង របៀបណា មានលក្ខណៈកាន់តែល្អិតល្អន់នៅក្នុងសារៈសំខាន់របស់វា។ ប្រសិនបើការចរចាត្រូវបានធ្វើឡើងនៅឯការិយាល័យមេធាវីរបស់អ្នក នោះអ្នកនឹងមានប្រៀបខាងទីតាំង។ អ្នកអាចមានអារម្មណ៍ងាយស្រួលជាងភាគីម្ខាងទៀត ដែលអាចមានអារម្មណ៍មិនសុខស្រួល នៅក្នុងបរិយាកាសដែលខ្លួនមិនធ្លាប់ស្គាល់។ លើសពីនេះទៅទៀត នៅក្នុងវប្បធម៌មួយចំនួន គេអាចចាត់ថាភាគីជាភ្ញៀវមានតម្រូវការជាងក្នុងការព្រមព្រៀងដោះស្រាយ ពីព្រោះពួកគេសុខចិត្តធ្វើដំណើរមកជួប។ ដោយសារមូលហេតុនេះ ជួនកាលការចរចាត្រូវបានធ្វើឡើងនៅកន្លែងអព្យាក្រឹត្ត ដូចជាការិយាល័យគណៈមេធាវី មជ្ឈមណ្ឌលតុលាការ ឬមជ្ឈមណ្ឌលសម្រុះសម្រួលឯកជន។

- **ដោយរបៀបណា**

សំណួរ របៀបណា ពាក់ព័ន្ធទៅនឹងដំណើរការចរចាផ្ទាល់។ តើភាគីទាំងពីរគួរផ្ញើអ៊ីម៉ែលឱ្យគ្នាដែរឬទេ? តើពួកគេគួរចរចាតាមទូរសព្ទដែរ ឬទេ? តើពួកគេត្រូវចរចាទល់មុខគ្នាផ្ទាល់ដែរឬទេ? ប្រសិនបើជួបផ្ទាល់ តើកូនក្តីត្រូវមានវត្តមាននៅពេលចរចាដែរឬទេ? ប្រសិនបើកូនក្តីរបស់អ្នកជាអ្នកមានប្រាក់ច្រើនជាង ជាមនុស្សដែលពោរពេញទៅដោយភាពជឿជាក់ពីធម្មជាតិនោះ ការចរចាទុលមុខគ្នាជាមួយកូនក្តីទាំងពីរអាចមានប្រយោជន៍។ ឬកូនក្តីរបស់អ្នកអាចមានលទ្ធភាពផ្តល់ព័ត៌មានដល់អ្នក ពាក់ព័ន្ធនឹងអង្គហេតុដែលមានសារៈសំខាន់ នៅក្នុងអំឡុងពេលចរចា។ ឬអាចថា ពីដំបូងមកកូនក្តីរបស់អ្នកអាចមានការរំពឹងទុកចំពោះដំណោះស្រាយដែលមិនប្រាកដនិយម ហើយការស្តាប់រឿងរ៉ាវរបស់ភាគីម្ខាងទៀតអាចជួយបន្ធូរបន្ថយការរំពឹងទុកទាំងនោះបាន។

### ៣.ដំណាក់កាលបញ្ចប់

នៅពេលដែលមានការព្រមព្រៀងនៅក្នុងអំឡុងពេលចរចាហើយ ត្រូវធានាថាលក្ខខ័ណ្ឌព្រមព្រៀងទាំងនោះត្រូវបានសរសេរចូលជាលាយលក្ខណ៍អក្សរភ្លាមៗ។ ការចងចាំរបស់មនុស្សតែងរលត់ទៅ ហើយប្រសិនបើភាគីចរចាពន្យាពេលដោយគ្រាន់តែចង់ចាំអំពីល័ក្ខខ័ណ្ឌនៃការព្រមព្រៀងនោះ ក្រោយមកទៀតពួកគេអាចមិនឯកភាពទៅលើល័ក្ខខ័ណ្ឌជាក់លាក់ណាមួយ នៅពេលដែលពួកគេព្យាយាមសរសេរវាចូល។ ម៉្យាងវិញទៀត ប្រសិនបើភាគីមានពេលវេលាច្រើនជ្រុលពេកនោះ ពួកគេអាចពិចារណាឡើងវិញនូវសម្បទានរបស់ខ្លួន

ហើយនឹងព្យាយាមចរចាឡើងវិញ ដើម្បីទទួលបានល័ក្ខខ័ណ្ឌកាន់តែប្រសើរជាងមុន។ ដើម្បីជៀសវាងបញ្ហានេះ ភាគីចរចាត្រូវត្រៀមខ្លួនជានិច្ចក្នុងការសរសេរចូលនូវល័ក្ខខ័ណ្ឌជាមូលដ្ឋាននៃកិច្ចព្រមព្រៀង និងចុះហត្ថលេខា ហើយបន្ទាប់មក ប្រហែលជាត្រូវសរសេរល័ក្ខខ័ណ្ឌជាស្ថាពរអោយបានឆាប់បន្ទាប់ពីនោះ ពោលគឺ នៅពេលដែលមេធាវីទាំងអស់មានលទ្ធភាពប្រើប្រាស់ទម្រង់ច្បាប់សមស្រប។

ជាងនេះទៅទៀត ប្រការដែលសំខាន់ គឺអ្នកមិនត្រូវប្រើក្រសែភ្នែកថាខ្លួនឈ្នះ ឬនិយាយពាក្យពេចន៍ដូចជា ( វាបែរជាល្អសម្រាប់ខ្ញុំ ជាងអ្វីដែលខ្ញុំបានគិតទៅទៀត ) ។ ការណ៍នេះអាចបង្កើតអារម្មណ៍មិនល្អ រវាងភាគីទៅវិញទៅមកហើយអាចឈានទៅដល់ការរំលាយកិច្ចព្រមព្រៀងនោះវិញក៏ថាបាន។

**កថាភាគទី៣៖ គុណសម្បត្តិ និងគុណវិបត្តិនៃការចរចា**

**១.គុណសម្បត្តិ**

- សន្សំសំចៃការចំណាយ៖ ការចរចាចំណាយអស់ប្រាក់តិចជាងវិធីសាស្ត្រដោះស្រាយវិវាទផ្សេងទៀត ។ នេះគឺជា ចំណែកមួយដែលនាំឱ្យការធរមាមានប្រជាប្រិយភាព ។ វាមិនមានប្រាក់ប្រដាប់ក្តី ឬថ្លៃចំណាយផ្សេងទៀតឡើយ ។
- ភាពឯកជន៖ ការចរចាអាចជាដំណើរការឯកជនទាំងស្រុង ដោយគ្រាន់តែធ្វើឡើងរវាងភាគី និងភាគី ឬតំណាង របស់ពួកគេតែប៉ុណ្ណោះ ។ គ្មានការចូលរួមពីតុលាការ គ្មានអ្នកសារព័ត៌មាន និងគ្មានអ្នកដទៃទៀតចូលរួមទេ
- ភាពបត់បែន៖ ការធរមាមានភាពបត់បែនក្នុងដំណើរការ និង លទ្ធផល ។ ភាពបត់បែនក្នុងដំណើរការមានន័យថា ការចរចអាចធ្វើឡើងដោយផ្ទាល់មាត់ ឬសរសេរជាលាយល័ក្ខអក្សរ ។ ឯភាពបត់បែនក្នុងលទ្ធផល គឺភាគីវិវាទផ្ទាល់ ដែលជាអ្នកឈានដល់ការស្រុះស្រួលរវាងគ្នា ដែលភាគីមិនអាចធ្វើបាននៅក្នុងការដោះស្រាយនៅមជ្ឈត្តការ ឬតុលាការឡើយ ។
- លឿន៖ ការចរចាមានសក្តានុពលក្នុងការដោះស្រាយបញ្ហាបានយ៉ាងឆាប់រហ័ស នឹងមានប្រសិទ្ធភាព។ ភាគីមីន ចាំបាច់ត្រូវរងចាំចៅក្រម មជ្ឈត្តករ ឬសទ្ធានការិ ដើម្បីធ្វើសវនការ និងម្រេចលើរឿងក្តីនោះឡើយ។ បញ្ហាអាច ត្រូវបានដោះស្រាយភ្លាមៗឱ្យតែភាគីឈានដល់ការស្រុះស្រួលគ្នា។
- លទ្ធផលគ្រប់គ្រងដោយភាគី៖ ការមរផ្តល់ឱ្យភាគីវិវាទនូវលទ្ធភាពគ្រប់គ្រងយ៉ាងពេញលេញទៅលើដំណើរការ និងការបញ្ចប់។ ភាគីវិវាទជាអ្នកកំណត់ថាតើត្រូវធ្វើការចរចាតាមរបៀបណា នឹងថាតើនឹងមានការស្រុះស្រួល ដែរឬទេ ? ក្នុងការចរចាតមិនបង្ខំភាគីណាមួយឱ្យចូលក្នុងដំណើរការចរចា ឬការស្រុះស្រួលណាមួយ ដោយគ្មាន ការព្រមព្រៀងពីគូភាគីនោះទេ ។

- ការរក្សាទំនាក់ទំនងបន្តះ ការចរចាផ្តល់លទ្ធភាពដល់ភាគីវិវាទក្នុងការរិះរកការស្រុះស្រួលណាមួយ ដែលអាច រក្សាទំនាក់ទំនងនេះបានដែលពួកគេធ្លាប់មានពីមុនមក។
- ការអនុវត្តដំណោះស្រាយនីតិវិធីតុលាការ នៅចំពោះមុខចៅក្រម ហើយនឹងអាចអនុវត្តបានដូចជាសាលក្រមដែរ[87]។

**២.គុណវិបត្តិ**

- ការពន្យាពេលៈ ភាគីម្ខាងអាចពន្យាពេលដំណើរការបើសិនជាខ្លួនចង់ ។ នៅក្នុងស្ថានភាពចរចាសុទ្ធសាធមួយ គ្មានវិធីអ្វីអាចបង្ខំភាគីណាមួយឱ្យពន្លឿនសកម្មភាពបានឡើយ។ វាជាលទ្ធភាពមួយដែលថាភាគីល្មើស អាចមិនទាំងប្រាកដប្រជាអំពីការស្រុះស្រួលផង ហើយប្រើប្រាស់ការចរចាមានវិធីសម្រាប់ពន្យាពេលបញ្ហា ឬ គេចវេសពីបណ្តឹងតុលាការ ។
- ការអនុវត្តដំណោះស្រាយៈ បន្ទាប់ពីការចរចារួម ភាគីអាចឯកភាពគ្នាលើកិច្ចព្រមព្រៀងស្រុះស្រួលមួយ ដែលត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងមានចុះហត្ថលេខា។ ប៉ុន្តែមួយរយៈក្រោយមកភាគីណាមួយអាចមិនគោរព តាមល័ក្ខខ័ណ្ឌនៃការស្រុះស្រួល។ ដោយសារតែការស្រុះស្រួលនោះ គ្រាន់តែជាកិច្ចព្រមព្រៀងតាមរយៈការចរចា ភាគីម្ខាងទៀតគ្មាលើវិធីដោយផ្ទាល់ក្នុងការដាក់ឱ្យអនុវត្តតាមផ្លូវតុលាការឡើយ ។ ជាលទ្ធផល ភាគីនោះអាចនៅតែ ត្រូវដាក់ពាក្យប្តឹងទៅតុលាការ ហើយត្រូវរង់ចាំក្នុងរយៈពេលយូរ ដើម្បីអនុវត្តកិច្ចព្រមព្រៀងស្រុះស្រួលខាងដើម នោះ ។
- ភាគីម្ខាងមានអំណាចខ្លាំងពេកៈ មានកាលៈទេសៈមួយចំនួនដែលភាគីមានវិសមភាពនឹងគ្នានៅក្នុងអំណាចចរចា ជាហេតុនាំឱ្យភាគីម្ខាងមានសិទ្ធិត្រួតត្រាហួសពេក[88]។

## ផ្នែកទី២ៈ សន្ធានកម្ម (ការសម្រុះសម្រួល)

### កថាភាគទី១ៈនិយមន័យនៃសន្ធានកម្ម

សន្ធានកម្ម អាចត្រូវបានផ្តល់និយមន័យយ៉ាងទូលំទូលាយថា ជាការចរចាដែលមានជំនួយ ឬការជួយសម្របសម្រួល[89]។ ជាទូទៅ សន្ធានកម្មត្រូវមានភាគីវិវាទពីរ ឬច្រើន ដែលព្យាយាមចរចាលើដំណោះស្រាយមួយដោយមានជំនួយពីភាគីទី៣ គឺសន្ធានការី ដែលមានអព្យាក្រឹតភាពចំពោះភាគីទាំងនោះ ក៏ដូចជា

[87] សៀវភៅដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មេធាវី ស្ទីវិន អ៊ែម អូស្ទើមឺឡឺរ៍ (បោះពុម្ពលើកទី២ ខែមករា ឆ្នាំ២០១០)។

[88] សៀវភៅដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មេធាវី ស្ទីវិន អ៊ែម អូស្ទើមឺឡឺរ៍ (បោះពុម្ពលើកទី២ ខែមករា ឆ្នាំ២០១០)។

[89] Paterson, et al. កំណត់សម្គាល់ខាងលើលេខ៩ នៅទំព័រ៥៣ ។ សន្ធានកម្មក៏ត្រូវបានកំណត់ឱ្យនិយមន័យផងដែរ ថាជាដំណើរការដែលនៅក្នុងនោះ អ្នកធ្វើអន្តរាគមន៍មិនលម្អៀងម្នាក់ជួយភាគីចរចាពីរ ឬច្រើន ឱ្យកំណត់ពីបញ្ហាកង្វល់ ហើយបន្ទាប់មកបង្កើតនូវសំណើនានា ដែលអាចទទួលយកបានទៅវិញទៅមក ដើម្បីដោះស្រាយកង្វល់ទាំងនោះ។ ALFINI ET AL.ទ្រឹស្តី និងការអនុវត្តសន្ធានកម្ម (បោះពុម្ពលើកទី១ ដោយ Matthew Bender ឆ្នាំ ២០០១)

លទ្ធផលនៃដំណោះស្រាយនោះផ្ទាល់។ សន្ធានការីមិនមានអំណាចចាប់បង្ខំឱ្យយកដំណោះស្រាយណាមួយឡើយ។ ផ្ទុយទៅវិញភាគីវិវាទនៅតែមានសិទ្ធិអំណាចក្នុងការសម្រេចថាតើខ្លួនចង់ ឬមិនចង់ដោះស្រាយ។ ប្រសិនបើភាគីវិវាទមិនចង់ដោះស្រាយ ឬមិនមានការព្រមព្រៀងគ្នា នោះនឹងគ្មានដំណោះស្រាយឡើយ ទោះជាមានការខិតខំប្រឹងប្រែងរបស់សន្ធានការីយ៉ាងណាក៏ដោយ។ មិនដូចក្នុងមជ្ឈត្តការ ឬបណ្ដឹងទៅតុលាការឡើយ សន្ធានការីគ្រាន់តែអាចស្នើរឡើងនូវដំណោះស្រាយចំពោះភាគីតែប៉ុណ្ណោះ។

ពាក្យថាសន្ធានកម្ម ឬ ការសម្រុះសម្រួល (mediation) និងពាក្យថាការផ្សះផ្សា (conciliation) ត្រូវបានប្រើលាយឡំគ្នាអស់រយៈពេលជាច្រើនឆ្នាំមកហើយ ដោយមជ្ឈដ្ឋានអ្នកសិក្សា ក៏ដូចជាអ្នកប្រកបវិជ្ជាជីវៈផ្នែកច្បាប់ និងតុលាការជាដើម។ សព្វថ្ងៃនេះ ពាក្យថា សន្ធានកម្ម និង ផ្សះផ្សា ជាញឹកញាប់ ត្រូវបានប្រើប្រាស់ជំនួសគ្នាទៅវិញទៅមក ដើម្បីសំដៅដល់ដំណើរការតែមួយ។ ទោះបីជាមានអ្នកខ្លះព្យាយាមគូសបង្ហាញពីភាពខុសគ្នារបស់វាក៏ដោយ ក៏មិនមានអាជ្ញាធរច្បាប់អន្តរជាតិណាមួយកំណត់ថា តើពាក្យទាំងពីរអាចមានភាពខុសគ្នាយ៉ាងដូចម្ដេចឡើយ[90]។

ពាក្យទាំងពីរនេះសំដៅដល់ដំណើរការចរចា ដែលមានភាគីទីបីដែលអព្យាក្រឹតជួយសម្របសម្រួល។ នៅក្នុងប្រទេសខុសគ្នា ប្រពៃណីខុសគ្នា ដំណើរការ ឬកម្រិតនៃការចូលរួមពីសំណាក់ភាគីអព្យាក្រឹតមានភាពដោយឡែកពីគ្នាយ៉ាងខ្លាំង នៅក្នុងប្រពៃណីខ្លះ ភាគីអព្យាក្រឹតមានសេរីភាពក្នុងការជម្រុញការស្រុះស្រួលដោយសកម្ម តាមរយៈកិច្ចប្រជុំជាឯកជនជាមួយភាគីវិវាទ (ដែលគេហៅថា កិច្ចប្រជុំដោះស្រាយ និងតាមរយៈការស្នើរនូវដំណោះស្រាយជាក់លាក់នានា)[91]។

---

[90] នៅប្រទេសអូស្ត្រាលី ក្រុមប្រឹក្សាយោបល់ជាតិស្ដីពីដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ National Alternative Dispute Resolution Advisory Council (NADRAC) បានគូសបញ្ជាក់ថា មានការច្រឡំគ្នាគួរឱ្យកត់សម្គាល់ ទាំងនៅក្នុងប្រទេស អូស្ត្រាលី និងនៅបណ្ដាប្រទេសផ្សេងទៀត ពាក់ព័ន្ធនឹងពាក្យទាំងពីរនេះ។ សូមមើលជាទូទៅ ឯកសារពិភាក្សាអំពីបច្ចេកស័ព្ទរបស់ NADRAC មាននៅ http://www.nadrac.gov.au/agd/www/Disputeresolutionhom.nsf/Page/RWP7E251CA71B8E7700CA256BD100135550? OpenDocument (ចូលទស្សនាលើកចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨) ។

[91] មានអាជ្ញាធរប្រទេសខ្លះឱ្យនិយមន័យពាក្យផ្សះផ្សា ថាជាដំណើរការ ដែលនៅក្នុងនោះភាគីអព្យាក្រឹតដើរតួនាទីស្នើរដំណោះស្រាយកាន់តែសកម្ម ចំណែកឯពាក្យសន្ធានកម្ម ត្រូវបានកំណត់ថាជាដំណើរការដែលនៅក្នុងនោះភាគីអព្យាក្រឹតមានតួនាទីគ្រាន់តែជួយសម្រួល និងកាន់តែអកម្ម។ សូមមើលពាក្យដំណោះស្រាយវិវាទ ក្រុមប្រឹក្សាយោបល់ជាតិ ស្ដីពីដំណោះស្រាយវិវាទក្រៅផ្លូវតុលាការ(អូស្ត្រាលី) នៅទំព័រ៣ (ឆ្នាំ២០០៣) មាននៅ http://1.1.1.1/467929504/472002888T080531121212.txt.binXMysM0dapplication/pdfXsysM0dhttp://wwwnadrac.gov.au/agd/WWW/rwpattach.nsf/VAP/(CFD7369FCAE9B8F32F341DBE097801FF)-1 Report8 6Dec.pdf/$file/1Report8_6Dec.pdf (ចូលទស្សនាលើកចុងក្រោយ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៣ ។

**កថាភាគទី២៖ ដំណើរការសន្ធានកម្ម**

ការសិក្សានានាបានបង្ហាញថានីតិវិធីសន្ធានកម្ម គឺជាកត្តាចម្បងសម្រាប់ភាពជោគជ័យនៃសន្ធានកម្ម។ ប្រសិនបើភាគីយល់ឃើញថាដំណើរការនោះមានភាពយុត្តិធម៌ ពួកគេអាចនឹងចង់ដោះស្រាយ។ នៅពេលដែលភាគីបង្កើតវិធាននីតិវិធីដោយខ្លួនឯង អត្រានៃការព្រមព្រៀងនឹងរឹតតែខ្ពស់ថែមទៀត[92]។ ដោយការចង់ចាំទុកនូវចំណុចនេះដំណាក់កាលខាងក្រោមនេះនឹងត្រូវពិនិត្យមើលឡើងវិញឱ្យកាន់តែលម្អិត។

**១.ការចាប់ផ្តើមសន្ធានកម្ម**

ដំណាក់កាលដំបូងបំផុតនៅក្នុងសន្ធានកម្មនីមួយៗ គឺជាការផ្តួចផ្តើមសន្ធានកម្ម។ ដូចគ្នានឹងដំណើរការ ADR ភាគច្រើនដទៃទៀតដែរ សន្ធានកម្មតែងកើតឡើង ប្រសិនបើមានកាលៈទេសៈណាមួយក្នុងចំណោមបីខាងក្រោមកើតឡើងៈ

១. ភាគីមាន ខស្តីពីដំណោះស្រាយវិវាទ នៅក្នុងកិច្ចសន្យាដែលមានស្រាប់របស់ពួកគេ ដែលបានជ្រើសរើសយក មធ្យោបាយសន្ធានកម្មមកប្រើ។

២. ភាគីសម្រេចចិត្តធ្វើសន្ធានកម្ម បន្ទាប់ពីវិវាទបានកើតឡើង ឬ

៣. តុលាការបានបង្គាប់ ឬណែនាំឱ្យភាគីធ្វើសន្ធានកម្ម។

នៅក្នុងកាលៈទេសៈទី១ និងទី២ ភាគីដែលផ្តួចផ្តើមសន្ធានកម្មផ្ញើរលិខិតអញ្ជើញជាលាយលក្ខណ៍អក្សរដើម្បីសម្រុះសម្រួលវិវាទនោះ។ លិខិតអញ្ជើញអាចដាក់បញ្ចូលនូវការស្នើរឡើងអំពីទីតាំង និងវិធានសម្រាប់សន្ធានកម្មនោះ។ ភាគីម្ខាងទៀតអាចយល់ព្រមតាមការអញ្ជើញ ឬបដិសេធ។ ប្រសិនបើភាគីម្ខាងទៀតយល់ព្រម នោះភាគីទាំងពីរត្រូវចាប់ផ្តើមកំណត់វិធាន និងស្វែងរកសន្ធានការី។ ប្រសិនបើភាគីម្ខាងទៀតបដិសេធ សន្ធានកម្មនឹងមិនកើតមានឡើយ ហើយភាគីអាចអនុវត្តវិធីផ្សេងទៀត។ ប្រសិនបើភាគីមានខស្តីពីសន្ធានកម្មនៅក្នុងកិច្ចសន្យាពីមុនមក ហើយភាគីម្ខាងបដិសេធន៍មិនធ្វើសន្ធានកម្ម នោះភាគីម្ខាងទៀតអាចស្វែងរកសេចក្តីបង្គាប់ពីតុលាការដែលតម្រូវឱ្យធ្វើសន្ធានកម្ម។ សេចក្តីបង្គាប់របស់តុលាការបែបនេះនឹងតម្រូវឱ្យភាគី ចូលរួម នៅក្នុងសន្ធានកម្ម ប៉ុន្តែមិនអាចបង្គាប់ឱ្យភាគីត្រូវតែយល់ព្រមដោះស្រាយនៅក្នុងសន្ធានកម្មនោះឡើយ។

យោងតាមវិធានស្តីពីការផ្សះផ្សារបស់ UNCITRAL (បោះពុម្ពឡើងវិញនៅក្នុងឧបសម្ព័ន្ធ ក)[93] ប្រសើបើភាគីដែលផ្តួចផ្តើមផ្សះផ្សាមិនទទួលបានចម្លើយតបក្នុងរយៈពេល៣០ថ្ងៃ ចាប់ពីថ្ងៃផ្ញើរលិខិតអញ្ជើញនោះ ឬក្នុងរ

[92] Douglas Henderson ភាពជោគជ័យនៃការសម្របសម្រួលៈ ការវិភាគដែលសំអាងលើការពិសោធន៍. ទិនា.ដំ.វិ.រដ្ឋអូហាយូ លេខ១១ ទំព័រ១៥០ (ឆ្នាំ១៩៩៦) Allred ភាពសកម្មនៃទំនាក់ទំនងក្នុងវិវាទ សៀវភៅណែនាំអំពីដំណោះស្រាយវិវាទ នៅទំព័រ៨៣. ៩១ (Michael L. Moffitt,Robert C.Bordone ed., ឆ្នាំ២០០៥

[93] វិធានផ្សះផ្សា UNCITRAL កំណត់សម្គាល់ខាងលើ លេខ១៣៦ នៅមាត្រា២ (៤)។

យៈពេលមួយដែលមានចែងនៅក្នុងលិខិតអញ្ជើញនោះ ភាគីនោះអាចចាត់ទុកថា ភាគីម្ខាងទៀតបដិសេធន៍ចំពោះការអញ្ជើញឱ្យមកផ្សះផ្សានោះ។ ប្រសិនបើភាគីនោះចាត់ទុកថាដូច្នេះ ភាគីនោះត្រូវជូនដំណឹងដល់ភាគីម្ខាងទៀត។

ប្រសិនបើតុលាការបានបង្គាប់ឱ្យមានសន្ធានកម្មដែលពាក់ព័ន្ធនឹងកម្មវិធីសន្ធានកម្មចំណុះឱ្យស្ថាប័នតុលាការ នោះតុលាការទំនងជានឹងផ្តល់ដល់ភាគីនូវសន្ធានការី និងវិធានអនុវត្តន៍ផងដែរ។

**២.ការជ្រើសរើសសន្ធានការី**

បន្ទាប់ពីសន្ធានកម្មត្រូវបានបង្កើតឡើងជាយន្តការដោះស្រាយវិវាទរួចមក ភាគីវិវាទត្រូវតែជ្រើសរើសយកសន្ធានការីមួយរូប។ ប្រសិនបើភាគីមិនបានចាត់តាំងមជ្ឈមណ្ឌលសន្ធានកម្មជាក់លាក់ណាមួយនោះទេ ពួកគេអាចជ្រើសរើសអ្នកណាម្នាក់ក៏បានដែលខ្លួនចូលចិត្ត និងតាមរបៀបណាមួយដែលចូលចិត្ត។ ប្រសិន បើពួកគេយល់ព្រមប្រើប្រាស់មជ្ឈមណ្ឌលសន្ធានកម្មជាក់លាក់ណាមួយនោះ ដូចជាមជ្ឈមណ្ឌលសន្ធានកម្មនៃប្រទេសសិង្ហបុរី វិធានរបស់មជ្ឈមណ្ឌល់នោះនឹងកំណត់ថាតើមានសន្ធានការីណាខ្លះដែលអាចធ្វើបាន ព្រមទាំងរបៀបជ្រើសរើសពួកគេផងដែរ។

សន្ធានកម្មជាច្រើនតម្រូវឱ្យមានអ្នកសម្រុះសម្រួលម្នាក់។ យ៉ាងណាមិញ គេក៏អាចធ្វើសន្ធានកម្មដែលមានសន្ធនការីពីរនាក់ ឬរហូតដល់បីនាក់ក៏បាន។ លើកលែងតែមានមូលហេតុច្បាស់លាស់ក្នុងការធ្វើបែបនេះ ការណែនាំជាទូទៅគឺគេគួរធ្វើវាជាមួយសន្ធានការីតែម្នាក់។ មជ្ឈមណ្ឌលសន្ធានកម្មទំនងជានឹងផ្តល់នូវបញ្ជីសន្ធានការីសក្តានុភូតដល់ភាគី ឬប្រសិនបើពួកគេមិនយល់ព្រម ឬមិនចង់សម្រេចចិត្តមជ្ឈមណ្ឌលក៏អាចតែងតាំងសន្ធានការីម្នាក់ សម្រាប់រឿងក្តីនោះផងដែរ។

ខាងក្រោមនេះគឺជាបញ្ជីបញ្ហាដើម្បីពិចារណា នៅពេលជ្រើសរើសសន្ធានការី។ តើសន្ធានការីនោះ៖

- មានអព្យាក្រឹតពេញលេញ និងគ្មានទំនាក់ទំនងជាមួយភាគីណាមួយ មែនឬទេ?
- មានចំណេះដឹងអំពីបញ្ហាដែលជាកម្មវត្ថុនៃវិវាទ (ឧទាហរណ៍ ដូចជា ស្តង់ដា និងវិធាននៃឧស្សាហកម្មសាងសង់អាគារ ) ដែរឬទេ?
- មានបទពិសោធន៍នៅក្នុងសន្ធានកម្មដែរឬទេ?
- ជាមេធាវី ចៅក្រម ឬជាអ្នកដែលគ្មានចំណេះដឹងខាងច្បាប់?
- ជាមន្ត្រីរដ្ឋាភិបាល?
- មានភាពលំអៀងនៅក្នុងផ្លូវណាមួយ ដូចជាគាំទ្រនិយោជិត ឬស្អប់ជនបរទេស ដែរឬទេ?
- ត្រូវបានណែនាំដោយភាគីដទៃទៀតដែរឬទេ?

- មានតម្លៃថ្លៃដែរឬទេ?
- ជាអ្នកស្តាប់ក៏ល្អដែរឬទេ?
- ពូកែបណ្តុះបណ្តាលដែរឬទេ?

**៣.ការបើកកិច្ចប្រជុំ**

នៅពេលភាគីបានផ្តល់ដល់អ្នកសម្របសម្រួលនូវព័ត៌មានផ្សេងៗមុនពេលសន្ធានកម្ម ហើយសន្ធានកម្មត្រូវបានកំណត់កាលវិភាគរួចរាល់ហើយ ដំណាក់កាលបន្ទាប់គឺជាការបើកកិច្ចប្រជុំ។ នៅពេលបើកកិច្ចប្រជុំ ភាគីវិវាទត្រូវជួបជាមួយសន្ធានការីដោយផ្ទាល់។ នៅក្នុងរឿងក្តីដែលសាមញ្ញ ឬតូចតាច ភាគីវិវាទអាចចូលរួមដោយមិនបាច់មានមេធាវី ហើយដំណើរការនោះមានលក្ខណៈក្រៅផ្លូវការជាង។ នៅក្នុងរឿងក្តីដែលស្មុគស្មាញ ភាគីវិវាទនឹងចូលរួមដោយមានវត្តមានមេធាវីរបស់ខ្លួន។

ជាទូទៅសន្ធានការីច្រើនតែជួបជាមួយភាគីទាំងពីរព្រមគ្នា ដើម្បីសន្សំសំចៃពេលវេលា និងកាត់បន្ថយអារម្មណ៍សង្ស័យ ឬភាពលំអៀងនៅពេលចាប់ផ្តើម។នឹងមិនមានការកត់ត្រានៅក្នុងសម័យប្រជុំទេ ហើយអ្នកខាងក្រៅក៏មិនត្រូវបានអនុញ្ញាតឱ្យចូលរួមដែរ។ ការបើកកិច្ចប្រជុំនេះមានគោលបំណងដូចខាងក្រោម៖

- ណែនាំអ្នកចូលរួមឱ្យស្គាល់គ្នា
- ពិភាក្សា និងពិនិត្យមើលឡើងវិញនូវដំណើរការសន្ធានកម្ម
- កំណត់អំពីវិធានដែលត្រូវអនុវត្តតាម
- ផ្តល់ពេលវេលាឱ្យភាគីនីមួយៗរៀបរាប់អំពីវិវាទ និងជំហរអង្គច្បាប់ និងអង្គហេតុរបស់ពួកគេ
- ផ្លាស់ប្តូព័ត៌មានសំខាន់ៗ គ្នាទៅវិញទៅមករវាងភាគីវិវាទ
- ផ្តល់ដល់ភាគីនូវឱកាសបង្ហាញពីអារម្មណ៍ និងផលប្រយោជន៍របស់ខ្លួន និង
- កំណត់ផ្នែកដំបូងនៃការព្រមព្រៀង និងមិនព្រមព្រៀង

សន្ធានការីតែងចាប់ផ្តើមដោយណែនាំអ្នកចូលរួមឱ្យស្គាល់គ្នាទៅវិញទៅមក។ បន្ទាប់មក សន្ធានការីនោះនឹងពិនិត្យមើលឡើងវិញនូវដំណើរការ និងវិធានសម្រាប់កិច្ចប្រជុំ។ មានពេលខ្លះសន្ធានការីនឹងព្យាយាមពន្យល់អំពីតួនាទីរបស់ខ្លួននៅក្នុងដំណើរការនោះ ដើម្បីឱ្យភាគីនីមួយៗមានការរំពឹងទុកដូចៗ គ្នា។ នៅពេលអំពីវិធាននៃកិច្ចប្រជុំសន្ធានការីត្រូវពន្យល់រឿងលម្អិតដូចជា ភាគីនីមួយៗត្រូវបន្តចូលរួមរហូតដល់កិច្ចប្រជុំនោះត្រូវបានបញ្ចប់ ហើយភាគីត្រូវស្តាប់នឹងមិនត្រូវនិយាយកាត់គេឡើយ។ ប្រសិនបើភាគីវិវាទឯកភាព សន្ធានការីនឹងត្រូវដឹកនាំការប្រជុំជាឯកជនជាមួយភាគីនីមួយៗ ដើម្បីជួយសម្រួលឱ្យមានដំណោះស្រាយ។ សន្ធានការីនឹងមិនមានការព្រមព្រៀងដោយបង្ខំឡើយ ហើយភាគីនីមួយៗត្រូវរក្សាការសម្ងាត់ ព្រមទាំងត្រូវបញ្ជាក់ថាភាគីនីមួយៗត្រូវបានតំណាងដោយអ្នកណាម្នាក់ដែលមានសិទ្ធិអំណាចពេញលេញដើម្បីដោះស្រាយ។ ទីបញ្ចប់ សន្ធានការី

នឹងឆ្លើយសំណួរដែលភាគីនីមួយៗមាន ពាក់ព័ន្ធនឹងដំណើរការសន្ទានកម្មទាំងមូល។ ប្រសិនបើសន្ទានកម្មត្រូវបានធ្វើឡើងនៅមជ្ឈមណ្ឌលដែលមានស្រាប់ វិធាននានាអាចមានជាលាយលក្ខណ៍អក្សររួចជាស្រេចសម្រាប់ភាគីវិវាទ។ ជាទូទៅ សន្ទានការី នឹងអនុញ្ញាតឱ្យមានការផ្លាស់ប្តូរខ្លះៗនៅក្នុងវិធានទាំងនោះ ប្រសិនបើភាគីយល់ព្រម។

បន្ទាប់ពីមានការពន្យល់បែបបទទាំងនោះរួច សន្ទានការីនឹងអញ្ជើញភាគីនីមួយៗឱ្យបញ្ចេញមតិបើកកិច្ចប្រជុំរបស់ខ្លួន។ នៅក្នុងមតិបើកកិច្ចប្រជុំនោះ ភាគីនឹងបង្ហាញពីដំណើររឿងដែលខ្លួនយល់ឃើញដោយបញ្ជាក់អំពីភស្តុតាង និងច្បាប់ផងដែរ។ នេះជាឱកាសសម្រាប់ភាគីនីមួយៗក្នុងការបញ្ចេញមតិយោបល់ខ្លួន ព្រមទាំងអាចប្រាប់ដល់ភាគីម្ខាងទៀតអំពីជំហររបស់ខ្លួន។

ភាគីនីមួយៗអាចបង្ហាញអំពីផលប្រយោជន៍របស់ខ្លួន។ ជាការល្អបំផុតនោះ គឺមិនត្រូវទាមទារអ្វីពីភាគីម្ខាងទៀត ក្នុងពេលថ្លែងបើកកិច្ចប្រជុំឡើយ។ ពោលគឺ ជាទូទៅ ភាគីនោះបានស្តាប់រឿងរ៉ាវទាំងមូលចេញពីទស្សនៈរបស់ភាគីម្ខាងទៀតជាលើកដំបូង។ មេធាវីរបស់ភាគីនីមួយៗគួរតែជាអ្នកឡើងបញ្ចេញមតិបើកកិច្ចប្រជុំ ដើម្បីធានាការឆ្លងឆ្លើយព័ត៌មានត្រូវបានធ្វើឡើងតាមរបៀបមួយដែលច្បាស់លាស់ មានប្រសិទ្ធិភាព និងមិនមានចរិកចោទប្រកាន់។

ក្រោយពីភាគីទីមួយបានបញ្ចប់សេចក្តីថ្លែងខ្លួនហើយ សន្ទានការីអាចសួរសំណួរខ្លះដើម្បីបំភ្លឺបញ្ហាមួយចំនួនផងដែរ។ ប្រសិនបើសន្ទានការីបានទទួលសេចក្តីផ្សេងៗ ដែលភាគីបានដាក់ជូនមុនពេលធ្វើសន្ទានកម្មរួចហើយ សន្ទានការីមិនចាំបាច់សួរសំណួរច្រើនពេកឡើយ។ បន្ទាប់ពីសំណួរទាំងនោះត្រូវបានឆ្លើយតបរួច ភាគីម្ខាងទៀតនឹងថ្លែងមតិបើកកិច្ចប្រជុំ ក្នុងលក្ខខណ្ឌដូចគ្នានឹងអ្នកទីមួយដែរ។ ជាទូទៅ សន្ទានការីនឹងធ្វើការកត់ត្រាយ៉ាងលម្អិតក្នុងអំឡុងពេលនោះ ដើម្បីធានាថាខ្លួនយល់បានទាំងស្រុងអំពីសេចក្តីវិវាទ ក៏ដូចជាអារម្មណ៍ និងផលប្រយោជន៍របស់ភាគីដែលមាននៅចំពោះមុខ។ នៅពេលភាគីទាំងអស់មានឱកាស ក្នុងបង្ហាញជំហររបស់ខ្លួនរួចហើយ ជាទូទៅសន្ទានការីនឹងសុំឱ្យមានការសម្រាករយៈពេលខ្លី[94]។

**៤.ការបញ្ចប់សន្ទានកម្ម**

សន្ទានកម្មនឹងបញ្ចប់ ដោយមានលទ្ធផលមួយក្នុងចំណោមលទ្ធផលដែលអាចមានចំនួនបីដូចខាងក្រោម៖

១. ភាគីបានឈានដល់ការព្រមព្រៀងគ្នាទាំងស្រុង។

២. ភាគីមិនបានឈានដល់ការព្រមព្រៀងគ្នាទាំងស្រុង ប៉ុន្តែនឹងបន្តសន្ទានកម្មនៅពេលក្រោយ ឬ

[94] សៀវភៅដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មេធាវី ស៊ីវិន អ៊ែម អូស្ទើមីឡឺរ៍ (បោះពុម្ពលើកទី២ ខែមករា ឆ្នាំ២០១០)។

៣. ភាគីបានឈានដល់ស្ថានភាពជាប់គាំង [95] ហើយសន្ធានកម្មត្រូវបានបញ្ចប់។

នៅក្នុងករណីទីមួយ សន្ធានការីនឹងលើកទឹកចិត្តឱ្យភាគីធ្វើពង្រាង និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងដោះស្រាយមួយ។ ការពន្យាក្នុងការធ្វើពង្រាង និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងដោះស្រាយនៅថ្ងៃក្រោយ គឺជាការប្រថុយប្រថាន ពីព្រោះភាគីអាចពិចារណាឡើងវិញអំពីការស្រុះស្រួលរបស់ខ្លួន។ ពួកគេអាចទទួលរងសម្ពាធពីគ្រួសារ មិត្តភក្តិ ឬមិត្តរួមការងារ ឱ្យបន្តទាមទារផលប្រយោជន៍កាន់តែច្រើនជាងនោះ។ ជាលទ្ធផលពួកគេអាចព្យាយាមទាមទារនូវសម្បទានចុងក្រោយពីភាគីម្ខាងទៀត និងអាចនឹងបំផ្លាញកិច្ចព្រមព្រៀងនោះតែម្តង។

ភាគីខ្លួនឯងគួរជាអ្នកធ្វើពង្រាងកិច្ចព្រមព្រៀងនោះ។ ប្រសិនបើសន្ធានការីធ្វើពង្រាងកិច្ចព្រមព្រៀង គាត់អាចប្រថុយជាមួយនឹងការលម្អៀងទៅភាគីម្ខាង ឬភាគីម្ខាងទៀត ដោយសារតែពាក្យពេចន៍ដែលគាត់ជ្រើសរើស។ យកល្អសន្ធានការីគួរសរសេរចូលនូវចំណុចជាមូលដ្ឋាននៃកិច្ចព្រមព្រៀងនៅចុងបញ្ចប់សម័យប្រជុំ ឱ្យភាគីចុះហត្ថលេខាលើនោះ ហើយទុកពេលវេលាដល់ភាគីឱ្យធ្វើពង្រាងកិច្ចព្រមព្រៀងទាំងមូលដោយខ្លួនឯង។ សន្ធានការីអាចពិនិត្យកិច្ចព្រមព្រៀងនោះបាន ប៉ុន្តែទោះជាយ៉ាងនេះក្តី គាត់ត្រូវមានការប្រុងប្រយ័ត្នចំពោះការជួយភាគីម្ខាងច្រើនជាងភាគីម្ខាងទៀត។ វាជាស្ថានភាពដែលរសើបបំផុត នៅពេលភាគីពីរដែលមានជម្លោះនឹងគ្នា បែរជាស្រុះស្រួលគ្នា ហើយព្យាយាមរំលឹកពីកិច្ចព្រមព្រៀងរបស់ពួកគេ។ អាស្រ័យហេតុនេះ សន្ធានការីត្រូវប្រុងប្រយ័ត្នថែមទៀត ដើម្បីធានាថាខ្លួនមិនធ្វើអ្វីឱ្យប៉ះទង្គិចដល់តុល្យភាពនោះឡើយ។

ប្រសិនបើលទ្ធផលទីពីរកើតឡើង ( ត្រូវសម្រុះសម្រួលបន្ថែមទៀតនាពេលក្រោយ ) សន្ធានការីត្រូវសង្កត់ធ្ងន់លើការរីកចម្រើនដែលបានបង្កើតឡើង និងផ្តល់សំណើរមួយចំនួនសម្រាប់ការពិចារណាសម្រាប់កិច្ចប្រជុំលើកក្រោយ។ កិច្ចប្រជុំបន្ទាប់ត្រូវកំណត់កាលបរិច្ឆេទឱ្យបានឆាប់ ដើម្បីជួយរក្សាភាពជឿនលឿនដែលទទួលបាននៅក្នុងកិច្ចប្រជុំមុន។

លទ្ធផលទីបីអាចកើតឡើងនៅគ្រប់ពេលទាំងអស់។ ភាគីណាម្ខាងអាចបញ្ចប់កិច្ចប្រជុំសម្រុះសម្រួលកាន់តែឆាប់ប្រសិនបើពួកគេខឹង ឬមិនមានឆន្ទៈក្នុងការបន្តការពិភាក្សាតទៅទៀត។ សន្ធានការីមិនអាចធ្វើអ្វីបានទាំងអស់ប្រសិនបើភាគីណាមួយបដិសេធយ៉ាងដាច់អហង្ការក្នុងពិភាក្សាដំណោះស្រាយតទៅទៀត។ សន្ធានការីក៏អាចជ្រើសរើសយកការបញ្ចប់កិច្ចប្រជុំផងដែរ ប្រសិនបើមិនមានការព្រមព្រៀងណាមួយអាចកើតឡើងបាន។ ទោះបីជាសន្ធានកម្មគឺជាមធ្យោបាយដ៏ប្រសើរបំផុតសម្រាប់ដោះស្រាយ ក៏ទីបំផុតវាអាស្រ័យតែទៅលើភាគីវិវាទខ្លួនឯង ហើយវិវាទមួយចំនួនក៏មិនអាចយកមកសម្រុះសម្រួលដោយជោគជ័យដែរ។ នៅពេលសន្ធានកម្មត្រូវបាន

[95] ជួនកាលពាក្យនេះត្រូវបានគេហៅថា (ភាពទ័លច្រក)។

បញ្ចប់បែបនេះ ភាគីមានសេរីភាពក្នុងការបន្តវិវាទរបស់ពួកគេនៅក្នុងវេទិកាផ្សេងទៀត ដូចជាមជ្ឈត្តការ ការចរចាជាឯកជន ព្រមទាំងបណ្តឹងទៅតុលាការ។

**កថាភាគទី៣៖ គុណសម្បត្តិ និងគុណវិបត្តិនៃសន្ធានកម្ម**

**១.គុណសម្បត្តិ**

- **ល្បឿន**

សន្ធានកម្មអនុញ្ញាឱ្យភាគីដោះស្រាយវិវាទលំបាកៗក្នុងរយៈពេលខ្លី ជាទូទៅ គឺក្នុងរយៈពេលមួយថ្ងៃ ឬតិចជាងនេះ។ បណ្តឹងទៅតុលាការ ឬមជ្ឈត្តការអាចប្រើរយៈពេលអស់ជាច្រើនខែ ឬច្រើនឆ្នាំ។ ការចរចាក៏មានសក្តានុពលក្នុងការដោះស្រាយបញ្ហាបានឆាប់រហ័សដែរ ប៉ុន្តែដោយសារតែវាច្រើនតែឡើងដោយគ្មានពេលកំណត់ ឬភាពបន្ទាន់ វាក៏អាចអូសបន្លាយពេលឱ្យយូរបានដែរ។ ផ្ទុយទៅវិញ សន្ធានកម្មជាទូទៅ គឺជាព្រឹត្តិការណ៍តែមួយដែលកើតឡើងក្នុងរយៈពេលខ្លី ទើបវាអាចដោះស្រាយបញ្ហាបានឆាប់រហ័ស។

- **ការចំណាយ**

ស្របពេលដែលការចរចាជាឯកជន តែងតែជាបច្ចេកទេសដោះស្រាយវិវាទដែលមានតម្លៃថោកជាងគេបំផុតនោះការចំណាយសម្រាប់សន្ធានកម្មក៏ច្រើនតែមានតម្លៃទាបជាងជម្រើសដទៃទៀតដូចជា បណ្តឹងទៅតុលាការ ឬមជ្ឈត្តការដែរ។ ជាទូទៅសន្ធានកម្មមានរយៈពេលមួយ ឬពីរថ្ងៃ ដូច្នេះថ្លៃសោហ៊ុយមេធាវី និងថ្លៃឈ្នួលមជ្ឈមណ្ឌលសន្ធានកម្មក៏មានតម្លៃទាបតាមនោះដែរ។ ចំពោះវិវាទសាមញ្ញៗ សន្ធានកម្មដែលធ្វើឡើងដោយមិត្តភក្តិ ឬសាច់ញាតិ ក៏អាចមិនអស់ថ្លៃអ្វីទាំងអស់ ដូចជាការចរចាដូច្នេះដែរ។

- **ការគ្រប់គ្រងរបស់ភាគីចំពោះលទ្ធផល**

ជាមួយសន្ធានកម្ម ភាគីនៅតែជាអ្នកគ្រប់គ្រងលើលទ្ធផលដដែល។ ភាគីអាចសម្រេចថាតើនឹងមានដំណោះស្រាយ ដែរឬទេ និងនៅក្នុងលក្ខខណ្ឌអ្វីខ្លះ។ ភាគីធ្វើការកំណត់ផងដែរ ថាតើដំណើរនោះជាកាបង្ខិនពេលវេលាដែរឬទេ ហើយគួរតែបញ្ចប់ ឬយ៉ាងណា។ គ្មានអ្នកណាម្នាក់អាចបង្ខំភាគីសន្ធានកម្មឱ្យធ្វើអ្វីមួយនោះទេ។

- **ការរក្សាសម្ព័ន្ធភាពជាបន្ត**

ដូចជាការចរចាដែរ សន្ធានកម្មអនុញ្ញាតឱ្យភាគីអាចរៀបចំដំណោះស្រាយមួយ ដែលអាចរក្សាសម្ព័ន្ធភាពរបស់របស់ពួកគេជាបន្តទៅទៀត។ ប្រកាសនេះមានសារៈសំខាន់ណាស់សម្រាប់សង្គមខ្មែរ ពីព្រោះទំនាក់ទំនងផ្ទាល់ខ្លួនគឺជាកត្តាចាំបាច់សម្រាប់កិច្ចជំនួញ នយោបាយ និងសកម្មភាពក្នុងវិស័យដទៃទៀត។

- **ភាពឯកជន**

ដំណើរការសន្ទានកម្មតម្រូវឱ្យមានរក្សាការសម្ងាត់។ យុត្តាធិការជាច្រើនផ្តល់ការការពារដល់ព័ត៌មានដែលពាក់ព័ន្ធនៅនឹងការចរចា ឬសន្ទានកម្ម ទោះបីជាវាមិនបណ្តាលឱ្យមានការព្រមព្រៀង ហើយវិវាទនោះត្រូវតែបន្តការប្តឹងផ្តល់ក៏ដោយ។ ឧទាហរណ៍ ច្បាប់ស្តីពីការផ្សះផ្សារបស់ UNCITRAL ចែងដូចខាងក្រោម[96]៖

មាត្រា៩ ការរក្សាការសម្ងាត់

លើកលែងតែមានការព្រមព្រៀងផ្ទុយពីនេះដោយភាគីវិវាទ ព័ត៌មានទាំងអស់ដែលពាក់ព័ន្ធទៅនឹងដំណើរការផ្សះផ្សាត្រូវរក្សាជាការសម្ងាត់ លុះណាតែច្បាប់តម្រូវឱ្យធ្វើការផ្សព្វផ្សាយ សម្រាប់គោលដៅអនុវត្ត និងដាក់ឱ្យអនុវត្តនូវកិច្ចព្រមព្រៀងស្រុះស្រួល។

- **លទ្ធភាពបទបែន**

ភាគីវិវាទមានលទ្ធភាពបទបែនជាច្រើនក្នុងការរៀបចំដំណើរការសន្ទានកម្ម។ សន្ទានការីមានតួនាទីជួយសម្របសម្រួលភាគី និងលើកទឹកចិត្តពួកគេ។ សន្ទានការីមានតួនាទីកាន់តែសកម្ម ដោយជួបប្រជុំជាមួយភាគីនីមួយៗដោយឡែកពីគ្នា ដើម្បីស្វែងយល់ផលប្រយោជន៍និងគោលជំហររបស់ពួកគេ ហើយទីបំផុតថែមទាំងអាចស្នើរឡើងនូវដំណោះស្រាយដែលអាចមានទៀតផង។

- **ការអនុវត្តដំណោះស្រាយ**

ដូចបានរៀបរាប់ខាងលើ ជាទូទៅកិច្ចព្រមព្រៀងដែលកើតពីសន្ទានកម្មដែលចំណុះឱ្យស្ថាប័នតុលាការអាចយកមកអនុវត្តដូចសាលក្រមតុលាការដែរ ដែលមានន័យថាវាជាដំណើរការអនុវត្តឆាប់រហ័ស[97]។ នៅប្រទេសកម្ពុជា ដំណោះស្រាយដែលកើតចេញពីសន្ទានកម្មជាឯកជន ដែលធ្វើឡើងនៅវេទិការមជ្ឈត្តកម្មណាមួយគួរតែទទួលសិទ្ធិអនុវត្តយ៉ាងឆាប់រហ័សបែបនេះ។ នេះគឺជាអត្ថប្រយោជន៍ដ៏ធំធេងជាងដំណោះស្រាយតាមរយៈការចរចា ដែលមិនទទួលបាននូវសិទ្ធិអនុវត្តឆាប់រហ័សឡើយ។

- **ឱកាសខ្ពស់នៃការព្រមព្រៀង**

កម្មវិធីសន្ទានកម្មជាច្រើនរាយការណ៍ថាមានអត្រាព្រមព្រៀងខ្ពស់។ ផ្អែកលើតួលេខទាំងនេះ សន្ទានកម្មប្រហែលជាមានភាពជោគជ័យក្នុងការសម្រេចបានការព្រមព្រៀងជាងការចរចា។ សន្ទានកម្មជោគជ័យជាងការចរចាដោយសារមូលហេតុមួយចំនួន។ ទី១ នៅក្នុងសន្ទានកម្មភាគីវិវាទមានឱកាស

[96] ច្បាប់ផ្សះផ្សា UNCITRAL. កំណត់សម្គាល់ ខាងលើ លេខ៨៧.មាត្រា៩។

[97] សូមមើល,ឧទា.Betty Southard Murphy ផលប៉ះពាល់នៃដំណោះស្រាយវិវាទក្រៅតុលាការទៅលើពាណិជ្ជកម្មអន្តរជាតិ.ទិនានុ. ដំណោះ.វិ លេខ៤៨. ទំព័រ៦៨,៧៣ (ឆ្នាំ១៩៩៣) (សំដៅដល់អត្រានៃការអនុវត្តតាមចំនួន៩០ភាគរយ)។
មគ្គុទេសក៏ ADR, កំណត់សម្គាល់ ខាងលើ លេខ១០៥, ឧបសម្ព័ន្ធ, ករណីសិក្សាលើប្រទេសស្រីលង្កា, ករណីសិក្សាលើប្រទេសអាហ្វ្រិកខាងត្បូង។

ពិសេសក្នុងការជួប និងស្តាប់រឿងរ៉ាវរបស់ភាគីម្ខាងទៀតនៅក្នុងក្របខណ្ឌក្រៅផ្លូវការ។ ទី២ ការចរចាតាមរយៈមេធាវីអាចមានហានិភ័យដែលថាព័ត៌មាននឹងត្រូវបំប្លែងឬយល់ខុស នៅពេលវាត្រូវបានបញ្ជូលពីភាគី (ក) ទៅមេធាវីរបស់ភាគី (ក) នោះបន្ទាប់មក គឺមេធាវីរបស់ភាគី (ខ) ទៅភាគី(ខ) ផ្ទាល់។ ទី៣ ការចរចាច្រើនតែធ្វើឱ្យជម្លោះបុគ្គលិកលក្ខណៈរបស់មេធាវីចរចាពីររូប កាន់តែមានភាពធ្ងន់ធ្ងរឡើង ចំណែកឯសន្ទានកម្មវិញអនុញ្ញាតឱ្យភាគីអព្យាក្រឹតដោះស្រាយបញ្ហាទាំងនោះ។ ទី៤ ក្នុងករណីមានការសង្ស័យគ្នាទៅវិញទៅមក សំណើរដោះស្រាយដែលលើកឡើងដោយសន្ទានការី អាចត្រូវបានទទួលយកដោយប្រាកដប្រជា និងគ្មានការសង្ស័យ ជាងសំណើរដែលលើកឡើងដោយមេធាវីបដិបក្ខរបស់ភាគីមួយ។

- **ថ្ងៃឡើងតុលាការ របស់ភាគីវិវាទ**

ជួនកាល វាជារឿងសំខាន់សម្រាប់ភាគីមួយ ក្នុងការមានឱកាសប្រាប់ភាគីម្ខាងទៀតអំពីរឿងរ៉ាវរបស់ខ្លួន និងមានអារម្មណ៍ដូចជាខ្លួនត្រូវបានគេស្តាប់។ នៅក្នុងប្រទេសមួយចំនួនចំនុចនេះត្រូវបានគេហៅថាជាការមាន (ថ្ងៃឡើងតុលាការ)។ ជាធម្មតា ការចរចាមិនផ្តល់ឱកាសដែលរៀបចំឱ្យហេតុការណ៍នេះកើតឡើងឡើយ។

- **ជៀសវាងអំពើពុករលួយ**

លក្ខណៈស្ម័គ្រចិត្តនៃដំណោះស្រាយតាមសន្ទានកម្ម ធ្វើឱ្យអ្នកចូលរួមមិនសូវរងគ្រោះនឹងអំពើពុករលួយទេ[98]។ សន្ទានការីមិនអាចទាមទារប្រាក់កម្រៃក្រៅផ្លូវការឡើយដោយសារខ្លួនមិនមាន ការគ្រប់គ្រង ឬសិទ្ធិអំណាចលើភាគីវិវាទឡើយ។

- **ការជ្រើសរើសភាគីអព្យាក្រឹត**

នៅក្នុងកិច្ចប្រជុំសន្ទានកម្ម ភាគីវិវាទតែងជ្រើសរើសភាគីអព្យាក្រឹតរបស់ខ្លួន ពោលគឺខុសពីដំណើរការបណ្តឹងទៅតុលាការ ដែលចៅក្រមត្រូវបានចាត់តាំងឡើង។ ការជ្រើសរើសនេះអាចជួយឱ្យភាគីមានអារម្មណ៍ជឿជាក់ថាសន្ទានការីមិនមានភាពលម្អៀង[99]។

**២. គុណវិបត្តិ**

- **ភាគីដែលគ្មានហេតុផល**

---

[98] Austermiller កំណត់សម្គាល់ ខាងលើ លេខ៨៥ នៅទំព័រ១៤២ សម្គាល់លេខ៨០។ សន្ទនការីដែលពុករលួយនៅតែអាចព្យាយាមបង្ខំឱ្យភាគីព្រមព្រៀង តាមរយៈឧបាយកលដោះស្រាយខ្លួន ឬការបង្ខិតបង្ខំ។

[99] សៀវភៅដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មេធាវី ស៊ីវិន អ៊ែម អូស្ទើរមីឡឺរ៍ (បោះពុម្ពលើកទី២ ខែមករា ឆ្នាំ២០១០)។

គ្មានភាគីណាមួយនៅក្នុងសន្ទានកម្មត្រូវបានបង្ខំឱ្យព្រមព្រៀងលើអ្វីមួយឡើយ។ ចំណុចនេះ ជាគុណសម្បត្តិផង និងជាគុណវិបត្តិផង។ ប្រសិនបើភាគីម្ខាងគ្មានហេតុផល ហើយមិនចង់ដោះស្រាយនោះ គ្មានអ្វីដែលសន្ទានការីអាចធ្វើបានឡើយ។ សន្ទានកម្មអាចបំផ្លាញពេលវេលា និងលុយកាក់ឥតប្រយោជន៍ ប្រសិនបើភាគីទាំងពីគ្មានហេតុផល និងគ្មានឆន្ទៈក្នុងការដោះស្រាយ។

- **អំណាចចរចាមិនស្មើភាពគ្នា**

ប្រសិនបើភាគីមានអំណាចមិនស្មើភាពគ្នា សន្ទានកម្មអាចមានគ្រោះថ្នាក់សម្រាប់ភាគីដែលខ្សោយជាង។ ឧទាហរណ៍ ក្រុមហ៊ុនធំមួយអាចមានអំណាចចរចាខ្លាំងជាង បើប្រៀបធៀបជាមួយហាងទំនិញជាលក្ខណៈគ្រួសារដ៏តូចមួយ។ ប្រសិនបើភាគីទាំងពីរធ្វើសន្ទានកម្ម ក្រុមហ៊ុនធំអាចគំរាមកំហែង ភាគីដែលទន់ខ្សោយជាងឱ្យព្រមព្រៀងលើដំណោះស្រាយដែលអយុត្តិធម៌។

- **ការអនុវត្តដំណោះស្រាយ**

អាស្រ័យទៅតាមយុត្តាធិការនីមួយៗ ដំណោះស្រាយតាមរយៈសន្ទានកម្មជាឯកជនខ្លះអាច មិនមានវិធានការអនុវត្តឆាប់រហ័ស។ ហេតុនេះ ភាគីត្រូវពិចារណាលើយុត្តាធិការកន្លែងដែលខ្លួនចុះកិច្ចសន្យាដើម្បីធានាថាពួកគេយល់អំពីវិធានការអនុវត្តន៍នៅទីនោះ។ ប្រសិនបើពួកគេស្ថិតនៅក្នុងយុត្តាធិការមួយដែលមិនផ្តល់នូវវិធានការអនុវត្តន៍ឆាប់រហ័ស សម្រាប់ដំណោះស្រាយតាមការសម្រុះសម្រួលជាឯកជន ដូចជានៅប្រទេសអូស្ត្រាលីជាដើមនោះ សន្ទានកម្មអាចមានភាពទាក់ទាញកាន់តែតិច។

- **ការចំណាយ**

សន្ទានកម្មអាចមិនអស់ប្រាក់ ប្រសិនបើសន្ទានការីគឺជាសមាជិកគ្រួសារ ឬជាមិត្តភក្តិរបស់ភាគីទាំងពីរ។ ប៉ុន្តែប្រសិនបើវិវាទកើតឡើងក្នុងចំណោមអ្នកមិនមែនជាសាច់ញាតិ ឬក្រុមហ៊ុន ជាទូទៅសន្ទានការីគឺជាភាគីអព្យាក្រឹតដែលយកថ្លៃឈ្នួល។ ភាគីអាចមិនទាន់ចង់ចំណាយប្រាក់សម្រាប់សន្ទានកម្ម តែអាចសាកល្បងចរចាគ្នាជាមុនសិន ដើម្បីពិនិត្យមើលថាអាចមានដំណោះស្រាយដោយមិនចាំបាច់ចំណាយលើអ្នកខាងក្រៅឬទេ[100]។

- **ភាពជាឯកជន**

ទោះជាការប្រាស្រ័យទាក់ទងគ្នារវាងភាគីវិវាទ ពាក់ព័ន្ធនឹងសន្ទានកម្មត្រូវបានរក្សាជាការសម្ងាត់តាមច្បាប់ក្តី យុត្តាធិការមួយចំនួនដូចជាប្រទេសកម្ពុជាជាដើម មិនមានច្បាប់សន្ទានកម្ម ដែលការពារជា

[100] ទោះបីជាការចរចាអាចមានរយៈពេលវែង ដែលអាចចំណាយប្រាក់ច្រើនសម្រាប់កម្រៃមេធាវីក្តី។

ពិសេសដល់ការប្រាស្រ័យទាក់ទងគ្នាពាក់ព័ន្ធនឹងសន្ធានកម្មនៅឡើយទេ។ អាស្រ័យហេតុនេះ ភាគីមិនអាចធានាបាននូវភាពជាឯកជនមួយរយភាគរយឡើយ[101]។

## ផ្នែកទី៣៖ មជ្ឈត្តការ

### កថាភាគទី១៖ និយមន័យនៃមជ្ឈត្តការ

មជ្ឈត្តការ គឺជាវិធីសាស្ត្រដោះស្រាយក្រៅប្រព័ន្ធតុលាការចម្បងទីបី។ នៅក្នុងមជ្ឈត្តការ គូភាគីដាក់វិវាទរបស់ខ្លួនជូនទៅភាគីទីបីដែលអព្យាក្រឹតមួយ (ដែលជាទូទៅហៅថា «មជ្ឈត្តករ» ឬប្រសិនបើច្រើនជាងម្នាក់ ហៅថា «ក្រុមមជ្ឈត្តករ» ឬ «វេទិកាមជ្ឈត្តកម្ម»)។

ក្នុងខណៈដែលវេទិកាភាគច្រើនខាងលើផ្តោតលើដំណោះ ស្រាយវិវាទផ្នែកពាណិជ្ជកម្ម ជាសំខាន់ គេត្រូវយល់ថា មជ្ឈត្តការក៏អាចអនុវត្តចំពោះវិស័យផ្សេងទៀតនៃច្បាប់ផងដែរ។ នៅក្នុងប្រទេសជាច្រើន វិវាទការងារក៏ត្រូវបាន ដោះស្រាយមជ្ឈត្តការដែរ ក្នុងពេលបច្ចុប្បន្ន។ កិច្ចព្រមព្រៀងអនុសញ្ញារួមតែងតែមានខ្សែចងស្តីពីមជ្ឈត្តការដែលទាមទារ ឱ្យគូភាគីបញ្ជូនវិវាទទៅធ្វើមជ្ឈត្តការ ។ កីឡាអាជីពជាច្រើន ប្រើប្រាស់មជ្ឈត្តការដើម្បីដោះស្រាយបញ្ហាប្រាក់បៀវត្សរ៍។ សូម្បីតែកីឡាអូឡាំពិកក៏បានប្រើប្រាស់មជ្ឈត្តការដើម្បីដោះស្រាយវិវាទដែរ។" កិច្ចសន្យាសាងសង់រវាងអ្នកសាងសង់ និងម្ចាស់សំណង់ តែងតែមានខចែងស្តីពីមជ្ឈត្តការ។ លើសពីនេះទៀត ខចែងស្តីពីមជ្ឈត្តការក៏ក្លាយជាបទដ្ឋានមួយនៅក្នុងកិច្ចសន្យាធានា កិច្ចសន្យាព្រមព្រៀងកម្មសិទ្ធិបញ្ញា និងកិច្ចសន្យាលក់សម្រាប់អ្នកប្រើប្រាស់ជាច្រើនប្រភេទ[102]។

### កថាភាគទី២៖ ដំណើរការមជ្ឈត្តការ

#### ១.ការផ្តួចផ្តើមដំណើរការមជ្ឈត្តការ

មជ្ឈត្តការអាចផ្តួចផ្តើមឡើងតាមវិធីបីយ៉ាងគឺ:

- ការស្នើសុំឱ្យធ្វើមជ្ឈត្តការស្របតាមកិច្ចព្រមព្រៀងស្តីពីមជ្ឈត្តការដែលមានស្រាប់
- ការព្រមព្រៀងធ្វើឱ្យមជ្ឈត្តការនៅពេលវិវាទកើតឡើង និង
- មជ្ឈត្តការដែលត្រូវអនុវត្តតាមបង្គាប់របស់តុលាការ។

វិធីទី១ក្នុងចំណោមវិធីទាំងបី ពោលគឺការស្នើសុំឱ្យធ្វើមជ្ឈត្តការស្របតាមកិច្ចព្រមព្រៀងមជ្ឈត្តការដែលមានស្រាប់ ត្រូវបានអនុវត្តជាទូទៅបំផុត។

[101] សៀវភៅដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មេធាវី ស៊ីវិន អ៊ែម អូស្ទើរមីឡឺរ៍ (បោះពុម្ពលើកទី២ ខែមករា ឆ្នាំ២០១០)។

[102] សៀវភៅដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មេធាវី ស៊ីវិន អ៊ែម អូស្ទើរមីឡឺរ៍ (បោះពុម្ពលើកទី២ ខែមករា ឆ្នាំ២០១០)។

### ១.១ ការដាក់ពាក្យរបស់ភាគីប្តឹងទាមទារ

#### ក.ការដាក់សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម

ភាគីអ្នកប្តឹងទាមទារដែលមានមានបំណងចង់ដាក់វិវាទរបស់ខ្លួនដើម្បីធ្វើការដោះស្រាយវិវាទតាមមជ្ឈត្តការ ត្រូវធ្វើការជូនដំណឹងទៅអគ្គលេខាធិការដ្ឋាននៃមជ្ឈមណ្ឌលនូវសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម។ ក្រៅពីភាសា ដែលត្រូវបានប្រើក្នុងដំណើរការមជ្ឈត្តការ សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មត្រូវធ្វើជាភាសាសម្រាប់មជ្ឈត្តកម្ម និងត្រូវបកប្រែជាភាសាខ្មែរ ឬជាភាសាអង់គ្លេស[103]។ ការជូនដំណឹងអំពីមជ្ឈត្តកម្ម ត្រូវមានភ្ជាប់មកជាមួយនូវការបង់ប្រាក់សម្រាប់កម្រៃសេវាចុះបញ្ជីដែលអាចជាមូលប្បទានប័ត្រ ឬការផ្ទេរចូលគណនីធនាគារកំណត់ណាមួយ របស់ ម.ជ.ម.។ ទម្រង់នៃសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មដោយត្រូវមានភ្ជាប់នូវព័ត៌មានដូចខាងក្រោម[104]៖

- សេចក្តីថ្លែងដែលបញ្ជាក់ថាភាគីដាក់វាឱ្យដោះស្រាយតាមរយៈការធ្វើមជ្ឈត្តកម្ម
- ឈ្មោះ អាស័យដ្ឋាន, លេខទូរស័ព្ទលេខទូរសារ និងអាស័យដ្ឋានសារអេឡិចត្រូនិច ហើយ ប្រសិនមានព័ត៌មានរបស់គូភាគីវិវាទ និងរបស់អ្នកតំណាង ប្រសិនបើមាន
- សញ្ជាតិ ឬប្រសិនបើតម្រូវ និងមានព៌ត៌មានអំពីអត្តសញ្ញាណរបស់ក្រុមហ៊ុនរបស់គូភាគីវិវាទ
- សេចក្តីយោងនៃខចែងស្តីអំពីមជ្ឈត្តកម្ម ឬកិច្ចសន្យាមជ្ឈត្តកម្មដោយឡែកដែលយកមករ៉ី និងភ្ជាប់សំណៅចម្លងនៃខចែងស្តីអំពីមជ្ឈត្តកម្ម ឬកិច្ចសន្យាមជ្ឈត្តកម្មដោយឡែកនោះ
- សេចក្តីយោងនៃកិច្ចសន្យា ឬទំនាក់ទំនងផ្សេងៗដែលកើតចេញពីវិវាទ ឬដែលទាក់ទងនិងវិវាទ ព្រមទាំងភ្ជាប់នូវសំណៅចម្លងនៃកិច្ចសន្យាទាំងនោះផងដែរប្រសិនបើអាច សេចក្តីថ្លែងសង្ខេបដែលពិពណ៌នាអំពីលក្ខណៈនៃវិវាទ និងកាលៈទេសៈនៃវិវាទ ការទាមទារ ឬការសង្គ្រោះដែលទាមទារ និងបើអាចភ្ជាប់នូវតម្លៃបឋមនៃការទាមទារដែលភាគីប្តឹងទាមទារ មានបំណងដាក់ស្នើ
- ចំនួនមជ្ឈត្តករដែលបានព្រមព្រៀង ឬក្នុងករណីដែឡមិនបានព្រមព្រៀងទេនោះ ចំនួនមជ្ឈត្តករ ដែលត្រូវស្នើសុំអាចមានចំនួន ១រូប ឬ៣រូប
- សេចក្តីថ្លែង ឬសំណើបន្ថែមផ្សេងៗ ពាក់ព័ន្ធនឹងដំណើរការមជ្ឈត្តការ រួមបញ្ចូលទាំងច្បាប់ដែល ត្រូវយកមកអនុវត្ត ភាសាសម្រាប់ដំណើការមជ្ឈត្តការ និងលក្ខណៈសម្បត្តិនិងសញ្ជាតិរបស់ មជ្ឈត្តករដែលបានព្រមព្រៀង ឬដែលចង់បានប្រសិនបើមាន។

---

[103] វិធានស្តីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ ៣៣ ។

[104] វិធានស្តីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ ៧ ។

ក្នុងករណីភាគីវិវាទជាអ្នកប្ដឹងបានដាក់សេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម ប៉ុន្តែមានលក្ខណៈមិនពេញលេញ អគ្គលេខាធិការដ្ឋាននៃ ម.ជ.ម. អាចស្នើសុំឱ្យភាគីប្ដឹងទាមទារបំពេញបន្ថែមនូវចំណុចខ្វះខាតទាំងនោះក្នុងកំឡុងពេលសមស្របណាមួយ។ នៅពេលដែលសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្មត្រូវបានបំពេញចប់សព្វគ្រប់ហើយសេចក្ដីជូនដំណឹងនោះត្រូវបានចាត់ទុកថាបានដាក់ក្នុងថ្ងៃដែលអគ្គលេខាធិការដ្ឋានបានទទួលនូវសំណៅឯកសារដំបូង។ អគ្គលេខាធិការដ្ឋានត្រូវជូនដំណឹងទៅភាគីវិវាទ បន្ទាប់ពីបានទទួលសេចក្ដីជូនដំណឹងពេញលេញអំពើ មជ្ឈត្តកម្ម[105]។

**ខ. សេចក្តីថ្លែងទាមទារ**

សេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្មអាចត្រូវបានភ្ជាប់មកជាមួយនូវសេចក្ដីថ្លែងទាមទារមកជាមួយផងដែរ ដោយភ្ជាប់ជាមួយនឹងសេចក្ដីលម្អិតដូចខាងក្រោម[106]៖

ក. អង្គហេតុដែលគាំទ្រការទាមទារនោះ

ខ. មូលដ្ឋានច្បាប់ ឬទឡ្ហីករណ៍តាមផ្លូវច្បាប់ដែលគាំទ្រការទាមទារនោះ

គ.សំណងការខូចខាត ឬការសង្គ្រោះដែលទាមទារ ឬចំនួនទឹកប្រាក់នៃការទាមទារដែលអាចកំណត់បានទាំងអស់។

ឃ. សេចក្ដីថ្លែងដោះសារចំពោះបណ្ដឹងតប

ប្រសិនបើមានបណ្ដឹងតបត្រូវបានធ្វើឡើង ភាគីប្ដឹងទាមទារត្រូវបញ្ជូនសេចក្ដីថ្លែងដោះសារចំពោះបងតបនោះក្នុងកំឡុងពេល ៣០ថ្ងៃប្រតិទិនបន្ទាប់ពីបានទទួលសេចក្ដីថ្លែងដោះសាររបស់ភាគីអ្នកឆ្លើយតប។ ក្នុងសេចក្ដីថ្លែងដោះសារចំពោះបណ្ដឹងតបត្រូវបំពេញនូវលក្ខខណ្ឌដូចគ្នាទៅនឹងសេចក្ដីថ្លែងដោះសាររបស់ខាងភាគីអ្នកឆ្លើយតបដែរ[107]។

**១.២. ការដាក់ពាក្យប្តឹងរបស់គូភាគីឆ្លើយតប**

នៅពេលភាគីអ្នកប្ដឹងទាមទារបានដាក់ពាក្យបណ្ដឹងរួច តាគីឆ្លើយតបត្រូវមកដាក់ពាក្យបណ្ដឹងរបស់ខ្លួនដូចគ្នាដែរ។ ភាគីឆ្លើយតបត្រូវធ្វើពាក្យដោះសាររបស់ខ្លួនដែលឆ្លើយតបទៅនឹងចំណុចដែលភាគីអ្នកប្ដឹង ព្រមទាំងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ និងបណ្ដឹងតបដែលខ្លួនមានផង។

[105] វិធានស្ដីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ ៧ ។

[106] វិធានស្ដីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ៣៧ ។

[107] វិធានស្ដីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ ៣៧ ។

ក្នុងរយៈពេល ១៥ថ្ងៃនៃប្រតិទិនបន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងអំពីមជ្ឈត្តករួចមក ភាគីឆ្លើយតប ត្រូវបញ្ជូនសេចក្តីជូនដំណឹងអំពីការឆ្លើយតបរបស់ខ្លួនទៅកាន់អគ្គលេខាធិការដ្ឋាននៃ ម.ជ.ម.[108]។ ក្រៅពីភាសាដែលត្រូវបានប្រើក្នុងដំណើរការមជ្ឈត្តការហើយ សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មត្រូវធ្វើជាភាសាសម្រាប់មជ្ឈត្តកម្ម ត្រូវបកប្រែជាភាសាខ្មែរ ឬជាភាសាអង់គ្លេស។ សេចក្តីជូនដំណឹងអំពីការឆ្លើយតបរបស់ភាគីឆ្លើយតបត្រូវមានបញ្ជាក់នូវព័ត៌មានមួយចំនួនរួមមានដូចខាងក្រោម[109]៖

- ឈ្មោះ អាស័យដ្ឋាន លេខទូរស័ព្ទ លេខទូរសារ និងអាស័យដ្ឋានសារអេឡិចត្រូនិច ហើយប្រសិនបើមានព័ត៌មានរបស់គូភាគីវិវាទ និងរបស់អ្នកតំណាង ប្រសិនបើមាន និងប្រសិនបើមានព័ត៌មាន ដែលខុសពីព័ត៌មានដែលមានក្នុងសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម
- សញ្ជាតិ ឬប្រសិនបើអាចគឺតម្រូវឱ្យមានអត្តសញ្ញាណរបស់ក្រុមហ៊ុនរបស់ភាគីវិវាទ និងប្រសិនបើ មានព័ត៌មានដែលខុសពីព័ត៌មានដែលមានក្នុងសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម
- ការបញ្ជាក់សង្ខេបអំពីការទទួលយក ឬការបដិសេធចំពោះការទាមទារទាំងស្រុងឬដោយផ្នែក
- សេចក្តីថ្លែងសង្ខេបដែលពិពណ៌នាអំពីលក្ខណៈ និងកាលៈទេសៈនៃបណ្តឹងតប និងប្រសិនបើអាច ត្រូវភ្ជាប់តម្លៃបឋមនៃបណ្តឹងតប ឬការដោះសារតាមការកាត់តែងនោះ
- ចំនួនមជ្ឈត្តករដែលបានព្រមព្រៀង ឬក្នុងករណីដែលមិនបានព្រមព្រៀងចំនួនមជ្ឈត្តករដែលត្រូវស្នើ ប្រសិនបើមានសេចក្តីថ្លែងការ ឬសំណើបន្ថែមផ្សេងៗដែលពាក់ព័ន្ធនឹងដំណើរការមជ្ឈត្តការរួមទាំង ច្បាប់ដែលត្រូវអនុវត្ត ភាសាសម្រាប់ដំណើរការមជ្ឈត្តការ លក្ខណៈសម្បត្តិរបស់មជ្ឈត្តករ និងសញ្ជាតិ របស់មជ្ឈត្តករដែលតម្រូវ ឬដែលជាការឆ្លើយតបចំពោះសេចក្តីថ្លែង ឬសំណើរនានាដែលមានក្នុង សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម។

ក្នុងករណីដែលសេចក្តីជូនដំណឹងអំពីមជ្ឈកម្មដែលមានភ្ជាប់មកនូវជាមួយសេចក្តីថ្លែងព្រមទាមទារខាងភាគីអ្នកឆ្លើយតបអាចត្រូវមានភ្ជាប់មកនូវជាមួយផងដែរនូវសេចក្តីថ្លែងដោះសារដែលអាចជាបណ្តឹងតប ឬការដោះសារតាមការកាត់កង និងទឡ្ហីករណ៍ចំពោះយុត្តាធិការរបស់វេទិការមជ្ឈត្តកម្ម។ សេចក្តីថ្លែងដោះសាររបស់ភាគីឆ្លើយតប ត្រូវមានបញ្ជាក់សេចក្តីលម្អិតមួយចំនួនដូចខាងក្រោម[110]៖

ក អង្គហេតុ និងអំណះអំណាងតាមផ្លូវច្បាប់ក្នុងសេចក្តីថ្លែងទាមទារដែលភាគីឆ្លើយតបបានទទួលស្គាល់

ខ. អង្គហេតុ រួមទាំងអំណះអំណាងតាមផ្លូវច្បាប់ក្នុងសេចក្តីថ្លែងទាមទារដែលភាគីឆ្លើយតបបដិសេធន៍

[108] វិធានស្តីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ ៨ ។

[109] វិធានស្តីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ ៨ ។

[110] វិធានស្តីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ ៣៧ ។

និងមូលហេតុនៃការបដិសេធន៍នោះ

គ. អង្គហេតុ និងអំណះអំណាងតាមផ្លូវច្បាប់ផ្សេងទៀតដែលភាគីឆ្លើយតបផ្អែកជាមូលដ្ឋាន។ ក្រៅតែអំពីសេចក្តីថ្លែងដោះសារសេចក្តីជូនដំណឹងអំពីការឆ្លើយតបអាចនឹងត្រូវបានរួមបញ្ចូលផងដែរនូវបណ្តឹងតបឬកាដោះសារតាមការកាត់កង ប៉ុន្តែបណ្តឹងតប ឬការដោះសារតាមការកាត់កងនោះត្រូវស្ថិតក្នុង យុត្តាធិការរបស់វេទិការមជ្ឈត្តកម្ម និងត្រូវបំពេញលក្ខខណ្ឌមួយចំនួនដូចជា[111]៖

ក. អង្គហេតុដែលគាំទ្រការទាមទារ

ខ. មូលដ្ឋានច្បាប់ ឬទឡ្ហីករណ៍តាមផ្លូវច្បាប់ដែលគាំទ្រការទាមទារ

គ. សំណងការខូចខាត ឬការសង្គ្រោះដែលទាមទារ ឬចំនួនទឹកប្រាក់នៃការទាមទារដែលអាចកំណត់បានទាំងអស់។

## ២.ការបង្កើតវេទិកាមជ្ឈត្តកម្ម

### ២.១. ការជ្រើសរើសមជ្ឈត្តករ

នៅគ្រប់ករណីទាំងអស់ វេទិការមជ្ឈត្តកម្មត្រូវមានសមាសភាពមជ្ឈត្តករជាចំនួនសេស[112]។ ស្របតាមខ្លឹមសារនេះវេទិការមជ្ឈត្តកម្មអាចមានមជ្ឈត្តករចំនួន ៣រូប ឬចំនួនច្រើន ឬតិចជាងនេះអាស្រ័យលើការព្រមព្រៀង ផ្សេងពីនេះរបស់គូវិវាទ។

ការតែងតាំងមជ្ឈត្តករសម្រាប់វេទិការមជ្ឈត្តកម្ម គឺអាចត្រូវបានកំណត់ដោយវិធានស្តីពីមជ្ឈត្តការ ឬអាចត្រូវបានតែងតាំងតាមរយៈគូភាគីវិវាទធ្វើការព្រមព្រៀងគ្នា។ ហេតុនេះហើយការជ្រើសតាំងមជ្ឈត្តករសម្រាប់ដោះស្រាយវិវាទគឺមានភាពខុសៗគ្នាទៅតាមការឯកភាពគ្នារវាងភាគីជម្លោះ។ រាល់ការតែងតាំងមជ្ឈត្តករ ត្រូវធ្វើការជូនដំណឹងទៅអគ្គលេខាធិការដ្ឋានភ្លាមបន្ទាប់ពីមជ្ឈត្តករត្រូវបានតែងតាំង ហើយអគ្គលេខាធិការដ្ឋានត្រូវជូនដំណឹងទៅភាគីវិវាទអំពីឈ្មោះ នឹងព័ត៌មានលម្អិតសម្រាប់ទាក់ទងមជ្ឈត្តករទាំងអស់ដែលត្រូវបានតែងតាំង បន្ទាប់មកទៀតអគ្គលេខាធិការដ្ឋាននៃ ម.ជ.ម. ត្រូវផ្ញើសំណុំរឿងនោះទៅវេទិការមជ្ឈត្តកម្ម[113]។

#### ក.ការតែងតាំងវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករមួយរូប

ចំពោះវេទិកាមជ្ឈត្តកម្មដែលមានមជ្ឈត្តករមួយរូប ប្រសិនបើមជ្ឈត្តករមិនទាន់ត្រូវបានតែងតាំងតាមរយៈសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម ឬសេចក្តីជូណដំណឹងអំពីការឆ្លើយតបទេនោះ គូភាគីត្រូវធ្វើការតែងតាំងមជ្ឈត្តករមួយរូបរួមគ្នាក្នុងកំឡុងពេល១៥ថ្ងៃនៃថ្ងៃប្រតិទិនបន្ទាប់ពីបានទទួលការជូនដំណឹងអំពីការឆ្លើយតប

[111] វិធានស្តីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ ២៤ ។

[112] វិធានស្តីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ ២៤ ។

[113] វិធានស្តីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ ២៤ ។

ពេញលេញ ឬបន្ទាប់ពីផុតរយៈពេល ៣០ថ្ងៃនៃថ្ងៃប្រតិទិនបន្ទាប់ពីបានទទួលដំណឹងអំពីការឆ្លើយតប របស់គូភាគី[114]។ ប្រការ២៥.៣ វាក្យខ័ណ្ឌទី២ បានកំណត់ផងដែរថា ប្រសិនបើភាគីវិវាទទាំងពីរខកខានក្នុងការតែងតាំងមជ្ឈត្តករក្នុងកំឡុងដែលវិធានបានកំណត់គណៈកម្មធិការតែងតាំង និងនីតិវិធីត្រូវតែងតាំងមជ្ឈត្តករ មួយរូបដើម្បីបង្កើតវេទិការមជ្ឈត្តកម្ម។

**ខ.ការតែងតាំងវេទិការមជ្ឈត្តកម្មនៃមជ្ឈត្តករបីរូប ឬច្រើនរូប**

ចំពោះវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករ ៣រូប ឬវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករច្រើនរូប ប្រសិនបើការតែងតាំងមិនត្រូវបានធ្វើឡើងតាមរយៈសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម ឬសេចក្តីជូនដំណឹងអំពីការឆ្លើយតបទេគូភាគីទាំងពីរត្រូវធ្វើការតែងតាំងមជ្ឈត្តករម្នាក់មួយរូប ឬច្រើនរូបស្មើៗគ្នា ក្នុងកំឡុងពេល១៥ថ្ងៃប្រតិទិន បន្ទាប់ពីទទួលបានការជូនដំណឹងអំពីការឆ្លើយតបចំពោះសេចក្តីជូនដំណឹងអំពីវេទិកាមជ្ឈត្តកម្ម[115]។ ប្រការ ២៥.២ នេះក៏បានបញ្ជាក់ផងដែរថា ក្នុងអំឡុងពេលរយៈពេល ១៥ថ្ងៃប្រតិទិនបន្ទាប់ពីមានការតែងតាំងមជ្ឈត្តកររូបចុងក្រោយ។ មជ្ឈត្តករដែលត្រូវបានតែងតាំងទាំងអស់ត្រូវរួមគ្នាតែងតាំងមជ្ឈត្តករមួយរូបផ្សេងទៀតដើម្បីធ្វើជាប្រធានវេទិកាមជ្ឈត្តកម្ម។ ក្នុងករណីដែលភាគីវិវាទខកខានក្នុងការតែងតាំងមជ្ឈត្តករតាមតម្រូវការ ឬមជ្ឈត្តករដែលត្រូវបានតែងតាំងនោះខកខានមិនបានតែងតាំងប្រធានវេទិកាមជ្ឈត្តកម្មក្នុងកំឡុងពេលដែលវិធានស្តីអំពីមជ្ឈត្តការដែលបានកំណត់ គណៈកម្មាធិការតែងតាំង និងនីតិវិធីត្រូវតែងតាំងមជ្ឈត្តករ ឬប្រធានវេទិការមជ្ឈត្តកម្ម។

**គ. ការជំទាស់នឹងមជ្ឈត្តករដែលត្រូវបានជ្រើសរើស**

ការជំទាស់ទៅនឹងមជ្ឈត្តការអាចនឹងត្រូវបានធ្វើឡើងក្នុងករណីដែលមានកាលៈទេសៈណាមួយបង្កឱ្យមានការសង្ស័យសមហេតុផលចំពោះឯករាជ្យភាព ឬអព្យាក្រឹត្យភាពរបស់មជ្ឈត្តករ[116]។ មជ្ឈត្តករអាចត្រូវបានជំទាស់ផងដែរប្រសិនបើមជ្ឈត្តកររូបនោះពុំមានលក្ខណៈសម្បត្តិដូចដែលគូភាគីបានព្រមព្រៀង។ គូវិវាទអាចធ្វើការជំទាស់ទៅនឹងមជ្ឈត្តករអាចធ្វើទៅបានតែក្នុងករណីដែលខ្លួនពុំបានដឹងអំពីមូលហេតុក្នុងការជំទាស់មុនពេលតែងតាំងមជ្ឈត្តករតែប៉ុណ្ណោះ។

ភាគីវិវាទដែលមានបំណងចង់ជំទាស់ទៅនឹងមជ្ឈត្តករ ត្រូវបញ្ជូនសេចក្តីជូនដំណឹងអំពីការជំទាស់របស់ខ្លួនដោយមានបញ្ជាក់អំពីមូលហេតុនៃការជំទាស់ទៅវេទិការមជ្ឈត្តកម្ម : គូភាគីវិវាទ និងអគ្គលេខាធិការដ្ឋានក្នុងកំឡុងពេល ១៥ថ្ងៃប្រតិទិនបន្ទាប់ពីទទួលបានដំណឹងអំពីការបង្កើតវេទិការមជ្ឈត្តកម្ម ឬក្នុងកំឡុងពេល ១៥ថ្ងៃ

114 វិធានស្តីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ ២៤ ។

115 វិធានស្តីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ ២៥ ។

116 វិធានស្តីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ ២៨ ។

ប្រតិទិន ដូចគ្នាបន្ទាប់ពីខ្លួនបានដឹងអំពីកាលៈទេសៈនានាដែលអាចជំទាស់ទៅនឹងមជ្ឈត្តករ[117]។ មជ្ឈត្តករដែលត្រូវបានជំទាស់អាចធ្វើការបដិសេធន៍ទៅលើការជំទាស់ដែលធ្វើឡើងដោយគូភាគីវិវាទណាមួយបាន ហើយភាគីដែលធ្វើការជំទាស់អាចធ្វើការដាក់ពាក្យតវ៉ាទៅមជ្ឈមណ្ឌលតាមរយៈអគ្គលេខាធិការដ្ឋានក្នុងរយៈពេល ៣០ថ្ងៃប្រតិទិនបន្ទាប់ពីទទួលបានការជូនដំណឹងបដិសេធន៍លើការជំទាស់នោះ។ ចំពោះការជំទាស់ទៅនឹងមជ្ឈត្តករភាគីម្ខាងទៀត ឬសមាជិកដទៃទៀតរបស់វេទិកាមជ្ឈត្តកម្មអាចធ្វើការផ្តល់យោបល់របស់ខ្លួនពាក់ព័ន្ធនឹងការជំទាស់នេះបានក្នុងរយៈពេល១៥ថ្ងៃទៅវេទិការមជ្ឈត្តកម្ម ឬភាគីវិវាទ និងអគ្គលេខាធិការដ្ឋានប្រសិនបើមាន[118]។

**ឃ. ការជំទាស់នឹងយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម**

គណៈកម្មាធិការតែងតាំង និងនីតិវិធីត្រូវធ្វើការសម្រេចលើការតវ៉ាចំពោះការជំទាស់ទៅនឹងមជ្ឈត្តករក្នុងកំឡុងពេល ១៥ថ្ងៃប្រតិទិនបន្ទាប់ពីអគ្គលេខាធិការដ្ឋានបានទទួលការតវ៉ាចំពោះការជំទាស់ទៅនឹងមជ្ឈត្តករ។ សេចក្តីសម្រេចរបស់គណៈកម្មាធិការតែងតាំង និងនីតិវិធីមិនចាំបាច់បង្ហាញហេតុផលឡើយ។ ហើយសេចក្តីសម្រេចនោះជាសេចក្តីសម្រេចជាស្ថាពរ និងបិទផ្លូវតវ៉ា។ អគ្គលេខាធិការដ្ឋានត្រូវជូនដំណឹងទៅគូភាគី និងវេទិការមជ្ឈត្តកម្មអំពីសេចក្តីសម្រេចរបស់គណៈកម្មាធិការតែងតាំង និងនីតិវិធីនោះ[119]។ មជ្ឈត្តករដែលត្រូវបានជំទាស់នោះ ត្រូវបន្តបំពេញតួនាទីរបស់ខ្លួនជាមជ្ឈត្តករបន្តទៀត ប្រសិនបើគណៈកម្មាធិការបដិសេធចំពោះការជំទាស់ទៅនឹងមជ្ឈត្តករ។ ប្រសិនបើគណៈកម្មធិការយល់ស្របចំពោះការជំទាស់ អាណត្តិរបស់មជ្ឈត្តករដែលត្រូវបានជំទាស់នោះនឹងត្រូវបញ្ចប់ដោយមានអានុភាពចាប់ពីថ្ងៃចេញសេចក្តីសម្រេចនោះ។ ក្នុងករណីនេះដើម្បីដំណើរការវេទិការមជ្ឈត្តការ គឺការដាក់មជ្ឈត្តករជំនួសត្រូវបានយកមកអនុវត្ត។

**៣.នីតិវិធីមុនសវនាការ**

ដំណើរការមុនសវនាការបង្កើតបានជាដំណាក់កាលបន្ទាប់។ ក្រោយពេលមជ្ឈត្តករត្រូវបានជ្រើសរើសរួមហើយយុត្តាធិការត្រូវបានកំណត់រួច ភាគីវិវាទមានបញ្ហាសំខាន់ៗជាច្រើនដែលត្រូវដោះស្រាយ ហើយជាទូទៅបញ្ហានេះត្រូវបញ្ចប់នៅក្នុងការប្រជុំពិភាក្សាមុនពេលសវនាការដែលនីតិវិធី ទីតាំង ការបង្ហាញសក្ខីកម្ម និងបញ្ហាផ្សេងទៀតនឹងត្រូវបានសម្រេច នៅពេលដែលខចែងស្តីពីមជ្ឈត្តការនៅក្នុងកិច្ចសន្យាដែលមិនបានចែង ឬមានមិនច្បាស់លាស់អំពីបញ្ហាទាំងនេះ។

**ក. ដំណើរការមជ្ឈត្តការ សេចក្តីបង្គាប់ និងសេចក្តីណែនាំ**

[117] វិធានស្តីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ ២៨ ។

[118] វិធានស្តីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ ២៨ ។

[119] វិធានស្តីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ ២៨ ។

បន្ទាប់ពីពិភាក្សាជាមួយភាគីវិវាទ ដោយផ្អែកលើភាពសាំញ៉ាំនិងតម្លៃនៃវិវាទ វេទិកាមជ្ឈត្តកម្មត្រូវដំណើរការក្នុងលក្ខណៈមួយដែលវេទិការមជ្ឈត្តកម្មយល់ថាសមស្របដើម្បីធានាឱ្យបាននូវយុត្តិធម៌ មានភាពឆាប់រហ័សមានប្រសិទ្ធភាព ចំណាយតិច និងផ្តល់ដំណោះស្រាយចុងក្រោយនៃវិវាទ។ វេទិការមជ្ឈត្តកម្មត្រូវដំណើរការ គ្រប់ករណីទាំងអស់ដោយគូវិវាទត្រូវបានទទួលការយកចិត្តទុកដាក់ស្មើៗគ្នា និងភាគីវិវាទនីមួយៗត្រូវបានផ្តល់ ឱកាសសមរម្យក្នុងការបង្ហាញហេតុផល និងទឡ្ហីករណ៍របស់ខ្លួន។

វេទិការមជ្ឈត្តកម្មត្រូវចេញសេចក្តីបង្គាប់ ឬសេចក្តីណែនាំដែលមានលក្ខណៈសមស្របដើម្បីធានានូវដំណើរការមជ្ឈត្តការប្រព្រឹត្តទៅដោយរលូន។ សេចក្តីបង្គាប់ ឬសេចក្តីណែនាំនេះមិនត្រូវផ្ទុយនឹងវិធានស្តីមជ្ឈត្តកម្ម ឬច្បាប់ដែលគ្រប់គ្រងមជ្ឈត្តការឡើយ។ ការធ្វើសេចក្តីបង្គាប់ ឬសេចក្តីណែនាំនេះតម្រូវឱ្យធ្វើជាលាយលក្ខណ៍ អក្សរលើកលែងតែការទាក់ទងដោយផ្ទាល់មាត់នៅពេលសវនាការ និងក្នុងកិច្ចប្រជុំនានាដែលរៀបចំឡើងដោយ វេទិកាមជ្ឈត្តកម្ម។

**ខ. ទីកន្លែងធ្វើមជ្ឈត្តការ**

ភាគីវិវាទមានសេរីភាពក្នុងការកំណត់កន្លែងធ្វើមជ្ឈត្តការ នៅក្នុងកិច្ចព្រមព្រៀងរបស់ពួកគេ ឬនៅក្នុងលិខិតផ្សេងទៀត។ ក្នុងករណីដែលពួកគេមិនបានព្រមព្រៀងគ្នាលើរឿងនេះ ទីកន្លែងធ្វើមជ្ឈត្តការត្រូវកំណត់ដោយវេទិការមជ្ឈត្តកម្ម ដោយពិចារណាអំពីកាលៈទេសៈនៃរឿងក្តី ដោយធ្វើឡើងនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា[120]។

**គ. ភាសា**

គូភាគីមានសេរីភាពក្នុងការយល់ព្រមលើភាសាណាមួយ ឬច្រើនមកប្រើក្នុងដំណើរការមជ្ឈត្តការ។ ក្នុងករណីដែលគ្មានការព្រមព្រៀងគ្នា វេទិកមជ្ឈត្តកម្មអាចសម្រេចយកភាសាណាមួយជាភាសាសម្រាប់ដំណើរការមជ្ឈត្តការ ដោយគិតពិចារណាលើកាលៈទេសៈនានាដែលពាក់ព័ន្ធទាំងអស់ រួមបញ្ចូលទាំងភាសានៃកិច្ចសន្យាផងដែរ[121]។

**ឃ. ការប្រជុំត្រៀម និងការប្រជុំបន្ថែមនានា**

ការរៀបចំការប្រជុំត្រៀម និងការប្រជុំបន្ថែមផ្សេងទៀតអាចធ្វើទៅបានភ្លាមៗតាមដែលអាចធ្វើទៅបាន។ វេទិកាមជ្ឈត្តកម្មអាចរៀបចំការប្រជុំត្រៀមជាមួយគូវិវាទដោយផ្ទាល់ ឬដោយមធ្យោបាយផ្សេងៗទៀតដើម្បីរៀបចំ និងកំណត់កាលវិភាគនៃដំណើរការមជ្ឈត្តការបន្ទាប់ ឬពិភាក្សាអំពីនីតិវិធីដែលមានភាពសមស្រប និងចំណាយអស់តិចបំផុតចំពោះសំណុំរឿង។ បន្ថែមពីលើការប្រជុំត្រៀម ការធ្វើមជ្ឈត្តកម្មអាចរៀបចំឱ្យមានការប្រជុំបន្ថែម

[120] វិធានស្តីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ ៣១ ។

[121] វិធានស្តីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ ៣៣ ។

ទៀតដូចជាការប្រជុំដើម្បីត្រួតពិនិត្យទីតាំង សម្ភារៈ ឬឯកសារនានា ឬត្រួតពិនិត្យលើភាពរីកចម្រើននៃដំណើរការមជ្ឈត្តការ[122]។

**ខ. ការស្វែងរកដំណោះស្រាយដោយស្រុះស្រួលគ្នា**

មុនពេល ឬក្នុងកំឡុងពេលប្រជុំត្រៀម វេទិការមជ្ឈត្តកម្មត្រូវពិភាក្សាជាមួយគូភាគីវិវាទដើម្បីស្វែងរកលទ្ធភាពក្នុងការដោះស្រាយវិវាទដោយមានការស្រុះស្រួលគ្នា និងត្រូវជួយដល់គូភាគីវិវាទក្នុងលក្ខណៈណាមួយដែលវេទិកាមជ្ឈត្តកម្មយល់ថាសមស្រប[123]។

**ច. ការបំបែកដំណើរការមជ្ឈត្តការដាច់ៗពីគ្នា**

ដំណើរមជ្ឈត្តការអាចត្រូវបានធ្វើឡើងដោយបំបែកដាច់ៗពីគ្នាបាន បន្ទាប់ពីបានពិភាក្សាជាមួយគូភាគីវិវាទ វេទិកាមជ្ឈត្តកម្មតាមរយៈឆន្ទានុសិទ្ធិរបស់ខ្លួន។ ក្នុងការបំបែកដំណើរការមជ្ឈត្តការដាច់ពីគ្នា វេទិកាមជ្ឈត្តកម្មត្រូវកំណត់ឱ្យគូភាគីវិវាទផ្តោតលើការបង្ហាញផ្សេងៗរបស់ពួកគេលើបញ្ហានានា និងសេចក្តីសម្រេចដែលសម្រេចលើបញ្ហាទាំងនោះថាអាចត្រូវបានបំបែកសំណុំរឿងទាំងមូល ឬដោយផ្នែកៗ[124]។

**ឆ. ការរួមបញ្ចូលមជ្ឈត្តការ**

តបតាមសំណើររបស់ភាគីវិវាទណាមួយដោយមានការយល់ព្រមពីគូភាគីវិវាទ អគ្គលេខាធិការដ្ឋានអាចរួមបញ្ចូលមជ្ឈត្តការ២(ពីរ) ឬច្រើនឱ្យទៅជាមជ្ឈត្តការតែមួយបាន ដែលការរួមបញ្ចូលមជ្ឈត្តការនានាគឺត្រូវអនុលោមទៅតាមប្រការ ៣៦,៣ នៃវិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២[125]។ នៅពេលរួមបញ្ចូលគ្នានៃមជ្ឈត្តការ នានា មជ្ឈត្តការទាំងនោះត្រូវរួមបញ្ចូល ដើម្បីសម្រេចលើការរួមបញ្ចូលមជ្ឈត្តការ អគ្គលេខាធិការដ្ឋាននៃ ម.ជ.ម. អាចពិចារណាលើ កាលៈទេសៈផ្សេងៗជាច្រើន ដែលអគ្គលេខាធិការដ្ឋានយល់ថាពាក់ព័ន្ធដូចខាងក្រោម[126]៖

- តើការទាមទារទាំងអស់នៅក្នុងមជ្ឈត្តការការពារត្រូវបានធ្វើឡើងក្រោមកិច្ចសន្យាព្រមមជ្ឈត្តកម្មតែមួយដែរឬទេ
- ប្រសិនបើការទាមទារត្រូវបានធ្វើឡើងក្រោមកិច្ចសន្យាមជ្ឈត្តកម្មផ្សេងគ្នាហើយមជ្ឈត្តការធ្វើឡើងដោយភាគីវិវាទដូចគ្នា តើវិវាទនានាក្នុងមជ្ឈត្តការទាំងនោះ កើតឡើងពាក់ព័ន្ធនឹងទំនាក់ទំនងគតិយុត្តិតែមួយ និងកិច្ចសន្យាមជ្ឈត្តកម្មទាំងនោះមិនត្រូវបានចាត់ទុកថាផ្ទុយគ្នាដែរទេ

[122] វិធានស្តីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ ៣៩ ។
[123] វិធានស្តីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ ៣១ ។
[124] វិធានស្តីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ ៣៧ ។
[125] វិធានស្តីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ ៣៦.៣ ។
[126] វិធានស្តីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ ៣៦ ។

- តើមជ្ឈត្តករដែលត្រូវបានតែងតាំងសម្រាប់មជ្ឈត្តការលើសពីមួយដែរឬទេ និងប្រសិនបើតែងតាំង មជ្ឈត្តករដែលបានតែងតាំងនោះតែមួយឬផ្សេងគ្នា។

**ង. ការចូលរួមពីតតិយជន**

ក្នុងករណីមានការព្រមព្រៀងគ្នារវាងគូភាគីវិវាទនិងតតិយជនជាលាយលក្ខណ៍អក្សរ វេទិការមជ្ឈត្តកម្មមានអំណាចក្នុងការអនុញ្ញាតឱ្យតតិយជនចូលរួមក្នុងដំណើរការមជ្ឈត្តករបាន។ ក្នុងករណីនេះ វេទិការមជ្ឈត្តកម្មអាចចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរតែមួយ ឬដោយឡែកសម្រាប់ដោះស្រាយវិវាទរបស់គូភាគី[127]។

**៤.សវនាការមជ្ឈត្តការ**

ដើម្បីដំណើរការសវនាការមជ្ឈត្តការបាន វេទិកាមជ្ឈត្តកម្មត្រូវកំណត់កាលបរិច្ឆេទ, ពេលវេលា ទីកន្លែង និងរបៀបនៃការធ្វើមជ្ឈត្តការជាមុនសិន។ បន្ទាប់មកទៀតវេទិកាមជ្ឈត្តកម្មត្រូវធ្វើការជូនដំណឹងជាមុនទៅគូភាគីវិវាទអំពីបញ្ហាទាំងនេះ យ៉ាងហោចណាស់ ១៥ថ្ងៃ មុនកាលបរិច្ឆេទធ្វើសវនាការ។ ជាមួយគ្នានេះដែរ យ៉ាងហោចណាស់ ១៥ថ្ងៃមុនពេលធ្វើសវនាការ វេទិកាមជ្ឈត្តកម្មអាចផ្តល់នូវបញ្ជីនៃចំណុចវិវាទ ឬសំណួរផ្សេងៗដែលវេទិកាមជ្ឈត្តកម្មមានបំណងផ្តល់ឱ្យភាគីវិវាទទាំងអស់ដើម្បីពិចារណាជាពិសេស[128]។

លើកលែងតែគូភាគីវិវាទបានព្រមព្រៀងអំពីរបៀបនៃការធ្វើសនវការ វេទិកាមជ្ឈត្តកម្មត្រូវសម្រេចថាតើត្រូវធ្វើសវនការដោយផ្ទាល់មាត់ ឬត្រូវដំណើរការមជ្ឈត្តការដោយផ្អែកលើឯកសារ និងលិខិតស្នាមផ្សេងៗតែប៉ុណ្ណោះ។ ប៉ុន្តែក្នុងករណីមានការស្នើសុំដោយភាគីណាមួយ វេទិកាមជ្ឈត្តកម្មត្រូវធ្វើសវនការដោយផ្ទាល់ មាត់នៅដំណាក់កាលសមរម្យណាមួយនៃដំណើរការមជ្ឈត្តការ[129]។ ប្រសិនការធ្វើសវនការផ្ទាល់មាត់ ឬត្រូវបានធ្វើឡើង វេទិកាមជ្ឈត្តកម្មអាចសម្រេចថាតើ សវនាការនឹងត្រូវធ្វើឡើងដោយមានការចូលរួមដោយផ្ទាល់ ឬពីចម្ងាយតាមរយៈសន្និសីទវីដេអូ ទូរស័ព្ទ ឬដោយមធ្យោបាយអេឡិចត្រូនិចផ្សេងទៀតជាមួយអ្នកចូលរួមដែលស្ថិតនៅ ទីកន្លែងមួយ ឬច្រើនបន្ទាប់ពីបានពិភាក្សាជាមួយគូភាគីវិវាទ ដោយផ្អែកលើអង្គហេតុពាក់ព័ន្ធ និងកាលៈទេសៈនៃសំណុំរឿង។ ដោយផ្អែកលើកាលៈទេសៈនៃមជ្ឈត្តការតម្រូវក្នុងដំណាក់កាលណាមួយនៃដំណើរការមជ្ឈត្តការ និងមុនពេលចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរ វេទិកាមជ្ឈត្តការអាចសម្រេចឱ្យមានមជ្ឈត្តករបន្ថែមបាន[130]។

ក្នុងដំណើរការមជ្ឈត្តការ វេទិកាមជ្ឈត្តកម្មត្រូវទទួលបន្ទុកគ្រប់គ្រងទាំងស្រុងលើសវនាការដែលគូភាគី វិវាទទាំងអស់មានសិទ្ធិចូលរួម។ លើកលែងតែមានការឯកភាពពីវេទិការមជ្ឈត្តកម្មនិងគូភាគីវិវាទ, អ្នកដែលមិនពាក់ព័ន្ធ

[127] វិធានស្តីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ ២០ ។
[128] វិធានស្តីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ ៣៩ ។
[129] វិធានស្តីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ ៣៩ ។
[130] វិធានស្តីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ ៣៩ ។

នឹងដំណើរការនៃនីតិវិធី មិនត្រូវបានអនុញ្ញាតឱ្យចូលរួមឡើយ[131]។ ក្នុងករណីដែលគូភាគីវិវាទនៃដំណើរការមជ្ឈត្តការមានការខកខានមិនបានចូលរួមក្នុងការបង្ហាញខ្លួននៅក្នុងសវនាការដោយផ្ទាល់មាត់ដោយមិនបានប្រាប់អំពីមូលហេតុគ្រប់គ្រាន់នៃការខកខាននេះ វេទិកាអាចបន្តធ្វើមជ្ឈត្តកម្មអាចចេញមជ្ឈត្តវិនិច្ឆ័យដោយផ្អែកលើ សេចក្តីថ្លែង និងភស្តុតាងដែលបានដាក់មកវេទិកាមជ្ឈត្តកម្ម។

យើងសង្កេតឃើញថា ដំណើរការនៃនីតិវិធីមជ្ឈការមានលក្ខណៈបត់បែន និងទន់ភ្លន់ ជាងនីតិវិធីនៅក្នុងតុលាការ ដោយហេតុថាប្រសិនបើមានការព្រមព្រៀងរវាងគូវិវាទការធ្វើសវនាការផ្ទាល់មិនចាំបាច់ប្រព្រឹត្តឡើងបាន ដោយគ្រាន់តែធ្វើការបង្ហាញនូវភស្តុតាងជាឯកសារ និងធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ជាលាយលក្ខណ៍អក្សរដាក់ជូនវេទិកាមជ្ឈត្តកម្មដើម្បីធ្វើការពិចារណាផងដែរ។ ប៉ុន្តែបើមានការស្នើឱ្យមានសវនាការដោយផ្ទាល់មាត់ដោយភាគីវិវាទ សវនាការនឹងត្រូវប្រព្រឹត្តឡើងដែរ[132]។

## ៥.ការធ្វើសេចក្តីសម្រេច ឬមជ្ឈត្តវិនិច្ឆ័យ

### ៥.១. ទម្រង់នៃមជ្ឈត្តវិនិច្ឆ័យ

មជ្ឈត្តវិនិច្ឆ័យត្រូវធ្វើជាលាយលក្ខណ៍អក្សរ លើកលែងតែគូភាគីវិវាទបានព្រមព្រៀងគ្នាផ្សេងពីនេះ និងស្របតាមវិធានស្តីពីមជ្ឈត្តការដែលចែងអំពី ការដោះស្រាយវិវាទដោយស្ម័គ្រចិត្ត[133] មជ្ឈត្តវិនិច្ឆ័យត្រូវមានសំអាងហេតុ ដែលជាមូលដ្ឋាននៃការសម្រេចចិត្ត[134]។

មជ្ឈត្តវិនិច្ឆ័យត្រូវមានការចុះកាលបរិច្ឆេទ និងទីកន្លែងដែលចេញមជ្ឈត្តវិនិច្ឆ័យនោះ និងត្រូវចុះហត្ថលេខាដោយមជ្ឈត្តករទាំងអស់ ដោយឡែកចំពោះវេទិការមជ្ឈត្តកម្មដែលមានមជ្ឈត្តករច្រើនរូប ហត្ថលេខារបស់សមាជិកភាគច្រើននៃវេទិកាមជ្ឈត្តកម្ម ត្រូវចាត់ទុកថាគ្រប់គ្រាន់ ប៉ុន្តែមជ្ឈត្តករដទៃទៀតដែលមិនបានចុះ ហត្ថលេខាតម្រូវឱ្យធ្វើការបញ្ជាក់ពីមូលហេតុដែលខ្លួនអវត្តមានមិនបានចុះហត្ថលេខាលើមជ្ឈត្តវិនិច្ឆ័យនោះ[135]។

មជ្ឈត្តករ ឬវេទិកាមជ្ឈត្តកម្ម អាចធ្វើការចេញមជ្ឈត្តវិន័យរបស់ខ្លួនបានបន្ទាប់ពីអគ្គលេខាធិការដ្ឋានបានពិនិត្យនិងឯកភាពចំពោះទម្រង់របស់មជ្ឈត្តវិនច្ឆ័យនោះ។

---

[131] វិធានស្តីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ ៣៩ ។

[132] វិធានស្តីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ ៣៧ ។

[133] ការដោះស្រាយវិទដោយស្ម័គ្រចិត្តៈ ប្រសិនបើមុនពេលមជ្ឈត្តវិនិច្ឆ័យជាស្ថាពរ គូភាគីវិវាទព្រមព្រៀងដោះស្រាយវិវាទដោយស្ម័គ្រចិត្ត វេទិកាមជ្ឈត្តកម្មត្រូវចេញសេចក្តីបង្គាប់បញ្ឈប់ដំណើរការមជ្ឈត្តការ ឬប្រសិនបើមានសំណើរបស់ភាគីវិវាទទាំងពីរ និងតាមវិសាលភាពនៃសំណើនោះ និងត្រូវទទួលយល់ព្រមរបស់វេទិកាមជ្ឈត្តកម្ម វេទិកាមជ្ឈត្តកម្មត្រូវកត់ត្រាដំណោះស្រាយវិវាទដោយស្ម័គ្រចិត្តនោះក្នុងទម្រង់មជ្ឈត្តវិនិច្ឆ័យតាមការព្រមព្រៀង។ វេទិកាមជ្ឈត្តការមជ្ឈត្តកម្មមិនកាតព្វកិច្ចក្នុងការផ្តល់មូលហេតុចំពោះមជ្ឈត្តវិនិច្ឆ័យបែបនោះទេ (ប្រការ៤៥ នៃវិធានស្តីមជ្ឈត្តការ ឆ្នាំ២០២១)។

[134] វិធានស្តីពីមជ្ឈត្តការ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១ ប្រការ៤៩ ។

[135] វិធានស្តីពីមជ្ឈត្តការ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១ ប្រការ៣៩ ។

### ៥.២. ការត្រួតពិនិត្យលើទម្រង់របស់មជ្ឈត្តវិនិច្ឆ័យ

មុនពេលចេញមជ្ឈត្តវិនិច្ឆ័យ វេទិកាមជ្ឈត្តកម្មត្រូវបញ្ជូនសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យទៅអគ្គលេខាធិការដ្ឋាន ដើម្បីធ្វើការពិនិត្យពិច័យលើទម្រង់របស់មជ្ឈត្តវិនិច្ឆ័យ។ សេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យនឹងត្រូវបានបញ្ជូនទៅអគ្គលេខាធិការដ្ឋានក្នុងកំឡុងពេល ៤៥ថ្ងៃប្រតិទិនគិតចាប់ពីថ្ងៃដែលវេទិការមជ្ឈត្តកម្មប្រកាសបិទដំណើរការមជ្ឈត្តកម្ម ប្រសិនបើអគ្គលេខាធិការពន្យាពេលកំណត់ស្របតាមសំណើរបស់វេទិការមជ្ឈត្តកម្ម ឬការព្រមព្រៀងរបស់គូភាគីវិវាទ។ ស្របតាមប្រការ ៥០.១ វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ក្នុងកំឡុងពេល ៣០ថ្ងៃប្រតិទិនគិតចាប់ពីថ្ងៃទទួលបានសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យ អគ្គលេខាធិការដ្ឋានអាចធ្វើការស្នើកែប្រែលើទម្រង់របស់មជ្ឈត្តវិនិច្ឆ័យ និងមិនធ្វើឱ្យប៉ះពាល់ដល់សេរីភាពក្នុងការសម្រេចរបស់វេទិកាមជ្ឈត្តកម្មឡើយ ។ ការស្នើឱ្យមានការកែប្រែលើមជ្ឈត្តវិនិច្ឆ័យក៏អាចជាកម្មវត្ថុក្នុងការឱ្យមានការកែតម្រូវ ការបំភ្លឺលំអិត និងការបកស្រាយនូវមជ្ឈត្តវិនិច្ឆ័យ និងមជ្ឈត្តវិនិច្ឆ័យបន្ថែមផងដែរ។ ការកែតម្រូវទៅលើមជ្ឈត្តវិនិច្ឆ័យ វេទិកាមជ្ឈត្តកម្មត្រូវធ្វើឡើងក្នុងរយៈពេល ៣០ថ្ងៃប្រតិទិនបន្ទាប់ពីទទួលបានមជ្ឈត្តវិនិច្ឆ័យ[136]។

### ៥.៣. ការចេញមជ្ឈត្តវិនិច្ឆ័យ

នៅពេលវេទិកាមជ្ឈត្តកម្មបានចេញមជ្ឈត្តវិនិច្ឆ័យសមស្របទៅតាមទម្រង់ហើយនោះ អគ្គលេខាធិការដ្ឋានត្រូវបោះត្រារបស់មជ្ឈមណ្ឌលលើមជ្ឈត្តវិនិច្ឆ័យដោយមិនបង្អង់ និងបញ្ជូនមជ្ឈត្តវិនិច្ឆ័យនោះទៅភាគីវិវាទទាំងអស់ប្រសិនបើការបង់ប្រាក់ជាមុន[137] ដែលតម្រូវត្រូវបានបង់ទៅ ម.ជ.ម. ឬក្នុងករណីបើកម្រៃសេវាទាំងអស់ត្រូវបានបង់គ្រប់ចំនួនទៅ ម.ជ.ម. សម្រាប់មជ្ឈត្តវិនិច្ឆ័យស្ថាពរ។

### ៥.៤. អានុភាព និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យ

ក្រោយពេលវេទិកាមជ្ឈត្តកម្មបានចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរហើយ មជ្ឈត្តវិនិច្ឆ័យនោះនឹងមានអានុភាព អនុវត្តចំពោះគូភាគីវិវាទចាប់ពីកាលបរិច្ឆេទដែលមជ្ឈត្តវិនិច្ឆ័យនោះត្រូវបានចេញ។ មជ្ឈត្តវិនិច្ឆ័យទោះជាបានធ្វើឡើងក្នុងប្រទេសណាក៏ដោយ គឺត្រូវបានគេទទួលស្គាល់ថាជាកាតព្វកិច្ច[138]។

### ៥.៥. ការធ្វើបណ្តឹងឧបាស្រ័យទៅនឹងមជ្ឈត្តវិនិច្ឆ័យ

សេចក្តីសម្រេចរបស់មជ្ឈត្តការ ឬមជ្ឈត្តវិនិច្ឆ័យ ជាសេចក្តីសម្រេចចុងក្រោយដែលភាគីមិនអាចធ្វើការតវ៉ាបាន។ តែទោះជាយ៉ាងនេះក្តី បញ្ញត្តិនៃច្បាប់បានកំណត់នូវលក្ខខណ្ឌមួយចំនួនដែលភាគីវិវាទអាចធ្វើការប្តឹង តវ៉ានឹងសេចក្តីសម្រេចនោះ។ ការប្តឹងជំទាស់នឹងសេចក្តីសម្រេចមជ្ឈត្តការមិនអាចធ្វើឡើងចំពោះការមិន

---

136 វិធានស្តីពីមជ្ឈត្តការ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១ ប្រការ៥៣ ។

137 វិធានស្តីពីមជ្ឈត្តការ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១ ប្រការ៦៤ ។

138 ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦ មាត្រា៤៥ ។

ពេញចិត្ត នឹងសេចក្តីសម្រេចនោះទេ ភាគីវិវាទអាចប្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់មជ្ឈត្តការបានតែចំពោះដំណើរការនៃវិវាទមជ្ឈត្តការបានធ្វើខុសទៅនឹងនីតិវិធីដែលភាគីបានកំណត់ក្នុងកិច្ចព្រមព្រៀង ឬក៏ផ្ទុយនឹងបញ្ញត្តិនៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម[139]។ ការប្តឹងជំទាស់នឹងនីតិវិធីក្នុងដំណើរការមជ្ឈត្តការអាចត្រូវធ្វើឡើង បើភាគីណាមួយនៃវិវាទបានបាត់បង់សិទ្ធិមួយចំនួនដូចជាការតែងតាំងមជ្ឈត្តករ ឬមិនបានទទួលដំណឹងពីដំណើរការមជ្ឈត្តការ

### កថាភាគទី៣៖ គុណសម្បត្តិ និងគុណវិបត្តិនៃមជ្ឈត្តការ

#### ១.គុណសម្បត្តិ

- ថ្លៃចំណាយ៖ មជ្ឈត្តការប្រើចំណាយតិចជាងបណ្តឹងតុលាការ។ នេះដោយសារមជ្ឈត្តការ មានភាពរលូនជាងបើធៀបទៅនឹងវិធានតុលាការ។ មួយវិញទៀតក៏ដោយសារតែមជ្ឈត្តការ ជាទូទៅ ពុំមានការប្តឹងឧបាស្រ័យ។
- ល្បឿន៖ មជ្ឈត្តការមានការដោះស្រាយវិវាទបានឆាប់រហ័សជាងបណ្តឹងតុលាការ។ ដូចដែលបានរៀបរាប់នៅខាងលើរួចហើយ មជ្ឈត្តការខុសពីបណ្តឹងតុលាការ ដោយជាទូទៅគឺមិនអនុញ្ញាតឱ្យមានបណ្តឹងឧបាស្រ័យឡើយ។ ផ្ទុយមកវិញ តាមរយៈបណ្តឹងតុលាការ គូភាគីអាចប្តឹងឧបាស្រ័យយ៉ាងហោចណាស់ម្តង ហើយជួនកាលច្រើនដងទៀតផង។ លើសពីនេះតុលាការមានរឿងក្តីដែលរងចាំការដោះស្រាយជាច្រើន ដែលបង្ខំឱ្យគីភាគីរងចាំការជំនុំជម្រះយ៉ាងយូរ។
- លក្ខណៈស្ថាពរ៖ ដោយហេតុថាមជ្ឈត្តការមិនអាចប្តឹងឧបាស្រ័យបាន ជាទូទៅសេចក្តីសម្រេចរបស់មជ្ឈត្តការមានលក្ខណៈស្ថាពរ។ ជាញឹកញាប់ ប្រការនេះគឺជាគុណសម្បត្តិធំធេងចំពោះភាគី។
- ការដាក់ឱ្យអនុវត្តថ្នាក់ជាតិ៖ ដោយហេតុថា ប្រទេសកម្ពុជាបានអនុម័តច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ខ្លួន តុលាការកម្ពុជាអាចដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យដោយផ្ទាល់។ ដំណោះស្រាយតាមការចរចា ឬសន្ធានកម្ម មិនអាចដាក់ឱ្យអនុវត្តបានដោយងាយស្រួលបែបនេះឡើយ[140]។
- ការដាក់ឱ្យអនុវត្តថ្នាក់អន្តរជាតិ៖ ដោយអនុលោមតាមអនុសញ្ញាក្រុងញ៉ូយកស្តីពីការទទួលស្គាល់ និងការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេស ( អនុសញ្ញាក្រុងញ៉ូយក ) ដែលប្រទេសកម្ពុជាបានចុះហត្ថលេខាផងដែរ នោះ មជ្ឈត្តវិនិច្ឆ័យដែលធ្វើឡើងនៅក្នុងប្រទេសហត្ថលេខី អាចដាក់ឱ្យអនុវត្តបានដោយ

---

[139] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦ មាត្រា៤៤ ។

[140] ទោះជាយ៉ាងណា ក៏នៅមានករណីលើកលែងមួយដូចមានកំណត់នៅក្នុងជំពូកមុនស្តីពីការចរចា និងសន្ធានកម្ម។ គូភាគីដែលកំពុងប្តឹងផ្តល់នៅតុលាករកម្ពុជា អាចសាកល្បងដោះស្រាយរឿងក្តីរបស់ខ្លួនបាន។ ប្រសិនបើ ពួកគេឈានដល់ (ការសះជាតាមផ្លូវតុលាការ ) ដែលមានកត់ត្រានៅក្នុងពិធីសារតុលាការ (កំណត់ហេតុតុលាការ) វានឹងមានអានុភាព និងប្រសិទ្ធិភាពដូចសាលក្រមតុលាការដែរ ហើយអាចអនុវត្តបានតាមរយៈតុលាការ។ ក.ន.រ.ព.ក. កំណត់សម្គាល់ខាងលើ លេខ៧ មាត្រា២២២។

ស្វ័យប្រវត្តិនៅក្នុងបណ្តាប្រទេសហត្ថលេខីផ្សេងទៀតទាំងអស់[141]។ ប្រការនេះគឺជាគុណសម្បត្តិក៏ធំសម្រាប់ដោះស្រាយវិវាទអន្តរជាតិដោយសារតែគ្មានប្រព័ន្ធដាក់ឱ្យអនុវត្តជាអន្តរជាតិស្រដៀងគ្នានេះសម្រាប់សេចក្តីសម្រេចរបស់តុលាការនៅឡើយ[142]។

- ការរក្សាទំនាក់ទំនង៖ ទោះបីជាមជ្ឈត្តការមានទិដ្ឋភាពបដិបក្ខក៏ដោយ ជាទូទៅមជ្ឈត្តការមានបដិបក្ខតិចជាងដំណើរការបណ្តឹងនៅតុលាការ។ កត្តានេះអាចជួយរក្សាទំនាក់ទំនងរវាងគូភាគីបាន។
- ភាពជាឯកជន៖ ផ្ទុយពីដំណើរការបណ្តឹងនៅតុលាការ ជាទូទៅមជ្ឈត្តការគឺជាដំណើរការជាឯកជន។ ប្រការនេះអាចជាគុណសម្បត្តិមួយ ប្រសិនបើភាគីមិនចង់ឱ្យសាធារណៈជនដឹងអំពីចំណុចលម្អិតនៃវិវាទរបស់ពួកគេ។
- ដំណោះស្រាយដែលអាចបត់បែនបាន៖ មជ្ឈត្តករតែងមានភាពបត់បែនក្នុងការដាក់ចេញនូវមធ្យោបាយដោះស្រាយដែលប្រកបដោយភាពច្នៃប្រឌិត ដែលតុលាការមិនអាចធ្វើបានឡើយ ដូចជាការសម្រេចឱ្យភាគីដែលឈ្នះក្តីចេញថ្លៃមេធាវីជាដើម។
- ជំនាញរបស់មជ្ឈត្តករ៖ គូភាគីអាចជ្រើសរើសមជ្ឈត្តករដែលមានជំនាញនៅក្នុងវិស័យអាជីវកម្មដែលត្រូវនឹងវិស័យការងាររបស់ពួកគេ ឧទាហរណ៍ នៅក្នុងវិស័យកាត់ដេរជាដើម។ ម៉្យាងទៀត ប្រព័ន្ធតុលាការភាគច្រើន ពុំមានចៅក្រមជំនាញសម្រាប់វិស័យនៃច្បាប់ណាមួយជាក់លាក់នោះទេ ហេតុដូច្នេះហើយ ភាគីវិវាទអាចត្រូវមានចៅក្រមអធិបតីម្នាក់ ដែលគ្មានចំណេះដឹងជាក់លាក់អំពីវិស័យឧស្សាហកម្មរបស់ខ្លួន។ ដូច្នេះ ក្នុងករណីដែលចំណេះដឹងជាក់លាក់អំពីវិស័យអាជីវកម្ម ឬច្បាប់មានភាពសំខាន់ដំណើរការមជ្ឈត្តការអាចផ្តល់លទ្ធផលកាន់តែត្រឹមត្រូវ និងផ្តល់ភាពជ្រួតជ្រាបបានល្អ។
- អព្យាក្រឹតភាពរបស់មជ្ឈត្តករ៖ គូភាគីនៃវិវាទអន្តរជាតិ តែងតែព្រួយបារម្ភថាចៅក្រមនៅក្នុងប្រទេសដើមរបស់ភាគីម្ខាង អាចនឹងមានភាពលម្អៀងទៅលើភាគីនោះ ជួនកាលហៅថា គុណសម្បត្តិនៃតុលាការលំនៅ។ ប៉ុន្តែនៅក្នុងមជ្ឈត្តការគូភាគីអាចជ្រើសរើសមជ្ឈត្តករបាន ហេតុនេះគឺអាចលុបបំបាត់ភាពលម្អៀងលើជាតិសាសន៍ដែលអាចកើតមាន។
- នីតិវិធីដែលអាចបត់បែនបាន៖ ជារឿយៗ គូភាគីអាចជ្រើសរើសថាតើពួកគេចង់ជ្រើសរើសនីតិវិធីស្មុគស្មាញដែលមើលទៅមានលក្ខណៈដូចជាដំណើរការបណ្តឹងនៅតុលាការ ឬនីតិវិធីដែលមានលក្ខណៈ

[141] មានប្រទេសជាង១៤០ បានចុះហត្ថលេខីកិច្ចព្រមព្រៀងញ៉ូយក។

[142] អនុសញ្ញាក្រុងឡាអេស្តីពីការជ្រើសរើសកិច្ចព្រមព្រៀងតុលាការ, សន្និសីទក្រុងឡាអេស្តីពីនីតិអន្តរជាតិឯកជនមាននៅ http://www.hcch.net/index_en.php?act=conventions.text&cid=98 ចូលទស្សនាចុងក្រោយថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ អនុសញ្ញានេះអនុញ្ញាតឱ្យទទួលស្គាល់ និងអនុវត្ត ខចែងស្តីពីការជ្រើសរើសវេទិកា និងសាលក្រមសម្រេចនៅក្នុងវិវាទពាណិជ្ជកម្ម ក្នុងចំណោមប្រទេសហត្ថលេខី។

សាមញ្ញជាងនេះ នៅបណ្ដឹងតុលាការ ភាគីវិវាទត្រូវតែគោរពតាមនីតិវិធីច្បាប់ ទោះបីជា ពួកគេមិនពេញចិត្តនឹងនីតិវិធីនោះក៏ដោយ[143]។

**២. គុណវិបត្តិ**

- ថ្លៃចំណាយ៖ ទោះបីជាមជ្ឈត្តការ ជាទូទៅមានការចំណាយទាបជាងដំណើរការកាត់ក្ដីដោយតុលាការក៏ដោយ ក៏មជ្ឈត្តការនៅតែអាចមានតម្លៃថ្លៃដដែល។ គូភាគីត្រូវបង់ថ្លៃសម្រាប់ពេលវេលារបស់មជ្ឈត្តករ បន្ទប់សវនាការថ្លៃរដ្ឋបាលនិងថ្លៃវិការធ្វើមជ្ឈត្តការ ព្រមទាំងថ្លៃដំណើរការកាត់ក្ដីធម្មតាផ្សេងទៀតដូចជា ថ្លៃជួលមេធាវី និងថ្លៃចំណាយដែលពាក់ព័ន្ធដទៃទៀត។ ជាទូទៅ ដំណើរការនេះមានតម្លៃថ្លៃជាងការចរចា ហើយជួនកាលថ្លៃជាងសន្ធានកម្មទៅទៀត។
- ល្បឿន៖ ទោះបីជាមជ្ឈត្តការ ជាទូទៅ ដំណោះស្រាយវិវាទឆាប់រហ័សជាងដំណើរការបណ្ដឹងតុលាការក៏ដោយ ក៏មជ្ឈត្តការអាចមានល្បឿនយឺតជាងការចរចា និងសន្ធានកម្មដែរ។ ជាធម្មតា គូភាគីត្រូវការពេលវេលាច្រើន ដើម្បីរៀបចំរឿងក្ដីរបស់ខ្លួនសម្រាប់ធ្វើមជ្ឈត្តការ បើប្រៀបធៀបនឹងការធ្វើសន្ធានកម្ម ឬការចរចា។
- អនុលោមភាពមានកម្រិតទាប៖ ដោយហេតុថាមជ្ឈត្តវិនិច្ឆ័យមិនមែនបានមកពីការចរចា និងការស្រុះស្រួលគ្នា ហេតុនេះគឺអាចមានលទ្ធភាពច្រើននៃការមិនអនុលោមតាមមជ្ឈត្តវិនិច្ឆ័យ។ ហេតុដូច្នេះហើយ គូភាគីអាចត្រូវចំណាយបន្ថែមកាន់តែច្រើនលើថ្លៃមេធាវី ដែលចាំបាច់បន្តសុំការអនុវត្តតាមប្រព័ន្ធតុលាការ។
- សវនាការជាអសាធារណៈ៖ ក្នុងស្ថានភាពខ្លះ ភាគីម្ខាងអាចចង់ឱ្យមានសវនាការជាសាធារណៈ ឧទាហរណ៍ ដូចជាដើម្បីការពារខ្លួនជាសាធារណៈប្រឆាំងនឹងការទាមទារ ឬដើម្បីដាក់ទណ្ឌកម្មភាគីម្ខាងទៀតឱ្យមានការអាម៉ាសមុខជាសាធារណៈជាដើម។ ដោយសារតែមជ្ឈត្តការមិនអនុញ្ញាតឱ្យមានចំណុចនេះទើបវាគឺជាគុណវិបត្តិដែលអាចនឹងកើតមានចំពោះគូភាគីនៅក្នុងស្ថានភាពជាក់លាក់មួយចំនួន។
- ការរក្សាទំនាក់ទំនង៖ ទោះបីជាមជ្ឈត្តការអាចរក្សាទំនាក់ទំនងរបស់គូភាគីបានប្រសើរជាងបណ្ដឹងតុលាការក៏ដោយ ក៏ទម្រង់នៃការដោះស្រាយវិវាទ ចំនួនពីរផ្សេងទៀត គឺការចរចា និងសន្ធានកម្មកាន់តែមានប្រសិទ្ធិភាពនៅក្នុងការរក្សាទំនាក់ទំនងរបស់គូភាគី។

[143] សៀវភៅដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មេធាវី ស៊ីវិន អ៊ែម អូស្ទ្រីមីឡឺរ៍ (បោះពុម្ពលើកទី២ ខែមករា ឆ្នាំ២០១០)។

- លទ្ធផលមិនប្រាកដប្រជាៈ ប្រសិនបើមជ្ឈត្តករបំពេញតួនាទីជាអ្នកជួយសម្រុះសម្រួល ពួកគេនឹងវិនិច្ឆ័យរឿងក្តីដោយផ្អែកលើគោលការណ៍សមភាព មិនចាំបាច់មានច្បាប់សម្រាប់គ្រប់គ្រងឡើយ។ ប្រការនេះ អាចនាំឱ្យមានលទ្ធផលមិនច្បាស់លាស់[144]។

[144] សៀវភៅដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មេធាវី ស្មីរិន អ៊ែម អូស្មើរមីឡឺរ៍ (បោះពុម្ពលើកទី២ ខែមករា ឆ្នាំ២០១០)។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាអំពីខ្លឹមសារទាំងមូល តាំងពីដើមរហូតដល់ចប់នៅក្នុងជំពូកនីមួយៗនៃអត្ថបទស្រាវជ្រាវមួយនេះមក យើងអាចទាញបាននូវសេចក្តីសន្និដ្ឋានបានថាការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ជាការដោះស្រាយវិវាទមួយបែបដែលមិនបានឆ្លងកាត់នីតិវិធីច្រើនសាំញ៉ាំដូចនៅស្ថាប័នតុលាការនោះទេ។ ហើយការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះទៀតសោធ មិនបាច់ចំណាយពេលវេលា និងចំណាយថវិកាច្រើននោះឡើយ ហើយសព្វថ្ងៃយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះឃើញថាមានភាពពេញនិយម និងមានប្រសិទ្ធិភាព អាចផ្តល់នូវភាពយុត្តិធម៌ជូនប្រជាពលរដ្ឋបានដោយមិនចាំបាច់ឆ្លងកាត់ស្ថាប័នតុលាការ ។

យន្តការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការយើងអាចធ្វើការដោះស្រាយបានតែប្រភេទវិវាទមួយចំនួនតែប៉ុណ្ណោះដូចជា៖ វិវាទរដ្ឋប្បវេណី វិវាទការងារ និងវិវាទផ្នែកពាណិជ្ជកម្ម។

ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការយើងមានបីចំណុចធំៗនេះដែលអាចធ្វើការយកមកដោះស្រាយបាន ដូចជាវិវាទរដ្ឋប្បវេណីសំដៅទៅលើវិវាទដែលពាក់ព័ន្ធទៅនឹងទំនាក់ទំនងទ្រព្យសម្បត្តិ (កម្មសិទ្ធ និងកិច្ចសន្យា)និងទំនាក់ទំនងញាតិ (អាពាហ៍ពិពាហ៍ និងសន្តតិកម្ម) ជាដើម។ វិវាទការងារសំដៅលើវិវាទដែលទាក់ទងទៅនឹងសិទ្ធិស្របច្បាប់ និងជាវិវាទដែលទាក់ទងទៅនឹងផលប្រយោជន៍ នាពេលអនាគត រវាងនិយោជក ឬនាយកសហគ្រាស ជាមួយនឹងកម្មករនិយោជិត។ ចំណែកវិវាទពាណិជ្ជកម្មទាក់ទងទៅនឹងការធ្វើពាណិជ្ជកម្ម ពាណិជ្ជកិច្ច ការទិញ លក់ផ្សេងៗក្នុងគោលដៅស្វែងរកផលចំណេញរៀងៗខ្លួន។ ម៉្យាងវិញទៀត បទល្មើសព្រហ្មទណ្ឌដូចជាបទហិង្សាស្រាលដែលត្រឹមតែជាបទលហុ ក៏អាចជាកម្មវត្ថុនៃការដោះស្រាយវិវាទតាមក្រៅប្រព័ន្ធតុលាការបានផងដែរ។

រាល់ការដោះស្រាយតាមរយៈការចរចា សន្ធានកម្ម ឬមជ្ឈត្តការប្រសិនបើគូភាគីវិវាទទាំងសងខាងមានការសះជានិងគ្នានឹងឈានទៅដល់ការធ្វើសេចក្តីសម្រេច ឬមជ្ឈត្តវិនិច្ឆ័យ ដែលត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរ និងចុះហត្ថលេខាដោយសម្លេងភាគច្រើននៃមជ្ឈត្តករ និងធ្វើការបញ្ជាក់អំពីហេតុផលដែលចេញមជ្ឈត្តវិនិច្ឆ័យព្រមទាំងបញ្ជាក់អំពីកាលបរិច្ឆេទ និងទីកន្លែងធ្វើមជ្ឈត្តការ ហើយភាគីនីមួយៗត្រូវទទួលបានមជ្ឈត្តវិនីច្ឆ័យដែលមានចុះហត្ថលេខាមួយច្បាប់។

រាល់ការស្រុះស្រួលដែលសម្រេចបានក្រោមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ត្រូវគោរពតាមលក្ខខណ្ឌតម្រូវដូចគ្នានេះ ដើម្បីធ្វើឱ្យមានអានុភាព និងប្រសិទ្ធិភាពជាសាលក្រម។ ការស្រុះស្រួលនោះក៏ត្រូវបញ្ជាក់ផងដែរថា វាគឺជាមជ្ឈត្តវិនិច្ឆ័យ។

# អនុសាសន៍

# អនុសាសន៍

ឆ្លងតាមការសិក្សាស្រាវជ្រាវនិងតាក់តែងអត្ថបទសារណាមួយនេះឡើងដែលជដែកពីប្រធានបទមួយនិយាយអំពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការរួចមក យើងខ្ញុំមានមតិយោបលមួយចំនួនដែលជាប្រយោជន៍សម្រាប់ប្រជាពលរដ្ឋទាក់ទងជាមួយនិងជីវិតរស់នៅប្រចាំថ្ងៃ ជាពិសេសទាក់ទងនិងវិវាទ និងដំណោះស្រាយវិវាទ។ ធម្មតាការរស់នៅក្នុងសង្គមរមែងតែងតែជួបនូវបញ្ហា ទំនាស់ផ្សេងៗ មិនថាតូច រឺធំ គឺជៀសមិនរួចឡើយ ហើយវាគឺមិនបានផ្តល់ផលល្អអ្វីដល់យើងនោះទេ ដូចច្នេះយើងគ្រប់គ្នាត្រូវចេះយោគយល់ អត់អោនអោយគ្នាទៅវិញទៅមកជៀសវាងបង្កជាជម្លោះផ្សេងៗ

យើងដឹងហើយថាក្នុងជីវភាពរស់នៅប្រចាំថ្ងៃតែងតែមានការប៉ះទង្គិចគ្នាបន្តិចបន្តួច ដែលវាជារឿងមួយតែងតែកើតមានជាញឹកញាប់មិនថាអ្នកមាន អ្នកក្រនោះឡើយ។ នៅពេលដែលកើតមាននូវទំនាស់ហ្នឹងគ្នា វានឹងឈានដល់ការប្តឹងផ្តល់គ្នាជាមិនខាន ហើយការប្តឹងផ្តល់គ្នាវានឹងនាំឱ្យបែកបាក់នូវចំណង់មិត្តភាពគ្នានឹងគ្នា ខាតបង់ទាំងថវិការ ទាំងពេលវេលាទាំងសងខាង។ យ៉ាងណាមិញ វិវាទអាចនាំឱ្យការប្រើប្រាស់នូវអំពើហឹង្សា រឺក៏អាចឈានដល់ការបង្កើតជាបទល្មើសធ្ងន់ធ្ងរ ឬបទឧក្រិដ្ឋជាដើម។ ដូចច្នេះនៅក្នុងការរស់នៅយើងត្រូវចេះយោគយល់ អធ្យាស្រ័យឱ្យគ្នា ត្រូវចេះរកដំណោះស្រាយដោយសន្តិវិធី ហើយនេះគឺជាបញ្ហាដែលយើងគួរតែយកចិត្តទុកដាក់ និងធ្វើការស្វែងយល់អោយបានស៊ីជម្រៅ។ មួយវិញទៀត រាល់ពេលដែលមានវិវាទកើតឡើងយើងត្រូវទុកឱ្យច្បាប់ជាអ្នករកដំណោះស្រាយតាមនីតិវិធីច្បាប់ យើងមិនត្រូវសម្រេចដោយឯកតោភាគីនោះទេ។

បន្ថែមពីនេះទៅទៀតនៅក្នុងការដោះស្រាយវិវាទ យើងមានពីរប្រភេទគឺការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ និងការដោះស្រាយតាមក្រៅប្រព័ន្ធតុលាការ។ ជាទូទៅ ការដោះស្រាយវិវាទភាគច្រើនគេតែងយល់ថាជាសមត្ថកិច្ចរបស់ស្ថាប័នតុលាការជាអ្នកដោះស្រាយ ប៉ុន្តែក្រៅពីប្រព័ន្ធតុលាការយើងក៏មាននូវយន្តការដោះស្រាយវិវាទនៅក្រៅប្រព័ន្ធតុលាការបានផងដែរ ដែលគេហៅថា ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ នៅពេលដែលមានវិវាទកើតឡើងភាគីវិវាទអាចជ្រើសរើសយកយន្តការដោះស្រាយវិវាទនៅក្រៅប្រព័ន្ធតុលាការដើម្បីធ្វើការផ្តល់ដំណោះស្រាយជូនខ្លួនជាមុនសិន មុនឈានទៅដល់ការដោះស្រាយដោយប្រព័ន្ធតុលាការ។ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការគឺជាវិធីសាស្ត្រមួយដែលល្អសម្រាប់ភាគីវិវាទដូចជា កាត់បន្ថយការចំណាយផ្សេងៗ ចំណេញពេលវេលា ប្រើរយះពេលខ្លី និងមិនមាននីតិវិធីសាំញ៉ាំច្រើនជាដើម។

វិវាទគឺជារឿងចម្រូងចម្រាសរវាងភាគីម្ខាងនិងភាគីម្ខាងទៀត ហើយនៅពេលដែលមានវិវាទមួយកើតឡើងយើងគួរតែនិយាយគ្នាដោយសន្តិវិធីជៀសវាងការប្រើប្រាស់អំពើហិង្សាទៅដោះស្រាយបញ្ហា។ ពេលខ្លះអាចឈានទៅដល់រឿងឃាតកម្មក៏មាន ដោយប្រែក្លាយពីរឿងរដ្ឋប្បវេណីទៅជារឿងព្រហ្មទណ្ឌទៅវិញគឺវាគ្មានផលប្រយោជន៍សម្រាប់គូភាគីនោះទេ គឺមានតែការខាតបង់ដ៏ធ្ងន់ធ្ងរតែប៉ុណ្ណោះ។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានជាតិ


1. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
2. ច្បាប់ស្តីពីមជ្ឈត្តការពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦
3. ច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧
4. ក្រមរដ្ឋប្បវេណី លេខនស.រកម.១២០៧/០៣១. ០៨ ធ្នូ ២០០៧
5. ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦
6. អនុសញ្ញាក្រុងឡាអេស្តីពីការជ្រើសរើសកិច្ចព្រមព្រៀងតុលាការ
7. ព្រះរាជក្រឹតស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ (១៩៩៩) និងព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងតុលាការ (២០០២)
8. អនុក្រឹតស្តីពីវិមជ្ឈការនៃតួនាទី មុខងារ និងអំណាចដល់ក្រុមប្រឹក្សាឃុំ (២០០២)
9. ការដោះស្រាយវិវាទដោយបង្ខំ គឺជាការដោះស្រាយវិវាទតាមផ្លូវតុលាការ។
10. ប្រកាសស្តីពីនីតិវិធីនៃការដោះស្រាយវិវាទបុគ្គល, លេខ៣១៨សកបយ, ២៩ វិច្ឆិកា ២០០១។
11. សេចក្តីព្រាងច្បាប់ ស្តីពីនីតិវិធីជម្រះក្តីវិវាទការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ថ្ងៃ២៥ ខែសីហា ឆ្នាំ២០១៧
12. ប្រកាស ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទបុគ្គល លេខ៣១៧សកបយ, ២៩ វិច្ឆិកា ២០០១។
13. ប្រកាស ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទរួម, លេខ៣១៧សកបយ, ២៩ វិច្ឆិកា ២០០១។
14. វិធានស្តីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១
15. វិធានការដោះស្រាយវិវាទក្រៅដោយខ្លួនឯង ជាវិធីដោះស្រាយជម្លោះដោយស្ម័គ្រចិត្ត និងដោយឆន្ទានុសិទ្ធិរបស់ភាគី ដែលត្រូវបានគេហៅថា ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។


## ឯកសារជាសៀវភៅ និងអត្ថបទផ្សេងៗ


1. មេធាវី ស្ទីវិន អ៊ែម អូស្ទើរមីឡឺរ៍ សៀវភៅសិក្សាស្តីពីទស្សនទានសំខាន់ៗ ៖ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅកម្ពុជា។
2. សៀវភៅមេរៀន ដោះស្រាយវិវាទពាណិជ្ជកម្ម សាស្ត្រាចារ្យ ជ័យ រិទ្ធី។
3. សៀវភៅមេរៀន នីតិពាណិជ្ជកម្ម សាស្ត្រាចារ្យ កង់ ស៊ីផាន់ណារ៉ា។
4. Auster miller, សន្ទានការីដែលពុករលួយនៅតែអាចព្យាយាមបង្ខំឱ្យភាគីព្រមព្រៀង តាមរយៈឧបាយកលដោះស្រាយខ្លួន ឬការបង្ខិតបង្ខំ។
5. Kong, "Overview of the Cambodian Legal and Judicial System and Recent Efforts at Legal and Judicial Reform".
6. ជួប បិតបេរឫទ្ធិ ដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ។

# គេហទំព័រ


1. http://www.wpro.who.int/countries/khm/en/
2. http://devdata.worldbank.org/external/CPProfile.asp?
3. https://www.thehrdaily.com/management-and-leadership/what-is-a-labor-dispute-and-what-if-employees-sue-your-company/?fbclid=IwAR0LYAinvkcGNsdwOlXm2TMK-1LXSNgPfgm5nlF086nbyjbOlCquQXjbsbI
4. https://www.khsearch.com/qna/13617?fbclid=IwAR0FlXjDRWoo75e7weAFlxFk97TpVik6R7-9C_GqAs71H07VAsg7iqlBM9k
5. http://www.nadrac.gov.au/agd/www/Disputeresolutionhom.nsf/Page/RWP7E251CA71B8E7700CA256BD100135550?
6. http://1.1.1.1/467929504/472002888T080531121212.txt.binXMysM0dapplication/pdfXsysM0dhttp://wwwnadrac.gov.au/agd/WWW/rwpattach.nsf/VAP/(CFD7369FCAE9B8F32F341DBE097801FF)-1 Report8 6D ec.pdf/$file/1Report8_6Dec.pdf
7. http://www.hcch.net/index_en.php?act=conventions.text&cid=98

# ឧបសម្ព័ន្ធទី១

# ឧបសម្ព័ន្ធទី១

**ឧបសម្ព័ន្ធ ៖ ការស្ទង់មតិមន្ត្រីផ្សះផ្សា**

សំនួរទី១៖ ក្នុងអំឡុងពេលផ្សះផ្សា អ្នកផ្សះផ្សាបានស្វែងរកដំណោះស្រាយផ្សះផ្សាដោយផ្អែកលើច្បាប់ , វិធានការផ្ទៃក្នុងរបស់សហគ្រាស ,កិច្ចព្រមព្រៀងសមូហភាព ឬកិច្ចសន្យាការងារជាបុគ្គល ?

| ក.ញឹកញាប់ខ្លាំង | ខ.ច្រើនដងដែរ | គ.គួរសមដែរ | ឃ.មិនសូវប៉ុន្មានទេ | ង.មិនដែលសោះ |
|---|---|---|---|---|
| ៣៥% | ២៩% | ២៤% | ៦% | ០% |

សំនួរទី២៖ ប្រសិនបើចម្លើយអ្នកមិនមែន ក តើអ្នកពឹងផ្អែកលើអ្វីដើម្បីឈានទៅកាន់ដំណោះស្រាយក្នុងការធ្វើការផ្សះផ្សាឱ្យភាគីវិញ?

ចម្លើយ៖ ផ្អែកទៅលើសមធម៌, វិធីសាស្ត្រសម្របសម្រួល ,និងការស្រុះស្រួលគ្នា

សំនួរទី៣៖ ក្នុងអំឡុងពេលផ្សះផ្សា តើអ្នកធ្លាប់ធ្វើការដាក់សំណើទៅកាន់ភាគីនូវដំណោះស្រាយដើម្បីឈានទៅកាន់ការសះជាដែរឬទេ?

| ក.ញឹកញាប់ខ្លាំង | ខ.ច្រើនដងដែរ | គ.គួរសមដែរ | ឃ.មិនសូវប៉ុន្មានទេ | ង.មិនដែលសោះ |
|---|---|---|---|---|
| ៤១% | ២៩% | ៦% | ២៥% | ០% |

សំនួរទី៤៖ ប្រសិនបើចម្លើយអ្នកមិនមែន ក តើអ្នកបានប្រើប្រាស់មូលដ្ឋានអ្វីដើម្បីធ្វើការសះជា ឬ ឈានទៅរកការបញ្ចប់វិញ?

ចម្លើយ៖ ឱ្យជម្រើសផ្សេងទៀតភាគីវិវាទដែលមិនផ្អែកលើច្បាប់, ឬឱ្យភាគីបង្កើតជម្រើសដោយខ្លួនឯងទៅតាមអ្វីដែលចង់បានដើម្បីឈានទៅរកដំណោះស្រាយ

សំនួរទី៥៖ តើអ្នកលើកទឹកចិត្ត ឬមួយជំរុញឲ្យភាគីវិវាទឱ្យយល់ស្របទៅតាមការលើកឡើងទៅតាមការណែនាំរបស់អ្នកដែរឬទេ?

| ក.ញឹកញាប់ខ្លាំង | ខ.ច្រើនផងដែរ | គ.គួរសមដែរ | ឃ.មិនសូវប៉ុន្មានទេ | ង.មិនដែលសោះ |
|---|---|---|---|---|
| ២៤% | ៣៥% | ១៨% | ១៨% | ៦% |

សំនួរទី៦៖ក្នុងអំឡុងពេលផ្សះផ្សា តើភាគីធ្លាប់ស្នើអ្នកឱ្យផ្ដល់ដំបូន្មានច្បាប់ណា ដែលទាក់ទិនទៅនឹងជម្លោះរបស់ពួកគេដែរឬទេ?

| ក.ញឹកញាប់ខ្លាំង | ខ.ច្រើនផងដែរ | គ.គួរសមដែរ | ឃ.មិនសូវប៉ុន្មានទេ | ង.មិនដែលសោះ |
|---|---|---|---|---|
| ២៤% | ៣៥% | ១៨% | ២៤% | ០% |

សំនួរទី៧៖ នៅក្នុងអំឡុងពេលផ្សះផ្សា តើភាគីព្យាយាមស្វែងរកដំណោះស្រាយដោយខ្លួនឯងឬអ្នកផ្សះផ្សាជាអ្នកព្យាយាមស្វែងរកដំណោះស្រាយដើម្បីបញ្ចប់ជម្លោះ?

| |
|---|
| ក.ភាគីគ្រប់ពេលតែងតែស្វែងរកដំណោះស្រាយដោយខ្លួនឯងដើម្បីបញ្ចប់ជម្លោះ ០% |
| ខ.ភាគីស្ទើរគ្រប់ពេលស្វែងរកដំណោះស្រាយដោយខ្លួនឯងដើម្បីបញ្ចប់ជម្លោះ ០% |
| គ.ភាគីពេលខ្លះស្វែងរកដំណោះស្រាយដោយខ្លួនឯងដើម្បីបញ្ចប់ជម្លោះ ៤១% |
| ឃ.អ្នកផ្សះផ្សាតែងតែស្វែងរកដំណោះស្រាយឱ្យ ដើម្បីបញ្ចប់ជម្លោះ ៤៧% |
| ង.អ្នកផ្សះផ្សាស្ទើរគ្រប់ពេលស្វែងរកដំណោះស្រាយឱ្យ ដើម្បីបញ្ចប់ជម្លោះ ១២% |

# ឧបសម្ព័ន្ធទី២

# ឧបសម្ព័ន្ធទី២

ឆ្នាំ ទី ៦ លេខ ៣៧ សប្តាហ៍ ទី ៣ ថ្ងៃ ទី ១៩ ខែ ឧសភា ឆ្នាំ ២០០៦ រាជកិច្ច ទំព័រ ៣០០០

## ព្រះរាជក្រម

នស/រកម/០៥០៦/០១០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបុណ្ណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីមជ្ឈត្តការថ្លៃពាណិជ្ជកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ដើម្បី ពិនិត្យច្បាប់នេះឱ្យទាន់តាមកាលកំណត់របស់មាត្រា១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ និងដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញតាមសេចក្តីសម្រេចលេខ ០៧៥/០០២/២០០៦ កបធ.ច ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងសម្រួលដល់ការដោះស្រាយជាបន្ទាន់ តាមការផ្សះផ្សានូវវិវាទពាណិជ្ជកម្មដែលកើតមានឡើងក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមការស្ម័គ្រចិត្តរបស់ភាគីវិវាទ ដើម្បីការពារសិទ្ធិនិងផលប្រយោជន៍នៃភាគីវិវាទទាំងនេះ និងដើម្បីលើកស្ទួយការអភិវឌ្ឍន៍សេដ្ឋកិច្ច ។

ច្បាប់នេះមិនប៉ះពាល់ដល់អានុភាពគតិយុត្តិនៃច្បាប់នានាឯទៀតរបស់ព្រះរាជាណាចក្រកម្ពុជាដែលនៅក្នុងនោះ ករណីវិវាទខ្លះផ្សះផ្សាបាន ឬ ដោះស្រាយបានតាមនីតិវិធីផ្សេងៗទៀត និងវិវាទខ្លះទៀតផ្សះផ្សាមិនបាន ។

**មាត្រា ២.-**

និយមន័យ និងវិធាននៃការបកស្រាយពាក្យដែលប្រើក្នុងច្បាប់នេះ :

ក- "មជ្ឈត្តការ" គឺជាការផ្សះផ្សាវិវាទដោយប្រើប្រាស់វេទិកាមជ្ឈត្តកម្ម ហើយអាចស្ថិតនៅក្នុង ឬ នៅក្រៅក្របខ័ណ្ឌនៃការគ្រប់គ្រងរបស់ស្ថាប័នផ្សះផ្សាអចិន្ត្រៃយ៍ ។

ខ- "វេទិកាមជ្ឈត្តកម្ម" គឺជាមជ្ឈត្តករមួយនាក់ ឬ មួយក្រុម ។

គ- "តុលាការ" គឺជាស្ថាប័ន ឬ អង្គការនៃប្រព័ន្ធតុលាការរបស់ប្រទេសមួយ ។

ឃ- "កិច្ចព្រមព្រៀងផ្សះផ្សា" ជាកិច្ចព្រមព្រៀងរវាងភាគីវិវាទក្នុងការធ្វើមជ្ឈត្តការវិវាទទាំងអស់ ឬ វិវាទបែបណាមួយដែលកើតឡើង ឬ ដែលអាចកើតឡើងរវាងភាគីវិវាទនានា ដោយគោរពតាមទំនាក់ទំនងកំណត់ដោយច្បាប់ ទោះបីជាមានកិច្ចសន្យា ឬ គ្មានក៏ដោយ ។

ង-ក្រៅពីមាត្រា ៣៦ កាលណាបទប្បញ្ញត្តិនានានៃច្បាប់នេះទុកសេរីភាពឱ្យភាគីវិវាទកំណត់ពីបញ្ហាណាមួយ សេរីភាពនេះគឺរាប់បញ្ចូលទាំងសិទ្ធិរបស់ភាគីវិវាទក្នុងការអនុញ្ញាតឱ្យមានភាគីទី ៣ រួមបញ្ចូលទាំងស្ថាប័នមួយ ដើម្បីធ្វើការសម្រេចលើបញ្ហានោះ ។

ច-ក្នុងករណីដែលបទប្បញ្ញត្តិនៃច្បាប់នេះ យោងតាមអ្វីដែលភាគីវិវាទបានព្រមព្រៀង ឬ អាចនឹងព្រមព្រៀងគ្នា ឬ យោងតាមមធ្យោបាយផ្សេងទៀតនៃកិច្ចព្រមព្រៀងរបស់ភាគីវិវាទ កិច្ចព្រមព្រៀងនោះ ។

ឆ-ក្រៅពីមាត្រា ៣៣ (១) និងមាត្រា ៤០ (១) នៃច្បាប់នេះ កាលណាបទប្បញ្ញត្តិនៃច្បាប់នេះយោងតាមការប្តឹងទាមទារ បទប្បញ្ញត្តិនោះក៏ត្រូវអនុវត្តចំពោះការប្តឹងទាមទារបកវិញដែរ ហើយនៅពេលដែលយោងតាមការដោះសាពីការប្តឹងទាមទារ ក៏ត្រូវអនុវត្តចំពោះការដោះសាពីការប្តឹងទាមទារបកវិញដែរ ។

ជ-មជ្ឈត្តការមានលក្ខណៈជា "អន្តរជាតិ" ក្នុងករណី :

ជ.១-ភាគីវិវាទ និងកិច្ចព្រមព្រៀងផ្សះផ្សាមានទីកន្លែងធ្វើពាណិជ្ជកម្មនៅក្នុងប្រទេសផ្សេងពីគ្នា ក្នុងពេលសម្រេចកិច្ចព្រមព្រៀងនោះ ឬ

ជ.២-ទីកន្លែងមួយក្នុងចំណោមទីកន្លែងខាងក្រោមនោះ ស្ថិតនៅក្រៅប្រទេសធ្វើពាណិជ្ជកម្មរបស់ភាគីវិវាទ :

-ទីកន្លែងធ្វើមជ្ឈត្តការ : ប្រសិនបើបានកំណត់ ឬ តាមយោងក្នុងកិច្ចព្រមព្រៀងផ្សះផ្សា ។

-ទីកន្លែងដែលកាតព្វកិច្ចសំខាន់នៃទំនាក់ទំនងពាណិជ្ជកម្មបានប្រព្រឹត្តទៅ ឬ ទីកន្លែងជិតជាងគេនៃរឿងពាក់ព័ន្ធនឹងវិវាទ ។

ជ.៣-ភាគីវិវាទបានព្រមព្រៀងជាក់លាក់ថា រឿងនៃកិច្ចព្រមព្រៀងផ្សះផ្សាទាក់ទងទៅនឹងប្រទេសលើសពីមួយ ។

ជ.៤-តាមគោលបំណងក្នុងកថាខណ្ឌ (ជ) នេះ :

-ប្រសិនបើភាគីវិវាទមួយមានទីកន្លែងប្រកបពាណិជ្ជកម្មលើសពីមួយកន្លែង ទីកន្លែងដែលមានទាក់ទងជិតស្និទ្ធជាងគេបំផុតទៅនឹងកិច្ចព្រមព្រៀងផ្សះផ្សាគឺជាទីកន្លែងពាណិជ្ជកម្ម ។

-ប្រសិនបើភាគីវិវាទមួយមិនមានទីកន្លែងប្រកបពាណិជ្ជកម្មទេ ការយោងក្នុងច្បាប់នេះគឺទីលំនៅអចិន្ត្រៃយ៍របស់ភាគីនោះ ។

ឈ-ពាក្យថា "ពាណិជ្ជកម្ម" ត្រូវបកស្រាយឱ្យបានទូលំទូលាយ ដើម្បីគ្របដណ្តប់លើធុរកិច្ចដែលមានប្រភេទជាពាណិជ្ជកម្ម ទោះបីជាមានកិច្ចសន្យា ឬ គ្មានកិច្ច

សន្យាក៏ដោយ ។ ធុរកិច្ចដែលមានប្រភេទជាពាណិជ្ជកម្មមានជាអាទិ៍ : កិច្ចការជំនួញដើម្បីផ្គត់ផ្គង់ ឬ ការផ្លាស់ប្តូរទំនិញ ឬ សេវាផ្សេងៗ កិច្ចព្រមព្រៀងនៃការចែកចាយតំណាង ឬ ទីភ្នាក់ងារពាណិជ្ជកម្ម ការទិញ-លក់គណនីក្រុមហ៊ុន ការជួលទីតាំង ឬ សម្ភារៈវត្ថុ ការងារស្ថាបនា ការពិគ្រោះយោបល់ វិស្វកម្ម ការចេញអាជ្ញាប័ណ្ណ ការវិនិយោគទុន ការផ្តល់ហិរញ្ញវត្ថុ ការធ្វើអាជីវកម្មធនាគារ ការធានារ៉ាប់រង កិច្ចព្រមព្រៀងធ្វើអាជីវកម្ម ឬ សម្បទាន ក្រុមហ៊ុនចំរុះ និងប្រភេទផ្សេងៗទៀតនៃសហប្រតិបត្តិការឧស្សាហកម្ម ឬ ពាណិជ្ជកម្ម និងការដឹកជញ្ជូនទំនិញ ឬ អ្នកដំណើរតាមផ្លូវអាកាស ផ្លូវទឹក ផ្លូវគោក ។

**មាត្រា ៣.-**

លើកលែងតែភាគីទាំងអស់បានព្រមព្រៀងផ្សេងពីនេះ :

១-លិខិតឆ្លើយឆ្លងជាលាយលក្ខណ៍អក្សរ ត្រូវចាត់ទុកថាបានទទួល ក្នុងករណីដែលបានប្រគល់ឱ្យអ្នកទទួលដោយផ្ទាល់ដៃ ឬ ប្រគល់ដល់កន្លែងប្រកបពាណិជ្ជកម្ម ឬ ទីលំនៅអចិន្ត្រៃយ៍ ឬ អាសយដ្ឋានប្រៃសណីយ៍របស់អ្នកទទួល ។ ប្រសិនបើរកកន្លែងទាំងនោះមិនឃើញទេ ក្រោយពីការស្វះស្វែងរកយ៉ាងល្អិតល្អន់រួចមក លិខិតឆ្លើយឆ្លងជាលាយលក្ខណ៍អក្សរ ត្រូវចាត់ទុកថាបានទទួលក្នុងករណីបានផ្ញើតាមរយៈលិខិតអនុសិដ្ឋ ឬ តាមមធ្យោបាយផ្សេងៗដែលផ្តល់ហេតុផលថា ពិតជាបានខំប្រឹងប្រែងប្រគល់លិខិតទៅដល់កន្លែងប្រកបពាណិជ្ជកម្ម ឬ ទីលំនៅអចិន្ត្រៃយ៍ ឬ អាសយដ្ឋានរបស់អ្នកទទួលដែលស្គាល់ចុងក្រោយបំផុត ។

២-បទប្បញ្ញត្តិនានាក្នុងមាត្រា ៣ នៃច្បាប់នេះ មិនយកទៅអនុវត្តលើលិខិតឆ្លើយឆ្លងក្នុងពេលដំណើរការកាត់ក្តីរបស់តុលាការទេ ។

**មាត្រា ៤.-**

ត្រូវបានចាត់ទុកថាបានបោះបង់សិទ្ធិជំទាស់របស់ខ្លួន ប្រសិនបើភាគីវិវាទមួយបានដឹងថាភាគីវិវាទផ្សេងទៀត អាចប្រព្រឹត្តខុសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬ ពុំគោរពតាមការតម្រូវរបស់កិច្ចព្រមព្រៀងផ្សះផ្សា ប៉ុន្តែភាគីវិវាទនោះនៅតែបន្តដំណើរការមជ្ឈត្តការដោយមិនបានជំទាស់ទៅនឹងការមិនគោរពនោះ ហើយក្នុងករណីដែលមានចែងពីរយៈពេលកំណត់សម្រាប់ការជំទាស់ ភាគីវិវាទនោះពុំបានធ្វើការពន្យារពេលជាចាំបាច់ ។

**មាត្រា ៥.-**

នៅក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ តុលាការធ្វើអន្តរាគមន៍បានតែក្នុងករណីទាំងឡាយណាដែលច្បាប់នេះបានចែង ។

**មាត្រា ៦.-**

មុខងារផ្សេងៗដែលមានចែងក្នុងមាត្រា ១៩ កថាខណ្ឌទី ៣, ៤ និង ៥ មាត្រា ២១ កថាខណ្ឌទី ៣ មាត្រា ២២ មាត្រា ២៤ កថាខណ្ឌទី ៣ នៃច្បាប់នេះ ត្រូវបំពេញដោយតុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ។

## ជំពូកទី ២
## កិច្ចព្រមព្រៀងផ្សះផ្សា

**មាត្រា ៧.-**

កិច្ចព្រមព្រៀងផ្សះផ្សារួមមានខចែងស្តីពីមជ្ឈត្តការដែលបានចែងនៅក្នុងកិច្ចសន្យា ឬ ក្នុងកិច្ចព្រមព្រៀងដោយឡែក ។

កិច្ចព្រមព្រៀងផ្សះផ្សាត្រូវសរសេរជាលាយលក្ខណ៍អក្សរ ។ ដែលហៅថាកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ គឺជាកិច្ចព្រមព្រៀងដែលស្ថិតនៅក្នុងឯកសារចុះហត្ថលេខាដោយភាគីវិវាទ ឬ ដែលស្ថិតនៅក្នុងការផ្ញើរលិខិតឆ្លាស់ ឬ មធ្យោបាយទូរគមនាគមន៍តាមប្រព័ន្ធអេឡិចត្រូនិច ដែលផ្តល់កំណត់ត្រាបញ្ជាក់ពីការព្រមព្រៀងគ្នា ឬ ដែលស្ថិតនៅក្នុងការប្តូរគ្នាទៅវិញទៅមកនូវពាក្យទាមទារ ឬ ពាក្យដោះសាដែលក្នុងនោះ ភាគីវិវាទមួយបានទាមទារ ហើយមិនត្រូវបានបដិសេធដោយភាគីវិវាទម្ខាងទៀត ។ សេចក្តីយោងក្នុងកិច្ចសន្យា និង ឯកសារមួយដែលមានប្រការស្តីពីមជ្ឈត្តការអាចក្លាយជាកិច្ចព្រមព្រៀងផ្សះផ្សាបានល្គិកណាកិច្ចសន្យានោះសរសេរជាលាយលក្ខណ៍អក្សរ ហើយសេចក្តីយោងនោះគឺជាប្រការដែលក្លាយជាផ្នែកមួយនៃកិច្ចសន្យា ។

**មាត្រា ៨.-**

នៅពេលដោះស្រាយបណ្តឹងវិវាទ តុលាការដែលទទួលដោះស្រាយវិវាទដែលជាកម្មវត្ថុកិច្ចព្រមព្រៀងផ្សះផ្សា ត្រូវបញ្ជូនភាគីវិវាទទៅធ្វើមជ្ឈត្តការ ប្រសិនបើមានសំណើពីភាគីវិវាទមួយ វៀរលែងតែតុលាការនោះរកឃើញថាកិច្ចព្រមព្រៀងផ្សះផ្សានោះត្រូវចាត់ទុកជាមោឃៈ ឬ មិនអាចអនុវត្តបាន ។

ទោះបីជាមានបណ្តឹងទាមទារទៅតុលាការដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះក៏ដោយ ក៏ដំណើរការរបស់វេទិកាមជ្ឈត្តកម្មអាចចាប់ផ្តើម ឬ បន្តដំណើរការបានតទៅទៀត ហើយតុលាការត្រូវបង្វែរសមត្ថកិច្ចជូនទៅវេទិកាមជ្ឈត្តកម្មវិញ ដោយរង់ចាំការសម្រេចរបស់វេទិកាមជ្ឈត្តកម្ម ។

**មាត្រា ៩.-**

នៅមុនពេល ឬ ក្នុងពេលកំពុងដំណើរការមជ្ឈត្តការ ការធ្វើសំណូមពររបស់ភាគីវិវាទមួយទៅតុលាការឱ្យផ្តល់វិធានការបណ្តោះអាសន្ន ដើម្បីការពារ និងការផ្តល់នូវវិធានការទាំងនោះដោយតុលាការពុំមានវិសមិតភាពជាមួយកិច្ចព្រមព្រៀងផ្សះផ្សាឡើយ ។

## ជំពូកទី ៣

## មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

**មាត្រា ១០.-**

ត្រូវបានបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការមួយឯករាជ្យ នៅក្រោមការឧបត្ថម្ភរបស់ក្រសួងពាណិជ្ជកម្ម ។ គោលបំណងនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការគឺ :

១-ជម្រុញការដោះស្រាយវិវាទពាណិជ្ជកម្ម តាមរយៈការផ្សះផ្សានៅក្នុងព្រះរាជាណាចក្រកម្ពុជា

២-បង្កើតរចនាសម្ព័ន្ធ និងវិធានចាំបាច់សម្រាប់គ្រប់គ្រងរឿងមជ្ឈត្តការនៅក្នុងព្រះរាជាណាចក្រកម្ពុជានៅពេលដែលកិច្ចព្រមព្រៀងជាក់ច្បាស់មួយនៃភាគីវិវាទ ដាក់វិវាទទៅមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ

៣-ធានាឱ្យមជ្ឈត្តការនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានគុណភាពខ្ពស់ ។ គោល

ម/២៩៨

បំណងនេះរួមបញ្ចូលការកំណត់ស្តង់ដាសម្រាប់លក្ខណៈសម្បត្តិរបស់មជ្ឈត្តករ ។

**មាត្រា ១១.–**

រូបវន្តបុគ្គលមានសញ្ជាតិខ្មែរ ឬ បរទេសដែលជាមជ្ឈត្តករត្រូវចុះបញ្ជីនៅមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ។ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការមានភារកិច្ចកំណត់ពីលក្ខណៈសម្បត្តិរបស់មជ្ឈត្តករ ហើយត្រូវធ្វើសេចក្តីប្រកាសជាសាធារណៈនូវបញ្ជីឈ្មោះមជ្ឈត្តករជារៀងរាល់ឆ្នាំ ។ បញ្ជីនេះមិនមានលក្ខណៈដាច់ណាត់ទេ ភាគីវិវាទអាចជ្រើសរើសមជ្ឈត្តករក្រៅពីបញ្ជីក៏បាន ។

**មាត្រា ១២.–**

អាចសុំចូលជាសមាជិកមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការបាន រូបវន្តបុគ្គល និងនីតិបុគ្គល ដូចខាងក្រោម ៖

-រូបវន្តបុគ្គលជាមជ្ឈត្តករដែលបានចុះឈ្មោះក្នុងបញ្ជីរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ

-សភាពាណិជ្ជកម្ម

-គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

-រាល់សមាគមដែលប្រមូលផ្តុំពាណិជ្ជករ ឧស្សាហករ អាជីវករ និង សេវាករ ។

សំណើសុំចូលជាសមាជិកមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ត្រូវបានពិនិត្យដោយក្រុមប្រឹក្សាប្រតិបត្តិនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការដែលមានចំនួនមិនលើសពីប្រាំពីរ (៧) នាក់ ។ សមាជិកក្រុមប្រឹក្សាប្រតិបត្តិមានអាណត្តិរយៈពេលបី (៣) ឆ្នាំ ហើយអាចឈរឈ្មោះបន្តមួយអាណត្តិទៀតបាន ។

**មាត្រា ១៣.–**

សភាពាណិជ្ជកម្មអាចរៀបចំមជ្ឈមណ្ឌលមជ្ឈត្តកម្មមួយនៅភ្នំពេញ ។ រាល់សមាគមដែលប្រមូលផ្តុំពាណិជ្ជករ ឧស្សាហករ អាជីវករ និងសេវាករ អាចបង្កើតមជ្ឈមណ្ឌលមជ្ឈត្តកម្មរបស់ខ្លួនដោយឡែកសម្រាប់ដោះស្រាយវិវាទរវាងសមាជិក និងរវាងសមាជិកជាមួយអ្នកដទៃ ។

**មាត្រា ១៤.-**

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ត្រូវគ្រប់គ្រងដោយ :

-មហាសន្និបាត

-ក្រុមប្រឹក្សាប្រតិបត្តិ ។

ភារកិច្ចសំខាន់ៗរបស់មហាសន្និបាតមាន :

-ប្រជុំមួយដង ឬ ពីរដងក្នុងមួយឆ្នាំ តាមការអញ្ជើញរបស់ប្រធានមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ឬ តាមសំណើរបស់សមាជិកភាគច្រើននៃក្រុមប្រឹក្សាប្រតិបត្តិ ។

-ជ្រើសតាំងក្រុមប្រឹក្សាប្រតិបត្តិ

-ពិនិត្យរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាប្រតិបត្តិ

-សម្រេចលើស្ថានភាពហិរញ្ញវត្ថុរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ

-កំណត់សោហ៊ុយ ដែលជាតម្លៃនៃការធ្វើមជ្ឈត្តការ

-ពិនិត្យសម្រេចលើរាល់សំណើកែប្រែលិខិតបទដ្ឋានដែលទាក់ទងដល់ដំណើរការមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ និងដំណើរការមជ្ឈត្តការ ។

-បំពេញភារកិច្ចផ្សេងទៀត ដែលកំណត់ដោយអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ។

**មាត្រា ១៥.-**

មហាសន្និបាតរួមប្រជុំដោយសមាជិកជារូបវន្តបុគ្គល និងតំណាងមួយរូបរបស់សមាជិកជានីតិបុគ្គលនីមួយៗ ។

**មាត្រា ១៦.-**

សមាសភាពក្រុមប្រឹក្សាប្រតិបត្តិដែលគ្រប់គ្រងមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការត្រូវបានបោះឆ្នោតជ្រើសតាំងក្នុងចំណោមសមាជិកដោយមហាសន្និបាត ។ ប្រធានក្រុមប្រឹក្សាប្រតិបត្តិ គឺជាប្រធានរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ។

**មាត្រា ១៧.-**

ការរៀបចំ និងការប្រព្រឹត្តិទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៤
## សមាសភាពនៃវេទិកាមជ្ឈត្តកម្ម

**មាត្រា ១៨.-**

ភាគីវិវាទមានសិទ្ធិកំណត់ចំនួនមជ្ឈត្តករនៃវេទិកាមជ្ឈត្តកម្ម ។ មជ្ឈត្តករត្រូវមានចំនួនសេស ។

បើគ្មានការកំណត់ពីភាគីវិវាទទេ មជ្ឈត្តករត្រូវមានចំនួនបី (៣) នាក់ ។

**មាត្រា ១៩.-**

ការជ្រើសតាំងមជ្ឈត្តករត្រូវអនុវត្តតាមបែបបទដូចខាងក្រោម :

១-មិនត្រូវបដិសេធជនណាម្នាក់មិនឱ្យធ្វើមជ្ឈត្តករ ដោយសារមូលហេតុនៃសញ្ជាតិរបស់គេឡើយ លើកលែងតែភាគីវិវាទ បានព្រមព្រៀងផ្សេងពីនេះ ។

២-ភាគីវិវាទអាចព្រមព្រៀងលើនីតិវិធីនៃការតែងតាំងមជ្ឈត្តករមួយ (១) នាក់ ឬ ច្រើននាក់ យោងតាមបទប្បញ្ញត្តិក្នុងកថាខណ្ឌទី ៤ និងកថាខណ្ឌទី ៥ នៃមាត្រានេះ ។

៣-ករណីមិនបានព្រមព្រៀងពីនីតិវិធីនេះ :

ក-ក្នុងការធ្វើមជ្ឈត្តការដែលមានមជ្ឈត្តករបី (៣) នាក់ ភាគីវិវាទនីមួយៗ ត្រូវជ្រើសតាំងមជ្ឈត្តករមួយ (១) នាក់ ហើយមជ្ឈត្តករទាំងពីរនាក់នេះ ត្រូវជ្រើសតាំងមជ្ឈត្តករទីបី ។ ប្រសិនបើភាគីវិវាទណាមួយពុំបានជ្រើសតាំងមជ្ឈត្តករក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ក្រោយពេលទទួលសំណើជ្រើសតាំងពីភាគីវិវាទម្ខាងទៀត ឬ ប្រសិនបើមជ្ឈត្តករទាំងពីរ (២) នាក់ ពុំបានព្រមព្រៀងលើការតែងតាំងមជ្ឈត្តករទីបីក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ក្រោយពីត្រូវបានគេជ្រើសតាំងរួចមក តុលាការ ( តុលាការពាណិជ្ជ-កម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជ-

កម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ត្រូវជ្រើសតាំងមជ្ឈត្តករទី ៣ តាមការស្នើសុំនៃភាគីវិវាទណាមួយ ។

ខ-ក្នុងការធ្វើមជ្ឈត្តការដែលមានមជ្ឈត្តករតែមួយនាក់ ប្រសិនបើភាគីវិវាទមិនអាចព្រមព្រៀងលើការជ្រើសតាំងមជ្ឈត្តករនេះទេនោះ តុលាការ (តុលាការ ពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះត្រូវជ្រើសតាំងមជ្ឈត្តករតាមសំណូមពររបស់ភាគីវិវាទណាមួយ ។

៤-តាមនីតិវិធីជ្រើសតាំងមជ្ឈត្តករ ដែលបានព្រមព្រៀងដោយភាគីវិវាទភាគីវិវាទណាក៏ដោយ អាចធ្វើសំណូមពរទៅតុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះឱ្យចាត់វិធានការចាំបាច់ ក្នុងករណីណាមួយដូចខាងក្រោម :

ក-ភាគីវិវាទមួយមិនបានប្រតិបត្តិតាមការតម្រូវក្នុងនីតិវិធី ឬ

ខ-ភាគីវិវាទ ឬ មជ្ឈត្តករពីរ (២) នាក់ មិនអាចឈានដល់ការព្រមព្រៀងដូចដែលគេរំពឹងទុកតាមនីតិវិធីនេះ ឬ

គ-ភាគីទីបី ដោយរាប់បញ្ចូលទាំងស្ថាប័នមួយផង មិនបានអនុវត្តមុខនាទីណាមួយដូចដែលបានប្រគល់ឱ្យក្នុងនីតិវិធីនោះ ។ មាត្រានេះ មិនត្រូវបានយកមកអនុវត្តទេ ប្រសិនបើការព្រមព្រៀងស្ដីពីនីតិវិធីជ្រើសតាំងមជ្ឈត្តករមានចែងពីវិធីផ្សេងទៀតសម្រាប់ធានាដល់ការជ្រើសតាំងនោះ ។

៥-ការជ្រើសតាំងរបស់តុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ លើបញ្ហាណាមួយតាមកថាខណ្ឌទី ៣ ឬ កថាខណ្ឌទី ៤ នៃមាត្រានេះ គឺជាការសម្រេចដែលមិនអាចតវ៉ាបានឡើយ ។ នៅក្នុងការជ្រើសតាំងមជ្ឈត្តករម្នាក់ តុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ត្រូវពិចារណាពីលក្ខណៈសម្បត្តិរបស់មជ្ឈត្តករដែលបានចែងក្នុងកិច្ចព្រមព្រៀងរបស់ភាគីវិវាទ ដើម្បីធានាដល់ការជ្រើសតាំងមជ្ឈត្តករដែលឯករាជ្យ និងមិនលម្អៀង ។ ក្នុងករណីមានមជ្ឈត្តករតែមួយនាក់

ឬ មានមជ្ឈត្តករទីបី នៅក្នុងការធ្វើមជ្ឈត្តការដែលមានលក្ខណៈអន្តរជាតិ តុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ត្រូវពិនិត្យលទ្ធភាពជ្រើសតាំងមជ្ឈត្តករដែលមានសញ្ជាតិផ្សេងពីសញ្ជាតិរបស់ភាគីវិវាទ ដូចមានចែងក្នុងចំណុច ១ នៃមាត្រា ១៩ នៃច្បាប់នេះ ។

**មាត្រា ២០.-**

បុគ្គលម្នាក់ដែលត្រូវគេជ្រើសតាំងជាមជ្ឈត្តករ ត្រូវបង្ហាញពីលក្ខណៈពិសេសដែលអាចបង្កឱ្យមានការសង្ស័យពីភាពមិនលម្អៀង ឬ ពីភាពឯករាជ្យរបស់ខ្លួន ចាប់ពីពេលដែលត្រូវគេជ្រើសតាំងមក រហូតដល់ពេលបញ្ចប់នីតិវិធីការមជ្ឈត្តការ ។ មជ្ឈត្តករត្រូវបង្ហាញពីលក្ខណៈពិសេសទាំងនោះឱ្យភាគីវិវាទបានដឹង ដោយគ្មានពន្យារពេល លើកលែងតែភាគីវិវាទបានដឹងពីលក្ខណៈសម្បត្តិរបស់មជ្ឈត្តករនោះរួចហើយ ។

មជ្ឈត្តករម្នាក់អាចត្រូវជំទាស់តែក្នុងករណីដែលកើតមានការសង្ស័យពីលក្ខណៈពិសេសដែលប៉ះពាល់ដល់ភាពមិនលម្អៀង ឬ ភាពឯករាជ្យរបស់ខ្លួន ឬ នៅពេលដែលខ្លួនមិនមានលក្ខណៈសម្បត្តិដូចដែលភាគីវិវាទបានព្រមព្រៀង ។ ភាគីវិវាទមួយអាចជំទាស់នឹងមជ្ឈត្តករដែលខ្លួនបានជ្រើសតាំង ឬ បានចូលរួមជ្រើសតាំងតែក្នុងករណីដែលមូលហេតុនៃការជំទាស់នោះត្រូវបានដឹងក្រោយពេលជ្រើសតាំងរួចប៉ុណ្ណោះ ។

**មាត្រា ២១.-**

ភាគីវិវាទដែលមានបំណងជំទាស់ទៅនឹងមជ្ឈត្តករ ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម :

១-ភាគីវិវាទ អាចព្រមព្រៀងលើនីតិវិធីនៃការជំទាស់នឹងមជ្ឈត្តករដោយអនុលោមតាមបទប្បញ្ញត្តិនៃកថាខណ្ឌទី ៣ ក្នុងមាត្រានេះ ។

២-ក្នុងករណីគ្មានការព្រមព្រៀងលើនីតិវិធីនៃការជំទាស់នេះ ភាគីវិវាទមួយដែលមានបំណងជំទាស់នឹងមជ្ឈត្តករ ត្រូវធ្វើលិខិតគតិបញ្ជាក់មូលហេតុពីការជំទាស់នោះជាលាយលក្ខណ៍អក្សរទៅកាន់វេទិកាមជ្ឈត្តកម្ម ក្នុងរយៈពេលដប់ប្រាំ (១៥) ថ្ងៃ ក្រោយពេលបង្កើតវេទិកាមជ្ឈត្តកម្ម ឬ ក្រោយពេលបានដឹងពីលក្ខណៈពិសេស ដូចចែងក្នុងមាត្រា ២០ នៃកថាខណ្ឌទី ២ ។ វេទិកាមជ្ឈត្តកម្មត្រូវសម្រេចលើការជំទាស់ លើកលែងតែមជ្ឈត្តករដែល

គេជំទាស់នោះ ដកខ្លួនចេញពីមុខតំណែង ឬ លើកលែងតែភាគីវិវាទមួយទៀតបានឯកភាព នឹងការជំទាស់នោះ ។

៣- ប្រសិនបើការជំទាស់ដែលត្រូវធ្វើតាមនីតិវិធីដែលព្រមព្រៀងដោយភាគីវិវាទ ឬ តាមនីតិវិធីក្នុងកថាខណ្ឌទី ២ នៃមាត្រានេះពុំបានសម្រេចទេនោះ ភាគីជំទាស់អាចស្នើសុំឱ្យតុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈ-មណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះធ្វើការសម្រេចចុងក្រោយលើការជំទាស់ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ បន្ទាប់ពីបានទទួលសេចក្ដីជូនដំណឹងបដិសេធការជំទាស់ ។ ក្នុងពេលរង់ចាំការសម្រេចរបស់តុលាការលើសំណើជំទាស់នេះ វេទិកាមជ្ឈត្តកម្មក្នុងនោះមានទាំងមជ្ឈត្តករដែលត្រូវគេជំទាស់ផងអាចបន្តដំណើរការមជ្ឈត្តការ ហើយអាចធ្វើសេចក្ដីសម្រេចបាន ។

**មាត្រា ២២.-**

ប្រសិនបើមជ្ឈត្តករម្នាក់ពុំអាចបំពេញមុខងាររបស់ខ្លួនបានដោយមូលហេតុខាងច្បាប់ ឬ មូលហេតុជាក់ស្ដែងណាមួយ ឬ មូលហេតុផ្សេងទៀតក្នុងរយៈពេលមួយសមស្របនោះ អាណត្តិរបស់មជ្ឈត្តករនោះត្រូវបានបញ្ចប់ដោយមជ្ឈត្តករនោះដកខ្លួនចេញពីមុខតំណែង ឬ ដោយភាគីវិវាទឯកភាពបញ្ចប់អាណត្តិនោះ ។ ផ្ទុយពីនេះ បើនៅតែមានភាពខ្វែងគ្នាស្ដីពីមូលហេតុណាមួយ ក្នុងចំណោមមូលហេតុទាំងនេះ ភាគីណាក៏ដោយអាចស្នើសុំឱ្យតុលា-ការ (តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាកាកំពូល) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះធ្វើការសម្រេចចុងក្រោយពីការបញ្ចប់អាណត្តិនោះ ។

តាមមាត្រានេះ ឬ មាត្រា ២១ កថាខណ្ឌទី ២ នៃច្បាប់នេះ ប្រសិនបើមជ្ឈត្តករម្នាក់ដកខ្លួនចេញពីមុខតំណែង ឬ ប្រសិនបើភាគីមួយឯកភាពចំពោះការបញ្ចប់អាណត្តិរបស់មជ្ឈត្តករនោះ ហេតុការណ៍នេះមិនបណ្ដាលឱ្យមានការទទួលយកជាការបាននូវមូលហេតុណាមួយដែលចែងក្នុងមាត្រានេះ ឬ មាត្រា ២០ កថាខណ្ឌទី ២ នៃច្បាប់នេះឡើយ ។

មាត្រា ២៣.–

ក្នុងករណីដែលអាណត្តិរបស់មជ្ឈត្តករម្នាក់ត្រូវបញ្ចប់តាមបញ្ញត្តិនៃមាត្រា ២១ ឬ មាត្រា ២២ នៃច្បាប់នេះ មជ្ឈត្តករជំនួសនឹងត្រូវជ្រើសតាំងស្របតាម វិធាននៃមាត្រា ១៨ នៃច្បាប់នេះ ។

## ជំពូកទី ៥
## សមត្ថកិច្ចរបស់វេទិកាមជ្ឈត្តកម្ម

មាត្រា ២៤.–

សមត្ថកិច្ចរបស់វេទិការមជ្ឈត្តកម្មត្រូវកំណត់ដូចខាងក្រោម :

១-វេទិកាមជ្ឈត្តកម្មអាចសម្រេចទៅតាមសមត្ថកិច្ចរបស់ខ្លួន ក្នុងនោះមានការជំទាស់នានាដែលទាក់ទងនឹងអត្ថិភាព ឬ សុពលភាពនៃកិច្ចព្រមព្រៀងផ្សះផ្សា ។ សម្រាប់គោលដៅនេះ ខចែងស្តីពីការផ្សះផ្សាដែលបង្កើតបានជាផ្នែកមួយនៃកិច្ចសន្យា ត្រូវចាត់ទុកថាជាកិច្ចព្រមព្រៀងដោយឡែក ដែលមិនទាក់ទិនទៅនឹងល័ក្ខខ័ណ្ឌដទៃទៀតក្នុងកិច្ចសន្យាឡើយ ។ ការសម្រេចរបស់វេទិកាមជ្ឈត្តកម្ម ដែលចាត់ទុកកិច្ចសន្យាថាមោឃៈ និងអសារឥតការមិននាំអោយខចែងស្តីពីការផ្សះផ្សានោះបាត់សុពលភាពឡើយ ។

២-ទឡ្ហីករណីដែលបញ្ជាក់ថា វេទិកាមជ្ឈត្តកម្មពុំមានអំណាចធ្វើមជ្ឈត្តការនោះ ត្រូវបង្ហាញឱ្យឃើញមុនការដាក់ជូនពាក្យដោះសា ។ មិនត្រូវហាមឃាត់ភាគីវិវាទមួយមិនឱ្យលើកឡើងពីទឡ្ហីករណីបែបនេះ ដោយសារតែភាគីនោះបានតែងតាំង ឬ បានចូលរួមតែងតាំងមជ្ឈត្តករឡើយ ។ ទឡ្ហីករណីដែលបញ្ជាក់ថា ក្របខ័ណ្ឌជំលោះដែលមានកើតហួសពីក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់វេទិការមជ្ឈត្តកម្មត្រូវបង្ហាញភ្លាមៗនៅពេលដែលបញ្ហាហួសក្របខ័ណ្ឌសមត្ថកិច្ចនេះ ត្រូវបានគេលើកឡើងក្នុងពេលធ្វើមជ្ឈត្តការ ។ ក្នុងចំណោមករណីទាំងពីរ វេទិកាមជ្ឈត្តកម្មអាចទទួលយកទឡ្ហីករណី ដែលលើកឡើងក្រោយរយៈពេលកំណត់ ប្រសិនបើពិចារណាឃើញថា ការយឺតយ៉ាវនេះមានភាពត្រឹមត្រូវ ។

៣-វេទិកាមជ្ឈត្តកម្មអាចធ្វើសេចក្តីសម្រេចលើទឡ្ហីករណីដូចចែងក្នុងកថាខណ្ឌ

ទី ២ នៃមាត្រានេះ ដោយចាត់ទុកថាជាបញ្ហាដំបូង ឬ ថាជាការសម្រេចតាមជាក់ស្តែង ។ ប្រសិនបើវេទិកាមជ្ឈត្តកម្មចាត់ទុកថាជាបញ្ហាដំបូងដែលខ្លួនមានអំណាចសម្រេចនោះ ភាគីណាក៏ដោយ ក៏អាចធ្វើសំណើទៅតុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ឱ្យសម្រេចចុងក្រោយលើបញ្ហានេះក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ក្រោយពីបានទទួលសេចក្តីជូនដំណឹងពីការសម្រេចនោះរបស់វេទិកា ។ ការសម្រេចរបស់តុលាការក្នុងរឿងនេះគឺជាការសម្រេចដែលមិនអាចតវ៉ាបាន ។ ក្នុងពេលរង់ចាំការសម្រេចពីតុលាការនោះ វេទិកាមជ្ឈត្តកម្មអាចបន្តដំណើរការមជ្ឈត្តការ និងអាចធ្វើមជ្ឈត្តវិនិច្ឆ័យបាន ។

មាត្រា ២៥.-

តាមការស្នើសុំរបស់ភាគីវិវាទមួយ វេទិកាមជ្ឈត្តកម្មអាចបង្គាប់ឱ្យភាគីណាមួយចាត់វិធានការបណ្តោះអាសន្នទៅតាមការចាំបាច់ទាក់ទិននឹងកម្មវត្ថុវិវាទ វៀរលែងតែភាគីវិវាទបានព្រមព្រៀងគ្នាផ្សេងពីនេះ ។ វេទិកាមជ្ឈត្តកម្មអាចតម្រូវឱ្យភាគីវិវាទណាមួយបង់ប្រាក់ធានាសមស្របសម្រាប់វិធានការនេះ ។

## ជំពូកទី ៦
## ដំណើរការនៃនីតិវិធីមជ្ឈត្តការ

មាត្រា ២៦.-

ភាគីវិវាទត្រូវបានទទួលការយកចិត្តទុកដាក់ស្មើៗគ្នា និងត្រូវបានផ្តល់ឱកាសពេញលេញ ដើម្បីបង្ហាញពីរឿងក្តីរបស់ខ្លួនរួមទាំងសិទ្ធិតែងតាំងជនណាម្នាក់ឱ្យធ្វើជាតំណាងរបស់ខ្លួនបាន ។

មាត្រា ២៧.-

ភាគីវិវាទអាចព្រមព្រៀង ឬ មិនព្រមព្រៀងលើនីតិវិធីដែលវេទិកាមជ្ឈត្តកម្ម ត្រូវអនុវត្តដើម្បីចាត់ចែងដំណើរការមជ្ឈត្តការ ។

ក្នុងករណីគ្មានការព្រមព្រៀងពីនីតិវិធីនេះទេ វេទិកាមជ្ឈត្តកម្មអាចចាត់ចែងការធ្វើមជ្ឈត្តការទៅតាមបែបបទណាដែលវេទិកាយល់ឃើញថាសមស្រប ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។ អំណាចដែលត្រូវបានប្រគល់ឱ្យទៅវេទិកាមជ្ឈត្តកម្មមានអំណាចក្នុងការកំណត់ពីភាពយកជាការបាននៃភស្តុតាងណាមួយ ។

### មាត្រា ២៨.-

ភាគីវិវាទអាចព្រមព្រៀងពីទីកន្លែងមជ្ឈត្តការ ។ ក្នុងករណីមិនបានព្រមព្រៀងពីទីកន្លែងទេ វេទិកាមជ្ឈត្តកម្មត្រូវកំណត់ទីតាំងដោយគិតគូរពីលក្ខណៈពិសេសនៃវិវាទ ក្នុងនោះត្រូវមានការឯកភាពពីភាគីវិវាទផង ។

ថ្វីបើមានបទប្បញ្ញត្តិក្នុងវាក្យខណ្ឌទី ១ នៃមាត្រានេះក៏ដោយ ក៏វេទិកាមជ្ឈត្តកម្មអាចប្រជុំនៅកន្លែងណាមួយដែលសមស្របក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ក្នុងបំណងពិគ្រោះយោបល់ក្នុងចំណោមសមាជិករបស់វេទិកា ស្តាប់សាក្សី ស្តាប់អ្នកជំនាញការ ស្តាប់ភាគីវិវាទ ឬ ធ្វើអធិការកិច្ចលើសម្ភារៈ កម្មសិទ្ធិ ឬ ឯកសារដទៃទៀត ។

### មាត្រា ២៩.-

ដំណើរការមជ្ឈត្តការដែលទាក់ទងនឹងវិវាទណាមួយ ចាប់ផ្តើមឡើងនៅថ្ងៃនៃកាលបរិច្ឆេទ ដែលភាគីឆ្លើយតបបានទទួលសំណើសុំឱ្យធ្វើមជ្ឈត្តការ វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ។

### មាត្រា ៣០.-

ភាគីវិវាទអាចព្រមព្រៀងលើភាសាណាមួយ ឬ លើសពីមួយ ដែលត្រូវប្រើប្រាស់ក្នុងដំណើរការធ្វើមជ្ឈត្តការ ។ ក្នុងករណីគ្មានការឯកភាពលើភាសាទេ វេទិកាមជ្ឈត្តកម្មត្រូវកំណត់ភាសាណាមួយ ឬ លើសពីមួយសម្រាប់ប្រើប្រាស់ក្នុងដំណើរការមជ្ឈត្តការ ។

វេទិកាមជ្ឈត្តកម្មអាចបង្គាប់ឱ្យមានការបកប្រែភ្ជាប់ជាមួយនឹងឯកសារ ភស្តុតាង ដោយប្រើប្រាស់ភាសាណាមួយ ឬ លើសពីមួយ ដែលបានឯកភាពដោយភាគីវិវាទ ឬ ដែលបានកំណត់ដោយវេទិកាមជ្ឈត្តកម្ម ។

**មាត្រា ៣១.-**

នៅក្នុងរយៈពេលដែលឯកភាពដោយភាគីវិវាទ ឬ កំណត់ដោយវេទិកាមជ្ឈត្តកម្ម អ្នកប្តឹងទាមទារត្រូវបញ្ជាក់ពីអង្គហេតុ ដើម្បីគាំទ្រការទាមទាររបស់ខ្លួនព្រមទាំងបញ្ជាក់ពីចំណុចជាក់លាក់នៃបញ្ហា និងសំណងការខូចខាតដែលត្រូវទាមទារ ហើយភាគីឆ្លើយតបត្រូវឆ្លើយបញ្ជាក់ពីការដោះសាលើចំណុចទាំងនេះ វៀរលែងតែភាគីវិវាទបានព្រមព្រៀងថា ក្នុងបណ្តឹងទាមទារ ឬ ការដោះសា ត្រូវបញ្ជាក់ផ្សេងពីនេះ ។ ភាគីវិវាទអាចភ្ជាប់ឯកសារទាំងអស់ដែលយល់ថាទាក់ទងនឹងពាក្យបណ្តឹងទាមទារ ឬ ពាក្យដោះសា ឬ អាចបន្ថែមការយោងលើឯកសារ ឬ ភស្តុតាងដទៃទៀត ដែលភាគីទាំងនោះត្រូវដាក់ជូនវេទិកាមជ្ឈត្តកម្ម ។

វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ភាគីវិវាទមួយអាចសុំកែសម្រួល ឬ បំពេញបន្ថែមលើពាក្យបណ្តឹងទាមទារ ឬ ពាក្យដោះសារបស់ខ្លួនបាន ក្នុងពេលកំពុងដំណើរការធ្វើមជ្ឈត្តការ លើកលែងតែវេទិកាមជ្ឈត្តកម្មយល់ថា ការសុំពន្យារពេលដើម្បីកែសម្រួលនេះពុំមានលក្ខណៈសមស្រប ។

**មាត្រា ៣២.-**

លើកលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ វេទិកាមជ្ឈត្តកម្មត្រូវសម្រេចថា តើត្រូវធ្វើសវនាការដោយផ្ទាល់មាត់ដើម្បីបង្ហាញពីភស្តុតាង ឬ ទឡ្ហីករណ៍ផ្ទាល់មាត់ ឬ ក៏ត្រូវដំណើរការមជ្ឈត្តការដោយផ្អែកលើមូលដ្ឋាននៃឯកសារ ឬ លិខិតស្នាមដទៃទៀត ។ ក៏ប៉ុន្តែ បើមានសំណើពីភាគីវិវាទមួយ វេទិកាមជ្ឈត្តកម្មត្រូវរៀបចំសវនាការបែបនេះ ក្នុងដំណាក់កាលសមស្របណាមួយនៃមជ្ឈត្តការ វៀរលែងតែភាគីវិវាទបានឯកភាពថា មិនត្រូវធ្វើសវនាការ ។

ត្រូវជូនដំណឹងឱ្យបានគ្រប់គ្រាន់ជាមុនដល់ភាគីវិវាទស្តីពីសវនាការ ឬ កិច្ចប្រជុំណាមួយរបស់វេទិកាមជ្ឈត្តកម្ម ដែលមានគោលបំណងធ្វើអធិការកិច្ចលើសម្ភារៈ ទំនិញ ទ្រព្យសម្បត្តិ និងឯកសារដទៃទៀត ។

រាល់សេចក្តីថ្លែង ឯកសារ ឬ ព័ត៌មានដទៃទៀត ដែលភាគីវិវាទមួយផ្តល់ជូនវេទិកាមជ្ឈត្តកម្ម ក៏ត្រូវបញ្ជូនទៅឱ្យភាគីវិវាទម្ខាងទៀតដែរ ។ របាយការណ៍របស់អ្នកជំនាញការ ឬ

ឯកសារភស្តុតាងណាមួយ ដែលវេទិកាមជ្ឈត្តកម្មអាចយកជាសំអាង ដើម្បីធ្វើការសម្រេច ក៏ត្រូវបញ្ជូនជាដំណឹងឱ្យភាគីវិវាទដែរ ។

មាត្រា ៣៣.–

វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ហើយបើគ្មានការបង្ហាញមូលហេតុគ្រប់គ្រាន់ :

១-វេទិកាមជ្ឈត្តកម្មត្រូវបញ្ចប់ដំណើរការមជ្ឈត្តការ ក្នុងករណីដែលអ្នកប្តឹងពុំមានបញ្ជាក់លើពាក្យបណ្តឹងទាមទាររបស់ខ្លួនតាមមាត្រា ៣១ នៃ កថាខណ្ឌទី ១ នៃច្បាប់នេះ ។

២-បើភាគីឆ្លើយតបពុំអាចផ្តល់សេចក្តីដោះសាររបស់ខ្លួនដូចចែងក្នុងមាត្រា ៣១ នៃកថាខណ្ឌទី ១ នៃច្បាប់នេះ វេទិកាមជ្ឈត្តកម្មត្រូវបន្តដំណើរការមជ្ឈត្តការដោយពុំចាត់ទុកការខកខាននេះថា ជាការទទួលស្គាល់ពាក្យចោទប្រកាន់របស់ភាគីប្តឹងទាមទារឡើយ ។

៣-បើភាគីវិវាទណាមួយពុំបានបង្ហាញមុខនៅសវនាការ ឬ ពុំបានផ្តល់ឯកសារភស្តុតាង វេទិកាមជ្ឈត្តកម្មអាចបន្តដំណើរការ ហើយធ្វើសេចក្តីសម្រេចដោយផ្អែកលើភស្តុតាងដែលមាននៅចំពោះមុខ ។

មាត្រា ៣៤.–

វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ វេទិកាមជ្ឈត្តកម្មអាច :

១-តែងតាំងអ្នកជំនាញការម្នាក់ ឬ ច្រើននាក់ ដើម្បីរាយការណ៍ឱ្យខ្លួនស្តីពីបញ្ហាជាក់លាក់នានា ដែលកំណត់ដោយវេទិកាមជ្ឈត្តកម្ម ។

២-តម្រូវឱ្យភាគីវិវាទមួយផ្តល់ព័ត៌មាន ឬ ឯកសារ ឬ អនុញ្ញាតឱ្យអ្នកជំនាញការពិនិត្យលើឯកសារ សម្ភារៈដែលសមស្របផ្សេងៗដែលទាក់ទងដល់ការធ្វើអធិការកិច្ចរបស់អ្នកជំនាញការ ។

វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ប្រសិនបើមានភាគីវិវាទមួយស្នើសុំ ឬ វេទិកាមជ្ឈត្តកម្មយល់ថាចាំបាច់ អ្នកជំនាញការបន្ទាប់ពីបានបង្ហាញរបាយការណ៍ផ្ទាល់មាត់ ឬ លាយលក្ខណ៍អក្សររួចហើយ ត្រូវចូលរួមក្នុងសវនាការដែលក្នុងឱកាសនោះ ភាគីវិវាទអាចលើកសំណួរ និងអញ្ជើញជំនាញការផ្សេងទៀត ក្នុងនាមជាសាក្សី ដើម្បីបញ្ជាក់ពីចំណុចជាក់លាក់នៃជម្លោះ ។

មាត្រា ៣៥.-

វេទិកាមជ្ឈត្តកម្ម ឬ ភាគីវិវាទមួយដោយបានការឯកភាពពីវេទិកាមជ្ឈត្តកម្ម អាចស្នើសុំជំនួយពីតុលាការ (តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល) ក្នុងការត្រួតពិនិត្យភស្តុតាង ។ តុលាការ (តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬតុលាការកំពូល) អាចអនុវត្តតាមសំណើនេះនៅក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន និងដោយអនុលោមតាមវិធានស្តីពីការត្រួតពិនិត្យភស្តុតាង ។

## ជំពូកទី ៧
## ការធ្វើមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម
## និងការបញ្ចប់ដំណើរការមជ្ឈត្តការ

មាត្រា ៣៦.-

ក្នុងការធ្វើមជ្ឈត្តវិនិច្ឆ័យវេទិកាមជ្ឈត្តកម្មត្រូវ ៖

១-សម្រេចពីវិវាទមួយទៅតាមវិធាននៃច្បាប់ ដែលជ្រើសរើសដោយភាគីវិវាទ និងដែលអនុវត្តបានចំពោះកម្មវត្ថុនៃវិវាទនេះ ។ ការកំណត់យកច្បាប់ ឬ ប្រព័ន្ធច្បាប់នៃប្រទេសណាមួយដែលត្រូវយកទៅបកស្រាយ គឺមិនត្រូវបកស្រាយដោយសំអាងលើភាពផ្ទុយគ្នានៃច្បាប់ ឬ វិធាននៃច្បាប់នោះឡើយ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ ។

២-ប្រើប្រាស់ច្បាប់ណាដែលយល់ថាអាចអនុវត្តបាន ក្នុងករណីដែលភាគីវិវាទមិនបានធ្វើការកំណត់លើប្រព័ន្ធច្បាប់ទេនោះ ។

៣-ធ្វើមជ្ឈត្តវិនិច្ឆ័យស្របតាមសមធម៌ ឬ តាមការសម្រុះសម្រួលតែក្នុងករណីដែលភាគីវិវាទអនុញ្ញាតច្បាស់លាស់ឱ្យធ្វើដូច្នោះ ។

៤-ធ្វើមជ្ឈត្តវិនិច្ឆ័យឱ្យស្របតាមលក្ខខណ្ឌនៃកិច្ចសន្យា និងត្រូវយកចិត្តទុកដាក់ផងដែរដល់ទម្លាប់ផ្នែកពាណិជ្ជកម្ម ដែលអនុវត្តបានចំពោះមុខជំនួញនោះ ។

**មាត្រា ៣៧.-**

ក្នុងដំណើរការមជ្ឈត្តការដែលមានមជ្ឈត្តករលើសពីមួយនាក់ មជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម ត្រូវធ្វើឡើងតាមមតិភាគច្រើនដោយប្រៀបនៃមជ្ឈត្តករ ដែលជាសមាជិកនៃវេទិកាមជ្ឈត្តកម្ម ។

**មាត្រា ៣៨.-**

មុនពេលចាប់ផ្ដើមដំណើរការមជ្ឈត្តការផ្លូវការ វេទិកាមជ្ឈត្តកម្មត្រូវពិភាក្សាជាមួយភាគីវិវាទ ដើម្បីស្វែងរកលទ្ធភាពនៃការដោះស្រាយវិវាទដោយស្ម័គ្រចិត្តរបស់ភាគី ៖

១-ប្រសិនបើភាគីវិវាទព្រមដោះស្រាយវិវាទដោយស្ម័គ្រចិត្ត វេទិកាមជ្ឈត្តកម្មត្រូវជួយភាគីវិវាទទៅតាមបែបបទដែលសមស្រប ។

២-ប្រសិនបើភាគីវិវាទបានស្រុះស្រួលគ្នាមុនពេលចាប់ផ្ដើម ឬ ក្នុងពេលកំពុងធ្វើមជ្ឈត្តការជាផ្លូវការ វេទិកាមជ្ឈត្តកម្មត្រូវបញ្ឈប់ដំណើរការ ។ ប្រសិនបើមានការស្នើសុំពីភាគីវិវាទ វេទិកាមជ្ឈត្តកម្មអាចកត់ត្រាទុកការដោះស្រាយនោះ ក្នុងមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម ។

៣-មជ្ឈត្តវិនិច្ឆ័យដែលផ្អែកលើការស្រុះស្រួល ត្រូវធ្វើឡើងតាមបទប្បញ្ញត្តិក្នុងមាត្រា ៣៩ នៃច្បាប់នេះ ហើយត្រូវបញ្ជាក់ថាជាមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម ។ មជ្ឈត្តវិនិច្ឆ័យនេះមានលក្ខណៈ និង ឥទ្ធិពលដូចមជ្ឈត្តវិនិច្ឆ័យដទៃទៀតដែលវេទិកាមជ្ឈត្តកម្មធ្វើដោយផ្អែកលើភាពជាក់ស្ដែងនៃវិវាទដែរ ។

**មាត្រា ៣៩.-**

មជ្ឈត្តវិនិច្ឆ័យត្រូវមានទម្រង់ទ្រាយ និងខ្លឹមសារដូចខាងក្រោម ៖

១-មជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្មត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវចុះហត្ថលេខាដោយមជ្ឈត្តករ ។ ក្នុងដំណើរការមជ្ឈត្តការដែលមានមជ្ឈត្តករលើសពីមួយនាក់ ហត្ថលេខារបស់សមាជិកភាគច្រើនក្នុងវេទិកាមជ្ឈត្តកម្មត្រូវបានចាត់ទុកថាគ្រប់គ្រាន់ ល្គឹកណាមានការបញ្ជាក់ពីមូលហេតុដែលមជ្ឈត្តករដទៃទៀតមិនបានចុះហត្ថលេខា ។

២-មជ្ឈត្តវិនិច្ឆ័យត្រូវបញ្ជាក់ពីមូលហេតុនានាដែលបានយកមកធ្វើជាគោលបង្អែក លើកលែងតែភាគីវិវាទបានព្រមព្រៀងគ្នាថាមិនចាំបាច់បញ្ជាក់ពីមូលហេតុទេ ឬ លើកលែងតែ

មជ្ឈត្តវិនិច្ឆ័យដែលផ្អែកលើការស្រុះស្រួលរបស់ភាគី ដូចមានចែងក្នុងមាត្រា ៣៨ នៃច្បាប់នេះ ។

៣-មជ្ឈត្តវិនិច្ឆ័យត្រូវបញ្ជាក់ពីសោហ៊ុយចំណាយក្នុងការធ្វើមជ្ឈត្តការ ដែលភាគីវិវាទមានចំណែកត្រូវចេញ ក្នុងនោះមានប្រាក់កម្រៃសម្រាប់មជ្ឈត្តករនិងការចំណាយផ្សេងៗ ដែលបានបម្រុងទុកជាមុន ដោយអនុលោមតាមបែបបទដែលព្រមព្រៀងដោយភាគីវិវាទ ឬ អនុលោមតាមការយល់សមស្របរបស់មជ្ឈត្តករ ប្រសិនបើគ្មានការព្រមព្រៀងដោយភាគីទេ ។ មជ្ឈត្តវិនិច្ឆ័យអាចចែងផងដែរពីសោហ៊ុយចំណាយសមស្របសម្រាប់ការពិគ្រោះច្បាប់ ដែលត្រូវសងទៅឱ្យភាគីឈ្នះ ប្រសិនបើភាគីវិវាទបានព្រមព្រៀងដូច្នោះ ឬ មជ្ឈត្តករយល់ថាសមស្រប ។

៤-មជ្ឈត្តវិនិច្ឆ័យត្រូវចែងពីកាលបរិច្ឆេទ និងទីកន្លែងផ្សះផ្សាដូចកំណត់ក្នុងមាត្រា ២៨ កថាខណ្ឌទី ១ នៃច្បាប់នេះ ។ ត្រូវចាត់ទុកទីកន្លែងធ្វើមជ្ឈត្តការជាទីកន្លែងធ្វើមជ្ឈត្តវិនិច្ឆ័យ ។

៥-បន្ទាប់ពីធ្វើមជ្ឈត្តវិនិច្ឆ័យរួចហើយ អត្ថបទចម្លងនៃមជ្ឈត្តវិនិច្ឆ័យនោះ ដែលចុះហត្ថលេខាដោយមជ្ឈត្តករតាមបែបបទក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវបញ្ជូនទៅឱ្យភាគីវិវាទនីមួយៗ ។

**មាត្រា ៤០.-**

ដំណើរការមជ្ឈត្តការត្រូវបញ្ចប់ដោយធ្វើមជ្ឈត្តវិនិច្ឆ័យជាស្ថាពរ ឬ ដោយដីកាបង្គាប់របស់វេទិកាមជ្ឈត្តកម្មស្របតាមកថាខណ្ឌទី ២ នៃមាត្រានេះ ។

វេទិកាមជ្ឈត្តកម្មចេញដីកាបង្គាប់ដើម្បីបញ្ចប់ដំណើរការមជ្ឈត្តការ នៅក្នុងករណីដែល :

១-ភាគីប្តឹងទាមទារដកពាក្យទាមទាររបស់ខ្លួន វៀរលែងតែភាគីឆ្លើយតបធ្វើការជំទាស់នឹងការដកពាក្យនោះ ហើយវេទិកាមជ្ឈត្តកម្មទទួលស្គាល់ពីអត្ថប្រយោជន៍ស្របច្បាប់របស់ភាគីឆ្លើយតបក្នុងការទទួលដំណោះស្រាយវិវាទជាស្ថាពរ ។

២-ភាគីវិវាទឯកភាពឱ្យបញ្ចប់ដំណើរការមជ្ឈត្តការ ។

៣-វេទិកាមជ្ឈត្តកម្មរកឃើញមូលហេតុផ្សេងទៀត ដែលបញ្ជាក់ពីភាពមិនចាំបាច់សម្រាប់បន្តដំណើរការ ឬ ការធ្វើមជ្ឈត្តការនោះពុំអាចបន្តទៅទៀតកើត ។

/.

អាណត្តិរបស់វេទិកាមជ្ឈត្តកម្មបញ្ចប់ជាមួយនឹងការបញ្ចប់ដំណើរការមជ្ឈត្តការតាមបទប្បញ្ញត្តិនៃមាត្រា ៤១ និងមាត្រា ៤២ កថាខណ្ឌទី ៤ នៃច្បាប់នេះ ។

មាត្រា ៤១.-

ការកែតម្រូវនិងការបកស្រាយមជ្ឈត្តវិនិច្ឆ័យត្រូវគោរពតាមល័ក្ខខ័ណ្ឌដូចខាងក្រោម :

១-ក្នុងកំឡុងពេលសាមសិប (៣០) ថ្ងៃ យ៉ាងយូរបន្ទាប់ពីទទួលមជ្ឈត្តវិនិច្ឆ័យ វៀរលែងតែភាគីវិវាទបានព្រមព្រៀងលើរយៈពេលបន្តទៀត :

ក-ភាគីវិវាទមួយដែលបានជូនដំណឹងដល់ភាគីវិវាទម្ខាងទៀតអាចស្នើសុំឱ្យវេទិកាមជ្ឈត្តកម្មកែតម្រូវកំហុសផ្នែកគណនា កំហុសផ្នែកការងារលេខាធិការ និងកំហុសនៃការបោះពុម្ព ឬ កំហុសដទៃទៀត ដែលមានលក្ខណៈស្រដៀងគ្នា ។

ខ-ភាគីវិវាទមួយដែលបានជូនដំណឹងដល់ភាគីវិវាទម្ខាងទៀត អាចស្នើសុំឱ្យវេទិកាមជ្ឈត្តកម្មផ្តល់ការបកស្រាយ ឬ ការបំភ្លឺលម្អិតពីចំណុច ឬ ផ្នែកណាមួយនៃមជ្ឈត្តវិនិច្ឆ័យ ប្រសិនបើភាគីវិវាទបានព្រមព្រៀងដូច្នេះ ។ ប្រសិនបើយល់ថាសំណើនោះសមស្របវេទិកាមជ្ឈត្តកម្មត្រូវបកស្រាយ ឬ បំភ្លឺលម្អិតក្នុងរយៈពេលយ៉ាងយូរសាមសិប (៣០) ថ្ងៃ បន្ទាប់ពីទទួលសំណើ ។ ការបកស្រាយ ឬ ការបំភ្លឺលម្អិតនោះ ត្រូវបញ្ចូលជាផ្នែកមួយនៃមជ្ឈត្តវិនិច្ឆ័យ ។

២-ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃយ៉ាងយូរ ក្រោយកាលបរិច្ឆេទចេញមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្មអាចកែតម្រូវកំហុសដូចដែលចែងក្នុងកថាខណ្ឌទី ១ក នៃមាត្រានេះ ទៅតាមគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ ។

៣-វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ក្នុងរយៈពេលយ៉ាងយូរសាមសិប (៣០) ថ្ងៃ ក្រោយពីទទួលបានមជ្ឈត្តវិនិច្ឆ័យ ភាគីវិវាទមួយដែលបានជូនដំណឹងដល់ភាគីវិវាទម្ខាងទៀត អាចស្នើសុំឱ្យវេទិកាមជ្ឈត្តការធ្វើមជ្ឈត្តវិនិច្ឆ័យបន្ថែម ដូចជាដោយសារការទាមទារនានា ដែលលើកឡើងក្នុងដំណើរការមជ្ឈត្តការនោះ មិនបានដាក់ចូលទៅក្នុងមជ្ឈត្តវិនិច្ឆ័យ ។ ប្រសិនបើយល់ឃើញថាសំណើនោះសមស្របវេទិកាមជ្ឈត្តកម្ម ត្រូវធ្វើមជ្ឈត្តវិនិច្ឆ័យបន្ថែមក្នុងរយៈពេលយ៉ាងយូរសាមសិប (៣០) ថ្ងៃ ។

៤-ប្រសិនបើចាំបាច់ និងដោយមានជូនដំណឹងដល់ភាគីវិវាទ វេទិកាមជ្ឈត្តកម្មអាចពន្យាររយៈពេលដែលកំណត់សម្រាប់ការកែតម្រូវការបកស្រាយ ការបំភ្លឺលម្អិត ឬ ការធ្វើមជ្ឈត្តវិនិច្ឆ័យបន្ថែមតាមកថាខណ្ឌទី ១ និងកថាខណ្ឌទី ៣ នៃមាត្រានេះ ។

៥-បទប្បញ្ញត្តិនានានៃមាត្រា ៣៩ នៃច្បាប់នេះ ត្រូវយកទៅអនុវត្តសម្រាប់កែតម្រូវការបកស្រាយ ឬ ការបំភ្លឺលម្អិតលើមជ្ឈត្តវិនិច្ឆ័យ ឬ ការចេញមជ្ឈត្តវិនិច្ឆ័យបន្ថែម ។

## ជំពូកទី ៨
## ការប្តឹងជំទាស់ ការទទួលស្គាល់
## និង ការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ

### ផ្នែកទី១
### ស្ថាប័នមានសមត្ថកិច្ចក្នុងការប្តឹងជំទាស់
### ការទទួលស្គាល់ និងការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ

**មាត្រា ៤២.-**

សេចក្តីសម្រេចលើការប្តឹងជំទាស់ ការទទួលស្គាល់ និងការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ ជាសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤៣.-**

តុលាការកំពូលជាសាលាជំនុំជម្រះក្តីចុងក្រោយ ដែលមានសមត្ថកិច្ចជំនុំជម្រះបណ្តឹងជំទាស់របស់ភាគីវិវាទ ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ក្នុងរយៈពេលដប់ប្រាំថ្ងៃ (១៥) ថ្ងៃ ។

### ផ្នែកទី ២
### បណ្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យ

**មាត្រា ៤៤.-**

ភាគីវិវាទអាចប្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យតាមទម្រង់ជាបណ្តឹងបដិសេធ និងតាមបែបបទដូចខាងក្រោម ៖

១-បណ្ដឹងបដិសេធទៅនឹងមជ្ឈត្តវិនិច្ឆ័យតាមផ្លូវតុលាការ អាចធ្វើទៅបានលុះត្រាតែស្របតាមលក្ខខណ្ឌ ដូចមានចែងក្នុងវាក្យខណ្ឌទី ២ និងវាក្យខណ្ឌទី ៣ នៃមាត្រានេះ ។

២-សាលាឧទ្ធរណ៍ និង តុលាការកំពូលអាចបដិសេធមជ្ឈត្តវិនិច្ឆ័យរបស់មជ្ឈត្តករ បានក្នុងករណី :

ក-ភាគីដែលដាក់ពាក្យសុំបដិសេធបានផ្ដល់ភស្តុតាងគ្រប់គ្រាន់ថា :

ក.១-ភាគីមួយនៃកិច្ចព្រមព្រៀងផ្សះផ្សាដូចមានយោងក្នុងមាត្រា ៧ នៃច្បាប់នេះ បានបាត់បង់សិទ្ធិមួយចំនួនខាងផ្លូវច្បាប់ ឬ កិច្ចព្រមព្រៀងផ្សះផ្សានោះ ពុំអាចយកជាការបាន បើយោងតាមច្បាប់ដែលភាគីវិវាទបានសំអាង ឬ កិច្ចព្រមព្រៀងផ្សះផ្សាពុំបានគោរពតាមបញ្ញត្តិណាមួយនៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ក.២-ភាគីដែលដាក់ពាក្យសុំបដិសេធនោះ មិនបានទទួលដំណឹងត្រឹមត្រូវពីការតែងតាំងមជ្ឈត្តករ ឬ ពីដំណើរការមជ្ឈត្តការ ឬ ភាគីនេះពុំអាចបង្ហាញពីអង្គហេតុរបស់ខ្លួនបានដោយប្រសិទ្ធភាព ។

ក.៣-មជ្ឈត្តវិនិច្ឆ័យដែលទាក់ទិននឹងវិវាទនោះពុំឆ្លើយតប ឬ ពុំគោរពលក្ខខណ្ឌនៃកិច្ចព្រមព្រៀងផ្សះផ្សា ។ ប្រសិនបើបញ្ហាដែលដាក់ឱ្យធ្វើមជ្ឈត្តការនោះ អាចផ្ដាច់ចេញពីបញ្ហាដែលមិនបានដាក់ឱ្យធ្វើមជ្ឈត្តការ ការបដិសេធអាចធ្វើទៅបានតែត្រង់ផ្នែកមួយនៃមជ្ឈត្តវិនិច្ឆ័យ លើបញ្ហាដែលបានដាក់ឱ្យធ្វើមជ្ឈត្តការពីមុនប៉ុណ្ណោះ ។

ក.៤-ការបង្កើតវេទិកាមជ្ឈត្តកម្ម ឬ ដំណើរការមជ្ឈត្តការ ពុំស្របនឹងកិច្ចព្រមព្រៀងរបស់ភាគីវិវាទ ក្នុងករណីដែលកិច្ចព្រមព្រៀងនោះស្របតាមបទបញ្ញត្តិនៃច្បាប់នេះ ។ ក្នុងករណីដែលគ្មានកិច្ចព្រមព្រៀងផ្សះផ្សាទេ ការបង្កើតវេទិកាមជ្ឈត្តកម្ម ឬ ដំណើរការមជ្ឈត្តការខាងលើមិនសមស្របតាមច្បាប់នេះ ។

ខ-សាលាឧទ្ធរណ៍ និង តុលាការកំពូលរកឃើញថា :

ខ.១- កម្មវត្ថុនៃវិវាទនោះ ពុំអាចដោះស្រាយបានតាមរយៈការធ្វើមជ្ឈត្តការឡើយ បើយោងទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ខ.២-មជ្ឈត្តវិនិច្ឆ័យនោះផ្ទុយនឹងនយោបាយសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ។

៣-ការដាក់ពាក្យសុំបដិសេធមិនអាចធ្វើបានឡើយ បើរយៈពេលបានកន្លងផុតសាមសិប (៣០) ថ្ងៃ គិតពីថ្ងៃដែលភាគីសុំបដិសេធនោះទទួលបានមជ្ឈត្តវិនិច្ឆ័យ ឬ ប្រសិនបើសំណើនោះធ្វើឡើងតាមមាត្រា ៤១ នៃច្បាប់នេះ រយៈពេលសាមសិប (៣០) ថ្ងៃ គិតពីកាលបរិច្ឆេទដែលវេទិកាមជ្ឈត្តកម្មបានដោះស្រាយលើសំណើនោះ ។

៤-នៅពេលទទួលដំណឹងបដិសេធមជ្ឈត្តវិនិច្ឆ័យ បើមានលក្ខណៈសមស្របហើយមានសំណើពីភាគីមួយ សាលាឧទ្ធរណ៍ និង តុលាការកំពូលអាចផ្អាកដំណើរការបដិសេធនេះ នៅក្នុងរយៈពេលមួយដែលកំណត់ដោយសាលាឧទ្ធរណ៍ និង តុលាការកំពូល ដើម្បីផ្តល់ឱកាសដល់វេទិកាមជ្ឈត្តកម្មធ្វើដំណើរការមជ្ឈត្តការឡើងវិញ ឬ ចាត់វិធានការមួយតាមការយល់ឃើញរបស់វេទិកាថា អាចនឹងលុបបំបាត់មូលហេតុនៃការសុំបដិសេធនោះបាន ។

## ផ្នែកទី ៣
## ការទទួលស្គាល់ និងការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ

**មាត្រា ៤៥.-**

មជ្ឈត្តវិនិច្ឆ័យ ទោះជាបានធ្វើនៅប្រទេសណាក៏ដោយត្រូវបានគេទទួលស្គាល់ថាជាកាតព្វកិច្ច ហើយបន្ទាប់ពីបានដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរទៅសាលាឧទ្ធរណ៍រួចមក ត្រូវបានអនុវត្តដោយយោងតាមបទប្បញ្ញត្តិក្នុងមាត្រានេះ និងមាត្រា ៤៤ ។

ភាគីដែលសំអាងលើមជ្ឈត្តវិនិច្ឆ័យ ឬ ដែលដាក់ពាក្យសុំឱ្យមានការអនុវត្តមជ្ឈត្តវិនិច្ឆ័យ ត្រូវផ្តល់ច្បាប់ដើមត្រឹមត្រូវពិតប្រាកដនៃមជ្ឈត្តវិនិច្ឆ័យ និងច្បាប់ដើមនៃកិច្ចព្រមព្រៀងផ្សះផ្សាដូចចែងក្នុងមាត្រា ៧ នៃច្បាប់នេះ ឬ អត្ថបទថតចម្លងដែលបញ្ជាក់ថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។ ប្រសិនបើមជ្ឈត្តវិនិច្ឆ័យ ឬ កិច្ចព្រមព្រៀងនោះមិនបានធ្វើជាភាសាខ្មែរទេ ភាគីនោះត្រូវផ្តល់សេចក្តីបកប្រែជាភាសាខ្មែរ ដែលមានការបញ្ជាក់ត្រឹមត្រូវតាមច្បាប់ដើម ។

**មាត្រា ៤៦.-**

ទោះបីជាមជ្ឈត្តវិនិច្ឆ័យធ្វើនៅប្រទេសណាក៏ដោយ ការជំទាស់ទៅនឹងការទទួលស្គាល់ ឬ ជំទាស់ទៅនឹងការដាក់ឱ្យអនុវត្តនូវមជ្ឈត្តវិនិច្ឆ័យ អាចធ្វើបានតែក្នុងករណី ៖

១-អនុវត្តន៍តាមសំណើរបស់ភាគីជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យ ដោយភាគីនោះផ្តល់ភស្តុតាងដល់សាលាឧទ្ធរណ៍ថា :

ក-ភាគីមួយនៃកិច្ចព្រមព្រៀងផ្សះផ្សាដូចបានយោងក្នុងមាត្រា ៧ បានបាត់បង់សិទ្ធិមួយចំនួនខាងផ្លូវច្បាប់ ឬ កិច្ចព្រមព្រៀងនោះពុំអាចយកជាការបាន បើយោងតាមច្បាប់ដែលភាគីវិវាទបានសំអាង ឬ កិច្ចព្រមព្រៀងផ្សះផ្សាពុំបានគោរពតាមការកំណត់ណាមួយនៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ឬ

ខ-ភាគីដែលជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យនោះ ពុំទទួលបានព័ត៌មានត្រឹមត្រូវពីការតែងតាំងមជ្ឈត្តករ ឬ ពីដំណើរការមជ្ឈត្តការពុំអាចបង្ហាញពីករណីរបស់ខ្លួនបានដោយប្រសិទ្ធភាព ឬ

គ-មជ្ឈត្តវិនិច្ឆ័យដែលទាក់ទងនឹងវិវាទនោះពុំឆ្លើយតប ឬ ពុំគោរពលក្ខខណ្ឌនៃកិច្ចព្រមព្រៀងផ្សះផ្សា ឬ ក៏បញ្ហាដែលបានសម្រេចនោះហួសពីក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងផ្សះផ្សា ។ ប្រសិនបើការសម្រេចលើបញ្ហាដែលបានដាក់ជូនឱ្យផ្សះផ្សា អាចផ្តាច់ចេញពីបញ្ហាដែលពុំបានដាក់ឱ្យផ្សះផ្សានោះ ផ្នែកមួយនៃមជ្ឈត្តវិនិច្ឆ័យលើបញ្ហាដែលបានដាក់ជូនអាចត្រូវគេទទួលស្គាល់ និងដាក់អោយអនុវត្ត ឬ

ឃ-ការបង្កើតវេទិកាមជ្ឈត្តកម្ម ឬ ដំណើរការមជ្ឈត្តការពុំសមស្របជាមួយនឹងកិច្ចព្រមព្រៀងរបស់ភាគីវិវាទ ឬ ប្រសិនបើគ្មានកិច្ចព្រមព្រៀងផ្សះផ្សានោះទេ ការបង្កើតវេទិកាមជ្ឈត្តកម្ម ឬ ដំណើរការមជ្ឈត្តការ គឺពុំសមស្របទៅនឹងច្បាប់នៃប្រទេសដែលការផ្សះផ្សាបានប្រព្រឹត្តទៅ ឬ

ង-មជ្ឈត្តវិនិច្ឆ័យនោះពុំទាន់បានក្លាយទៅជាកាតព្វកិច្ចនៅឡើយសម្រាប់ភាគីវិវាទ បើយោងតាមច្បាប់នៃប្រទេសដែលធ្វើសេចក្តីសម្រេចនោះ ឬ ម្យ៉ាងទៀតមជ្ឈត្តវិនិច្ឆ័យត្រូវបានបដិសេធ ឬ ព្យួរទុក ដោយតុលាការនៃប្រទេសដែលធ្វើមជ្ឈត្តវិនិច្ឆ័យ ឬ

២-ប្រសិនបើសាលាឧទ្ធរណ៍រកឃើញថា :

ក-កម្មវត្ថុនៃវិវាទនោះ ពុំអាចដោះស្រាយបានតាមការធ្វើមជ្ឈត្តការឡើយ បើយោងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬ

ខ-ការទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យនោះ អាចផ្ទុយនឹងនយោបាយសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ។

បើមានការសុំឱ្យសាលាឧទ្ធរណ៍បដិសេធ ឬ ព្យួរទុកមជ្ឈត្តវិនិច្ឆ័យ ដូចមានចែងក្នុងកថាខណ្ឌទី ១ (ង) នៃមាត្រានេះ ហើយប្រសិនបើសាលាឧទ្ធរណ៍យល់ថាត្រឹមត្រូវ សាលាឧទ្ធរណ៍ដែលភាគីវិវាទស្នើសុំការទទួលស្គាល់ ឬ ការអនុវត្តមជ្ឈត្តវិនិច្ឆ័យនោះ អាចបញ្ឈប់ការសម្រេចរបស់ខ្លួន ហើយអាចបញ្ជាឱ្យភាគីវិវាទម្ខាងទៀតផ្តល់ការធានាសមស្របទៅតាមសំណូមពររបស់ភាគីដែលសុំឱ្យមានការទទួលស្គាល់ ឬ ការអនុវត្តមជ្ឈត្តវិនិច្ឆ័យ ។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**មាត្រា ៤៧.-**

បទប្បញ្ញត្តិទាំងឡាយណាក្នុងវិស័យមជ្ឈត្តការពាណិជ្ជកម្មដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០០៦

**នស/រកម/០៥០៦/០១០ ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ហត្ថលេខា**

**ចម ប្រសិទ្ធ**

ដើម្បីចម្លងចែកចាយ

រាជធានីភ្នំពេញថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០០៦

អគ្គលេខាធិការរាជរដ្ឋាភិបាល